## អ្នកជួយពិនិត្យ

១ ឧទ្ទេសាចារ្យ **ធម្មសារោ ផុន សោភ័ណ** (វត្តឧត្តមមានជ័យ)

២ ព្រះធម្មកថិកាចារ្យ **សាន ភារ៉េត** ( វត្តរោងដំរី )

៣ ភិក្ខុ **នុត មុនីរ៉េត** ( វត្តរស្មីសាមគ្គី )

៤ ភិក្ខុ **អឿន អេន** ( វត្តរោងដំរី )

៥ ភិក្ខុ **កែវ រតនះ** ( វត្តរោងដំរី )

៦ ភិក្ខុ **សុខ ធម្មភាសី** ( វត្តសំសមី )

៧ ភិក្ខុ **ប៉ែន វិបុល** ( វត្តសំសមី )

៨ សាស្ត្រាចារ្យ **វ៉ា ប៊ិន** ( វត្តនិគ្រោធវ័ន )

៩ សាស្ត្រាចារ្យ **តុប ហឿន** ( ព្រៃវែង )

១០ ឧបាសក **សោម រតនះ** ( ព្រៃវែង )

១១ ក្រុមព្រះសង្ឃ និង ពុទ្ធបរិស័ទ ជាច្រើននាក់ទៀត

## មាតិកា ទំព័រ


១ អារម្ភកថា ........................................................ ក

២ ប្រវត្តិរូបអ្នកនិពន្ធ .................................................. ខ

៣ មហាពលិកម្មរបស់មាតាបិតា .................................... ១

៤ មាតាបិតាមានឈ្មោះ ៤ យ៉ាង ..................................... ២

៥ មាតាបិតាមានគុណ ៤ យ៉ាង ....................................... ៣

៦ មរតករបស់មាតាបិតា ៣ យ៉ាង .................................. ៤

៧ បុត្រមានប្រភេទ ៣ យ៉ាង .......................................... ៥

៨ រឿងព្រះបាទអជាតសត្រូវ .......................................... ៦

៩ គុណមាតាបិតា ( កំណាព្យ ) ....................................... ៧

១០ ភ្លើងអាចរលត់ដោយភ្លៀងរលឹម ( កំណាព្យ ) ............. ៨

១១ បាបកម្មចិញ្ចឹមកូន ( កំណាព្យ ) ................................ ៩

១២ កូនស្តាយក្រោយណាស់ ( កំណាព្យ ) ........................ ១០

១៣ ម៉ែត្រេកអរនឹងកូនសាងផ្នួស ( កំណាព្យ ) ................ ១១

១៤ អវសានកថា ( កំណាព្យ ) ................................... ១២

១៥ នាមសប្បុរសជន ................................................ ១៣

## សហការីកុំព្យូទ័រ

១ ភិក្ខុ **ផាន់ ភារ័ក្ស**

២ ភិក្ខុ **ម៉ង់ សុខា**

៣ ភិក្ខុ **អ៊ឹម សំអាត**

៤ ភិក្ខុ **ពង់ ណាក់**

៥ សាមណេរ **ខិន ហាន**

៦ សាមណេរ **ពុំ គន្ធី**

៧ សាមណេរ **ជាម វិចិត្រ**

## អារម្ភកថា

នៅក្នុងសង្គមសព្វថ្ងៃនេះ មានកូនអកតញ្ញូពួកខ្លះបានវាយធ្វើបាបមាតាបិតារបស់ខ្លួន សម្លុត គម្រាម កំហែងមាតាបិតារបស់ខ្លួនដែលមានវ័យចាស់ជរា ឱ្យរងទឹកភ្នែក រងការឈឺចាប់ ប្រមាថមើលងាយជារៀងរាល់ថ្ងៃ ។ ដោយមានការអាណិតអាសូរចំពោះមាតាបិតាគ្រប់រូប ដែលលោកខំប្រឹងប្រែងចិញ្ចឹមបីបាច់មើលថែរក្សាកូន ៗ នោះ ខ្ញុំក៏បានព្យាយាមសរសេរសៀវភៅមួយក្បាលដែលឱ្យឈ្មោះថា"**មហាពលិកម្មរបស់មាតាបិតា**" គឺសៀវភៅដែលលោកអ្នកកំពុងតែអាននេះឯង។ ម្យ៉ាងទៀត សម្រាប់ទុកជាសម្បត្តិធម្មទាន ក្នុងឱកាសបុណ្យបំពេញឧបសម្បទាជាភិក្ខុ របស់ខ្លួនខ្ញុំផ្ទាល់ ដែលនឹងប្រារព្ធធ្វើនៅ **វត្តរស្មីសាមគ្គី** ភូមិពងទឹក ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង នៅថ្ងៃ ៨រោច ខែ ផល្គុន ឆ្នាំ ច អដ្ឋស័ក ព.ស ២៥៥០ ត្រូវនឹងថ្ងៃ អាទិត្យ ទី ១១ ខែ មិនា ឆ្នាំ ២០០៧ ។

នេះជាលើកដំបូងបង្អស់ហើយ ក្នុងមួយឆាកជីវិតរបស់ខ្ញុំ ដែលបានបន្សល់ទុកនូវស្នាដៃផ្ទាល់ខ្លួន សម្រាប់ជាប្រយោជន៍ដល់សាធារណជន។ ធម្មតាការងារថ្មីតែងតែជួបការលំបាកឧបសគ្គរាំងស្ទះជាច្រើន និងមានចំណុចខ្វះខាតមិនខានឡើយ ។ រឿងនេះហើយ ដែលបានធ្វើឱ្យខ្ញុំមានក្ដីកង្វល់ជាយូរខែថ្ងៃ ខ្ញុំបានអង្គុយសញ្ជឹងគិតពិចារណាម្ដងហើយម្ដងទៀត សាចុះសាឡើង ៗ នៅទីបំផុត ខ្ញុំក៏បានកាន់យកនូវគំនិតមួយថា មានខុសទើបមានត្រូវ ឬមានឧបសគ្គទើបមានជ័យជំនះ ។ ដូច្នេះហើយ ខ្ញុំក៏បានសម្រេចចិត្តថា នឹងសរសេរសៀវភៅនេះ ឱ្យបានចប់សព្វគ្រប់ទាន់ពេលថ្ងៃបុណ្យបួសរបស់ខ្ញុំ ។ ក្រោយពេលបានសរសេរចប់សព្វគ្រប់ភ្លាម ខ្ញុំក៏បានយកសំនេរ ដែលខ្ញុំបានសរសេរនេះ ទៅជូនលោកអ្នកចេះដឹងជាច្រើនរូប ដើម្បីសុំឱ្យលោកជួយពិនិត្យកែតម្រូវលើចំណុចខ្លះ ៗ និងសុំមតិយោបល់បន្ថែមពីលើនេះខ្លះ ៗ ទៀត ដើម្បីឱ្យមានភាពសុក្រឹត្យត្រឹមត្រូវឡើង នៅក្នុងការបោះពុម្ពផ្សព្វផ្សាយជាធម្មទានលើកនេះ។ ទោះបីជាមានការពិនិត្យបានហ្មត់ចត់យ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា គង់នៅមានកំហុសឆ្គងទាំងឡាយ ទាំងផ្នែកឃ្លោងឃ្លា អត្ថន័យ ខ្លឹមសារ អក្ខរាវិរុទ្ធ ពាក្យពេចន៍ ធ្ងន់ស្រាល ដោយការភ្លាំងភ្លាត់មិនលែងឡើយ ។ ដូច្នេះហើយ ខ្ញុំសង្ឃឹមទុកជាមុនថា លោកអ្នកអានទាំងឡាយ នឹងអភ័យទោស រាល់កំហុសឆ្គងគ្រប់យ៉ាង ដែលបានកើតមានឡើងដោយសារការភ្លាំងភ្លាត់នោះ ។ ខ្ញុំរីករាយនឹងទទួលស្វាគមន៍នូវរាល់ពាក្យរិះគន់ ក្នុងលក្ខណៈជួយកែលំអអំពីសំណាក់ លោកអ្នកជាពហុស្សូត អ្នកចេះដឹងទាំងឡាយគ្រប់ពេលវេលាជានិច្ច ។

ដោយអំណាចនៃបុញ្ញកម្មនេះ សូមឱ្យខ្ញុំបានឆ្លងដល់ត្រើយពោលគឺព្រះនិព្វាន បើមិនទាន់បានដល់ទេ អន្ទោលទៅចាប់កំណើតកើតនៅក្នុងជាតិណា ភពណា ក៏សូមឱ្យខ្ញុំបានកើតនៅក្នុងប្រទេសដ៏សមគួរ ត្រកូលជាសមាទិដ្ឋិ ជាមនុស្សសម្បូរទៅដោយប្រាជ្ញារកទីបំផុតគ្មាន សូមឱ្យបានជួបតែនឹង ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយសូមឱ្យមានសទ្ធា បានចេញសាងផ្នួសបួសជាបព្វជិតនៅក្នុងសំណាក់ព្រះពុទ្ធសាសនាគ្រប់ៗជាតិ ។ សូមឱ្យលោកអ្នកអានទាំង

ឡាយ បានសម្រេចនូវបុណ្យកុសលច្រើន ៗ បានសមប្រកបជួបប្រទះ នូវសម្បត្តិ ៣ ប្រការ គឺ **សម្បត្តិមនុស្ស** ១ **សម្បត្តិទេព្ដា** ១ **សម្បត្តិព្រះនិព្វាន** ១ ព្រមទាំងពុទ្ធពរទាំង ៤ ប្រការ គឺ **អាយុ** ១ **វណ្ណៈ** ១ **សុខៈ** ១ **ពលៈ** ១ កុំបីអាក់ខានឡើយ ។/

**ព.ស ២៥៥០**

ព្រៃវែង ,ថ្ងៃ ពុធ ១៥ កើត ខែ ស្រាពណ៍ ឆ្នាំ ច អដ្ឋស័ក ________

**គ.ស ២០០៦**

# ប្រវត្តិរូបអ្នកនិពន្ធ

សាមណេរ : **ឈុំ ឈន់** កើតនៅថ្ងៃសៅរ៍ ទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៨៤ នៅភូមិព្រៃខ្នុរ ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង ។

- ញោមប្រុសឈ្មោះ **សួន ឈុំ**
- ញោមស្រីឈ្មោះ **ឃិន ហ៊ាន**

មានបងប្អូនបង្កើតចំនួន៥នាក់គឺប្រុស ៣ នាក់ ស្រី ២ នាក់ :

- **ឈុំ ឈាន** (ប្រុស)
- **ឈុំ ស្រីអូន** (ស្រី)
- **ឈុំ ឈន់** (ប្រុស)
- **ឈុំ រ៉ាឌី** (ស្រី)
- **ឈុំ សារឯម** (ប្រុស)

កំរិតវប្បធម៌មុនពេលបួស រៀនបានដល់ថ្នាក់ទី ៥ នៃសាលាបឋមសិក្សាវត្តរស្មីសាមគ្គី ។ ពេលអាយុបាន ១៣ ឆ្នាំ ត្រូវបាន

មាតាបិតានាំយកទៅផ្ញើនឹងព្រះគ្រូ : **នុត មុន្នីរ៉េត** ជាមន្ត្រីសង្ឃឃុំ និង ជាព្រះគ្រូចៅអធិការ **វត្តរស្មីសាមគ្គី** ភូមិពងទឹក ឃុំ ព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង ។ នៅអាយុ ១៤ ឆ្នាំ បានបួសជាសាមណេរនៅក្នុងវត្តខាងលើ (ឆ្នាំ១៩៩៩) ដោយបាននិមន្តព្រះភិក្ខុ : **សីលប្បញ្ញោ : ឡុង ភាជ** (វត្តចន្ទ័ក្រីស្នា) មកធ្វើជាព្រះឧបជ្ឈាយ៍ ។

- នៅអាយុ ១៥ ឆ្នាំ ត្រូវបានព្រះភិក្ខុ **នុត មុន្នីរ៉េត** ដែលជាគ្រូផ្ទាល់បញ្ជូនឱ្យទៅសិក្សាភាសាបាលីថ្នាក់ទី ១ នៅ វត្តសំរោង ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង (២០០០) ។

- នៅអាយុ ១៦ ឆ្នាំ បានបន្តទៅសិក្សាថ្នាក់ទី ២ នៅក្នុងសំណាក់ព្រះគ្រូអនុគណសង្ឃស្រុកមេសាងព្រះនាម **ទិត្យ មុនី** វត្ត **ពោធិមង្គល** ឃុំជីផុច ស្រុកមសាង ខេត្តព្រៃវែង (២០០១) ។

- នៅអាយុ ១៧ ឆ្នាំ បានបន្តទៅសិក្សាថ្នាក់ទី ៣ ជាមួយនឹងព្រះគ្រូឧទ្ទេសាចារ្យ **ធម្មសារោ ផុនសោភ័ណ** វត្តឧត្តមមានជ័យ ភូមិពាមកោះ ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង(២០០២) ។

នៅពេលបំណាច់ឆ្នាំសិក្សាទី ៣ នេះដែរ បានប្រឡងជាប់យកវិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សា និងបានប្រឡងជាប់ចូលរៀននៅសាលាពុទ្ធិកវិទ្យាល័យព្រៃវែង។

- នៅអាយុ ១៨ ឆ្នាំ បានបន្តមកសិក្សានៅថ្នាក់ឆ្នាំទី ១ ជំនាន់ទី ៥ នៅឯពុទ្ធិកវិទ្យាល័យនៃពុទ្ធិកមធ្យមសិក្សាបឋមភូមិ ព្រៃវែង (២០០៣) ។

- នៅអាយុ ២១ ឆ្នាំ បានប្រឡងជាប់សញ្ញាប័ត្រពុទ្ធិក-មធ្យមសិក្សាបឋមភូមិ នៅឯមណ្ឌលប្រឡង ពុទ្ធិកវិទ្យាល័យស្វាយរៀង **វត្តជម្ពូព្រឹក្សា** ខាងកើតទីរួមខេត្ត ព្រមទាំងបានប្រឡងជាប់ចូលរៀន នៅឯសាលាពុទ្ធិកវិទ្យាល័យនៃពុទ្ធិកមធ្យមសិក្សាទុតិយភូមិខេត្តព្រៃវែង នៅមណ្ឌលប្រឡងពុទ្ធិកវិទ្យាល័យព្រៃវែង វត្ត **សុវណ្ណរង្សី** ទីរួមខេត្ត (២០០៥) ។

សព្វថ្ងៃនេះ មានអាយុ ២២ ឆ្នាំ ជាសមណសិស្សថ្នាក់ឆ្នាំទី១ ទុតិយភូមិ (សាលាខាងលើ) ស្នាក់នៅ **វត្តរោងដំរី** ឃុំកំពង់លាវ ស្រុកកំពង់លាវ ទីរួមខេត្តព្រៃវែង (២០០៦) ។/

# មហាពលិកម្មរបស់មាតាបិតា

បុរសស្ត្រីនៅក្នុងលោកសន្និវាសនេះមុននឹងមានឈ្មោះថា**មាតា**
ឬ **បិតា** បាន  លុះត្រាតែឆ្លងកាត់នូវឧបសគ្គភយន្តរាយផ្សេងៗរាប់
ម៉ឺនសែនបញ្ហា  ដែលមនុស្សដទៃមិនធ្លាប់ជាមាតាបិតាមិនអាចទ្រាំ
ទ្រធ្វើទៅកើត  ។ ក្រោយពេលមាតាបិតាបានគ្នាជាស្វាមីភរិយារួច
មក ពួកគាត់ក៏ប្រាថ្នាចង់បាននូវកូនប្រុសផងកូនស្រីផង  សម្រាប់ត
ពូជពង្សវង្សត្រកូលរបស់ខ្លួន  មិនមានមាតាបិតាណានៅក្នុងលោក
នេះដែលមិនប្រាថ្នាចង់បាននូវផលគឺកូននោះឡើយ ។កាលបើមាតា
បិតាទាំងពីរនាក់ប្រាថ្នាចង់បានកូនហើយ   ពួកគាត់តែងធ្វើកិច្ចទាំង
ឡាយមានការអុជធូបបន់ព្រះសំពះទេវតាជាដើម  សូមឱ្យពួកគាត់
មានកូនសមតាមសេចក្ដីប៉ងប្រាថ្នារបស់ខ្លួន ។ ពេលដែលមានហេតុ
បច្ច័យប្រកបព្រមហើយ     គឺ     មានកំណើតសត្វចូលមកបដិសន្ធិ
នៅក្នុងផ្ទៃនៃស្ត្រីជាម្ដាយ មកសុំសេចក្ដីសង្គ្រោះពីស្ត្រីដែលជាម្ដាយ
ម្ដាយក៏មានអារម្មណ៍ខុសប្លែកពីសព្វដង  គឺមានអាការៈអស់កម្លាំង
ល្វិតល្វៃដៃជើងឧស្សាហ៍ឈឺក្បាលវិលមុខជាញឹកញាប់   ហើយគាត់
ក៏មិនប្រាកដខ្លួនឯងថា មានជំងឺអ្វីកើតឡើងនោះដែរ គាត់គ្រាន់តែ
មានការងឿងឆ្ងល់នៅក្នុងចិត្តតែប៉ុណ្ណោះ  ។ ក្រោយមកគាត់ក៏បាន
ប្រាប់រឿងរ៉ាវទាំងប៉ុន្មានដល់ស្វាមីរបស់គាត់ឱ្យបានដឹង អ្នកទាំងពីរ
ក៏មានការព្រួយបារម្ភនៅក្នុងចិត្តជាខ្លាំង  ហើយក៏បានយករឿងរ៉ាវ
ទាំងអស់នោះប្រាប់ដល់ជីដូនជីតា ម៉ែឪ បងប្អូន អ៊ំ ពូ មីង មា ទាំង
សងខាងឱ្យពួកគាត់បានដឹង  ព្រោះពួកគាត់ធ្លាប់បានដឹង  ធ្លាប់បាន
ឆ្លងកាត់រឿងរ៉ាវច្រើនបែបច្រើនយ៉ាងរួចមកហើយ  ។ ក្រោយមក
ទៀតពួកគាត់បានឮចាស់ទុំនិយាយគ្រប់ៗគ្នាថា  មានកូននៅក្នុងផ្ទៃ
ដូច្នេះ  （មានគភ៌）  ទាំងពីរនាក់ក៏សប្បាយរីករាយញញឹមញញែម
ដោយរំពឹងទុកជាមុនថាខ្លួននឹងមានកូនហើយ  ខ្លួនជិតបានក្លាយទៅ
ជាឪពុកជាម្ដាយរបស់គេហើយ ។មាតាបិតាខំប្រឹងព្យាយាមធ្វើការ
ឡើងទ្វេដង   មិនខ្លាចលំបាកនឿយហត់ឡើយ   ព្រោះគាត់ទាំងពីរ
នាក់គិតដល់កូនដែលនៅក្នុងផ្ទៃជានិច្ច  ខ្លាចក្រែងដល់ពេលកូនកើត
មកគ្មានទ្រព្យសម្បត្តិអ្វីទុកឱ្យកូន ។  ម៉ែដឹងប្រាកដនៅក្នុងចិត្តរបស់

ម៉ែថាម៉ែមានកូននៅក្នុងផ្ទៃ ដូច្នេះម៉ែធ្វើអ្វីក៏ដោយ ម៉ែទៅណាមកណាក៏ដោយ ម៉ែស្ថិតនៅក្នុងទីណាក៏ដោយ ម៉ែតែងតែមានការប្រុងប្រយ័ត្នជានិច្ចគ្រប់ឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ និងអង្គុយ ។ កាលពីដើមម៉ែដេកដោយទម្រេតខ្លួនយ៉ាងរហ័សបម្រះនឿលទៅវិញទៅមក ដល់ពេលក្រោកឡើងក៏ដូចគ្នា ម៉ែក្រោកដោយរហ័សមិនមានការប្រុងប្រយ័ត្ននោះឡើយ ប៉ុន្តែឥឡូវនេះម៉ែមិនអាចធ្វើដូច្នោះទៀតបានទេ ម៉ែត្រូវតែមានការប្រុងប្រយ័ត្នគ្រប់វិនាទីទើបបាន ម៉ែសម្រាន្តថ្នមៗ ម៉ែមិនហ៊ានបម្រះទៅមកដោយរហ័សនោះទេ ម៉ែក្រោកពីសម្រាន្តមកវិញក៏ក្រោកដោយថ្នមៗដែរ ។ពីមុនម៉ែធ្លាប់ដើរទៅណាមកណាតាមទំនើងចិត្តរបស់ខ្លួន ម៉ែចង់ទៅលេងទីផ្សារ ម៉ែចង់ទៅមើលវាលស្រែ ម៉ែចង់ទៅលេងចំការ ម៉ែចង់ទៅលេងនៅកន្លែងនេះកន្លែងនោះ ម៉ែចង់ទៅលេងនៅខេត្តនេះខេត្តនោះនៅតាមព្រៃភ្នំនិងរមណីយដ្ឋាននានាជាដើម ។បើម៉ែមានលុយម៉ែនឹងទៅលេងភ្លាមដើម្បីតម្រូវចិត្តរបស់ម៉ែ ។ ឥឡូវនេះ ខុសគ្នាពីមុនឆ្ងាយណាស់ ម៉ែមិនអាចទៅណាមកណាតាមតែទំនើងចិត្តរបស់

ខ្លួនបានទេ ម៉ែខ្លាចក្រែងដល់ពេលម៉ែជិះឡាន ជិះម៉ូតូទៅរលាក់ប៉ះពាល់ដល់កូនដែលនៅក្នុងផ្ទៃ ។ម៉ែមិនហ៊ានឈរនៅក្រោមកំដៅថ្ងៃដែលកំពុងតែក្តៅ ឬ ឈរនៅក្រោមមេឃដែលកំពុងតែមានភ្លៀងខ្លាំងនោះឡើយ ព្រោះតែម៉ែខ្លាចមានគ្រោះថ្នាក់ដល់កូនរបស់ម៉ែ ។ ចំណែកឯការអង្គុយក៏ដូចគ្នាដែរ មុននឹងអង្គុយម្តង ៗ ម៉ែគិតសព្វគិតគ្រប់ដង្ហើមចេញចូលទាំងអស់ គិតគ្រប់ពេលវេលា គ្មានចន្លោះម្តងណាឡើយ ។ រាល់ពេលដែលម៉ែទទួលទានអាហារម្តងៗ មិនថាតែបាយទឹកនំចំណីត្រីសាច់នោះទេ សូម្បីម៉ែទទួលទានរបស់អ្វីៗ ក៏ដោយ ម៉ែគិតណាស់ ចំណីអាហារណាដែលមិនផ្តល់ជីវជាតិដល់កូនរបស់ម៉ែ ឬក៏ ចំណីអាហារណា ដែលម៉ែទទួលទានទៅហើយផ្តល់ផលវិបាកទុក្ខទោសដល់កូនរបស់ម៉ែដែលនៅក្នុងផ្ទៃ ចំណីអាហារនោះ ទោះបីជារបស់គួរឱ្យឆ្ងាញ់គួរឱ្យចង់ពិសាយ៉ាងណាក៏ដោយចុះក៏បំពង់ករបស់ម៉ែបិទជិតអស់ហើយ មាត់របស់ម៉ែហាក់ដូចជាស្អិតជាប់គ្នាអស់ទៅហើយ មិនអាចនឹងហាមាត់លេបចំណីអាហារនោះបានឡើយ ដៃរបស់ម៉ែទាំងទ្វេទន់ល្វន់ល្វើយមិនអាចនឹងចាប់កាន់

យកចំណីអាហារទាំងនោះមកដាក់ចូលទៅក្នុងមាត់បានឡើយ ម៉ែមិនអាចទ្រាំធ្មេចភ្នែកលេបចំណីអាហារដែលខ្លួនចូលចិត្ត ដែលខ្លួនយល់ថា ចំណីអាហារដែលគួរឱ្យឆ្ងាញ់ពិសា ហើយទុកឱ្យកូនរបស់ខ្លួនដែលនៅក្នុងផ្ទៃនោះជួបទុក្ខលំបាកបានឡើយ ។ ទាំងអស់នេះក៏ព្រោះតែម៉ែគិតដល់កូនជាងគិតដល់ជីវិតរបស់ខ្លួន ម៉ែមាននូវមេត្តាធម៌ចំពោះកូនដែលនៅក្នុងផ្ទៃរបស់ម៉ែនោះ ។ ចំណែកឯចំណីអា-ហារណាដែលផ្តល់ជាតិវីតាមីនដល់កូន ដែលជំនួយដល់កូន ចំណីអាហារនោះ ទោះបីជាម៉ែមិនចូលចិត្ត ម៉ែមិនឃ្លាន ម៉ែលំបាកក្នុងការទទួលទានយ៉ាងណាក៏ដោយ ក៏ម៉ែនៅតែទ្រាំលេបទ្រាំទទួលទានចំណីអាហារនោះៗជានិច្ច ដើម្បីឱ្យកូនដែលនៅក្នុងផ្ទៃរបស់ម៉ែបានសុខស្រួល ។ ពេលខ្លះកូនបានធ្វើឱ្យម៉ែចង់ទទួលទានចង់ពិសារបស់នេះរបស់នោះ ចង់ពិសា ផ្លែស្វាយ ផ្លែក្រូច ផ្លែខ្វិត ផ្លែអម្ពិល ចង់របស់ជូរ របស់ហឹរ របស់ប្រៃជាដើម (ចាញ់គភ៌) កាលណាបើម៉ែបានទួលទាននូវរបស់នោះៗ ម៉ែអាចអត់ទ្រាំនូវចំណង់នោះបាន អាចកាត់បន្ថយទប់ទល់នូវចំណង់នោះបាន តែសម្រាប់ម៉ែដែលនៅតាមជនបទស្រុកស្រែចំការវិញ ពេលខ្លះម៉ែមិនអាចបានទទួលទានរបស់អ្វីៗទៅតាមចំណង់របស់ខ្លួននោះឡើយ ព្រោះរបស់ដែលម៉ែចង់ពិសាចង់បរិភោគនោះ វាមានទៅតាមរដូវកាល ទៅតាមពេលវេលារបស់វា ។ ពេលខ្លះទៀត ម៉ែមានអារម្មណ៍ថា ដូចជាធឹងធោងវិលមុខខ្សោះនៅក្នុងខ្លួនប្រាណ ថែមទាំងមានអាការៈក្អួតចង្អោរជាញឹកញាប់ទៀតផង ។ ដើម្បីកូន ម៉ែអាចធ្វើបានគ្រប់រឿងទាំងអស់ ពីមុនឈឺល្មមៗម៉ែមិនធ្លាប់ទៅកាន់មន្ទីរពេទ្យឡើយ ព្រោះម៉ែខ្លាចពេទ្យចាក់ថ្នាំដោយសេរ៉ាងម្ជុល ម៉ែខ្មាសពេទ្យប្រុសៗ ម៉ែមិនធ្លាប់លេបឱសថនោះឡើយ (ថ្នាំគ្រាប់) ម៉ែលំបាកណាស់ពេលលេបថ្នាំម្តងៗ ម៉ែក្អួតចង្អោរ ម៉ែទទឹងរឹងរូសនឹងលោកគ្រូពេទ្យប្រកែកមិនព្រមលេបថ្នាំ ម៉ែតែងលបលួចលាក់ថ្នាំ ដែលលោកគ្រូពេទ្យឱ្យមកទុកសម្រាប់លេប ម៉ែយកវាទៅក្រវាត់ចោលដោយមិនស្តាយស្រណោះបន្តិចសោះឡើយ ។ ប៉ុន្តែឥឡូវនេះ ម៉ែមានកូនហើយ ម៉ែមិនអាចធ្វើដូច្នោះទៀតបានទេ ម៉ែត្រូវតែទ្រាំលេបថ្នាំទ្រាំឱ្យពេទ្យចាក់ថ្នាំវ៉ាក់សាំង ម៉ែឧស្សាហ៍ឱ្យគេជូនទៅមន្ទីរពេទ្យជារឿយៗ

ទៀតផង ។ សូម្បីថ្នាំខ្មែរបុរាណដែលផ្សំឡើងដោយវត្ថុច្រើនមុខច្រើនយ៉ាងមានរសជាតិល្វីងយ៉ាងណាក៏ដោយ ដើម្បីកូន ម៉ែស៊ូទ្រាំបិទភ្នែកបិទច្រមុះលេបបានទាំងអស់។ ទន្ទឹមគ្នានឹងទុក្ខលំបាកទាំងអស់នេះ ម៉ែក៏ឧស្សាហ៍យកដៃរបស់គាត់ទៅស្ទាបអង្អែលថ្នមៗនៅលើពោះ ហើយលួចញញឹមតែម្នាក់ឯង ដោយរំពឹងទុកក្នុងចិត្តថាមិនយូរថ្ងៃទៀតទេ ខ្ញុំនឹងអាចបានឃើញមុខកូនហើយ ។ តើកូនរបស់ខ្ញុំប្រុសឬស្រី ល្អឬអាក្រក់ ល្ងង់ឬឆ្លាត តើវាកាត់មករកខ្ញុំឬកាត់ទៅរកឪពុករបស់វា ? ពេលខ្លះទៀត ម៉ែចេះតែគិតដល់កូនខ្លាំងពេក ម៉ែមិនអាចសប្បាយចិត្តបានទាល់តែសោះ ព្រោះម៉ែគិតថា កូនដែលនៅក្នុងផ្ទៃនោះ មិនដឹងជាមានទុក្ខលំបាកយ៉ាងណាទេ មិនដឹងជាកូនត្រូវការរបស់អ្វី ចង់បានរបស់អ្វី ក៏ម៉ែមិនដឹង ហើយចំណីអាហារដែលម៉ែទទួលទានទៅរាល់ថ្ងៃនោះក៏ម៉ែមិនបានដឹងថាចំណីអាហារណាមួយធ្វើឱ្យកូនបានសុខសប្បាយហើយចំណីអាហារណាមួយធ្វើឱ្យកូនមានសេចក្តីទុក្ខសេចក្តីលំបាកនោះឡើយ។ ដូច្នេះហើយ ទើបបានជាម៉ែគ្រប់ៗរូបចេះតែគិតបារម្ភដល់កូនដែលនៅក្នុងផ្ទៃ។ ម៉ែពផ្ទៃ ម៉ែរក្សាគភ៌អស់វេលាជាយូរខែយូរថ្ងៃ មិនមែនលំបាកតិចទេគឺពិតជាសែនលំបាកខ្លាំងណាស់ជាភារៈដ៏ធ្ងន់សែនធ្ងន់ក្រៃលែង ព្រោះគ្មានបុគ្គលណាម្នាក់អាចជួយធ្វើភារៈនេះជំនួសម៉ែបានឡើយ អាចជួយពផ្ទៃជំនួសម៉ែបានឡើយ តែម៉ែអាស្រ័យនូវទឹកចិត្តមេត្តា អាស្រ័យនូវកម្លាំងចិត្តម៉្យាងដែលគិតថា ចង់ឱ្យកូនដែលនៅក្នុងផ្ទៃបានរស់ ដូច្នេះគ្មានរឿងអ្វីដែលថា ម៉ែមិនអាចធ្វើបាននោះឡើយ។ ម៉ែពផ្ទៃ ម៉ែរក្សាគភ៌គ្រប់ ៩ ខែ ១០ ថ្ងៃ ហើយម៉ែក៏នឹងត្រូវដល់ពេលសម្រាលកូនដែលយើងរាល់គ្នានិយមហៅថា "ឆ្លងទន្លេ" ។

ចំណែកឯឪពុកវិញក៏មានការហត់នឿយខ្លាំងណាស់ដែរក្នុងអំឡុងពេលដែលម៉ែកំពុងតែពផ្ទៃនោះ ។ ការងារធ្ងន់ស្រាលតូចធំទាំងអស់រាប់រយជំពូក ត្រូវបានធ្លាក់មកលើឪពុកតែម្នាក់ឯងគត់ ។ ឪពុកគ្រប់រូបនៅពេលម៉ែឆ្លងទន្លេត្រូវធ្វើការងារតែម្នាក់ឯង ព្រោះគាត់មិនព្រមអនុញ្ញាតឱ្យប្រពន្ធរបស់គាត់ ដែលកំពុងតែពផ្ទៃនោះធ្វើការងារឡើយ សូម្បីការងារទាំងអស់នោះ ជាការងារធ្ងន់ក្តី

ស្រាលក្តី ក៏គាត់មិនអនុញ្ញាតឱ្យប្រពន្ធរបស់គាត់ធ្វើដែរ ព្រោះគាត់ខ្លាចមានគ្រោះថ្នាក់ដល់កូនរបស់គាត់ដែលនៅក្នុងផ្ទៃ ។ ទឹកចិត្តរបស់ឪពុកដែលមានចំពោះកូនក៏មិនខុសគ្នានឹងទឹកចិត្តរបស់ម៉ែដែរ គ្រាន់តែថា ឪពុកមិនបាន ពផ្ទៃមែន តែគាត់រ៉ាប់រងធ្វើការងារធ្ងន់ស្រាលគ្រប់ជំពូកទាំងអស់ជំនួសម៉ែ ដោយមិនខ្លាចការនឿយហត់នោះឡើយ ។ ឪពុកត្រូវប្រឹងប្រែងធ្វើការងារទាំងថ្ងៃទាំងយប់មិនខ្លាចការនឿយហត់ ដើម្បីបានកម្រៃទុកសម្រាប់ផ្គត់ផ្គង់គ្រួសារទុកសម្រាប់បម្រុងការពារពេលប្រពន្ធឆ្លងទន្លេជាដើម ។ ពេលខ្លះឪពុកត្រូវធ្វើការស៊ីឈ្នួលគេ ទោះបីជាត្រូវគេស្តីឱ្យម្តេចម្តា ក៏គាត់ខំអត់ទ្រាំដែរ ដើម្បីឱ្យតែបានប្រាក់កម្រៃ សម្រាប់យកមកផ្គត់ផ្គង់ក្រុមគ្រួសារ ។ ពេលខ្លះទៀតឪពុកគាត់ត្រូវស្វះស្វែងដើររកទិញថ្នាំសង្កូវសព្វបែបយ៉ាង សព្វទីកន្លែងមិនថាថ្នាំនោះមានតម្លៃថ្លៃហួសពីលុយកាក់ដែលខ្លួនមានក៏ដោយ ដើម្បីប្រពន្ធ និងកូនដែលនៅក្នុងផ្ទៃនោះ ឪពុកធ្វើបានទាំងអស់ ទោះបីជាតម្រូវឱ្យគាត់ខ្ចីបុលបញ្ចាំចងការប្រាក់អ្នកដទៃក៏ដោយ ។ ពេលជិតឆ្លងទន្លេ ម៉ែរៀបចំខ្លួនប្រាណដើម្បីបម្រុងត្រៀមទុកជាស្រេចឱ្យហើយ ។ ចំណែកឪពុកវិញគាត់រៀបចំផ្ទះសំបែង ដងទឹកចាក់ពាង ចាក់អាង រកអុស រកធ្យូងទុកបម្រុងជាស្រេច ហើយគាត់ប្រាប់ដំណឹងនេះដល់មាតាបិតាជីដូន ជីតា អ៊ំពូ មីងមា ញាតិមិត្រស្និទ្ធស្នាលទាំងខាងខ្លួន និងខាងភរិយារបស់ខ្លួនសុំឱ្យពួកគាត់មកជួយ ។

ពេលម៉ែពផ្ទៃ ឪពុករីងរៃ ស្មើរតែមរណា
ម្យ៉ាងរឿងរកស៊ី ផ្គត់ផ្គង់គ្រួសារ ម្យ៉ាងរឿងភរិយា
ជិតឆ្លងទន្លេ ។

គាត់សែនខ្វល់ខ្វាយ មិនដែលសប្បាយ ក្នុងចិត្តម្តងទេ
គិតមុខគិតក្រោយ មិនមានទំនេរ ក្នុងចិត្តរិះរេ
ខ្លាចក្រែងមានភ័យ ។

ប្រឹងប្រែងធ្វើការ ព្យាយាមឧស្សាហ៍ ជារៀងរាល់ថ្ងៃ
ក្រោកតាំងពីព្រឹក រៀបចំអ្វី ៗ រួចទើបលកលៃ
ចេញទៅធ្វើការ ។

ចេញដល់ក្រៅផ្ទះ គាត់ខំរួតរះ ស្វះស្វែងឧស្សាហ៍

គ្មានឈប់សម្រាក មួយគ្រាម្តងណា ដើម្បីភរិយា
កំពុងពផ្ទៃ ។
ខ្លួនប្រាណទៅក្រៅ តែចិត្តសំដៅ មកបុត្រចរណៃ
ព្រមទាំងភរិយា ជីវិតថ្លើមថ្លៃ នឹកគិតមមៃ
មិនដឹងយ៉ាងណា ។
លុះវិលមកផ្ទះ គាត់ខំរួតរះ ចំអិនអាហារ
ពេលឆ្អិនរួចស្រេច នាំគ្នាពិសា ជួបជុំគ្រួសារ
រួចទើបសម្រាន្ត ។

ថ្ងៃឆ្លងទន្លេបានចូលមកដល់ មនុស្សម្នាជាច្រើននាក់មានសាច់ញាតិទាំងសងខាង ទាំងខាងភរិយា និងទាំងខាងស្វាមីបានមកជួយខ្វល់ខ្វាយនៅក្នុងពេលឆ្លងទន្លេនោះ ។ មនុស្សដែលបានមកចូលរួមជួយខ្វល់ខ្វាយនៅពេលនោះទាំងប៉ុន្មាន សុទ្ធតែមានទឹកមុខស្រងូតស្រងាត់ មានអារម្មណ៍ភ័យព្រួយខ្លាំងណាស់។ ចំណែកឯឪពុកវិញភ័យស្លន់ស្លោមុខស្លាំងអស់ ស្ទុះចុះឡើងបន្តិចទៅនេះបន្តិចទៅនោះអង្វរសុំឱ្យគេជួយស្រោចស្រង់ជីវិតប្រពន្ធ និងជីវិតកូនរបស់ខ្លួន ឱ្យបានរួចផុត ពីគ្រោះភយន្តរាយដ៏ធ្ងន់ធ្ងរនេះ ។ ឪពុកភិតភ័យជាងអ្នកណាៗទាំងអស់ ព្រោះគាត់ធ្លាប់បានឃើញស្ត្រីដទៃៗទៀតមានស្ត្រីខ្លះបានស្លាប់បាត់បង់ជីវិតនៅពេលឆ្លងទន្លេនេះ ។ ក្រៅពីនេះឪពុកមានការមមាញឹកក្នុងការងារទាំងឡាយ ក្នុងអំឡុងពេលដែលម៉ែកំពុងតែឆ្លងទន្លេនេះ ដូចជា ដាំទឹកក្តៅ ដាំបាយ និងចំអិនម្ហូបអាហារសម្រាប់ភ្ញៀវដែលមកក្នុងពេលនោះជាដើម។ បើនិយាយពីម៉ែវិញរឹងរឹតតែនិយាយលែងចេញទៅទៀត ម៉ែភិតភ័យខ្លាំងណាស់ ម៉ែស្រែកយំសូមឱ្យពេទ្យឆ្មប និងអ្នកណាក៏បានដែរ ឱ្យតែអាចជួយម៉ែបាន។ ម៉ែនឹកក្នុងចិត្តថា បើជីវិតកូនរបស់ម៉ែពិតជាថ្លៃថ្លៃមែននោះ សូមកូនកុំធ្វើឱ្យម៉ែលំបាក កុំធ្វើបាបម៉ែ ម៉ែឈឺណាស់ ម៉ែចុកចាប់ពេញសារពាង្គកាយអស់ហើយ សុំកូនជួយម៉ែផង ។នៅពេលនេះជីវិតរបស់ម៉ែងាយនឹងបាត់បង់ខ្លាំងណាស់ប្រៀបបាននឹងអំបោះតូចឆ្មារដែលងាយនឹងដាច់ ។ សរសៃតូចធំដែលមាននៅក្នុងសារពាង្គកាយរបស់ម៉ែទាំងប៉ុន្មាន ត្រូវរង្គោះរង្គើរញ្ជួយញ័រញាក់គ្មានសល់ត្រង់ណាមួយឡើយ។ ចំណែកឯញើសបានហូរស្រក់

ចេញពីខ្លួនប្រាណរបស់ម៉ែឥតស្រាកស្រាន្ត រួមជាមួយនឹងតំណក់នៃទឹកភ្នែករបស់ម៉ែ ដែលមិនអាចអត់ទ្រាំទៅនឹងការឈឺចុកចាប់បាន ដូច្នេះហើយក៏បានធ្វើឱ្យខ្លួនប្រាណរបស់ម៉ែជោគជាំទៅដោយគ្រាប់ញើសប៉ុន១៧គ្រាប់ពោត។ ពេលម៉ែកំពុងតែឆ្លងទន្លេនោះ ម៉ែឈឺចុកចាប់ហួសប្រមាណ ហួសនឹងពណ៌នា ព្រោះកូនដែលនឹងប្រសូតចាកផ្ទៃនៃមាតានោះ ប្រៀបបាននឹងអ្នកដទៃមកអារសាច់ស្រស់ៗរបស់ម៉ែឱ្យដាច់ចេញពីគ្នា ។

ញើសឈាមអ្នកម្ដាយ ហូរមិនរសាយ ជោគជាំពេញខ្លួន
តែគាត់ខំអត់ ឈឺចាប់ផ្ទួនៗ ដើម្បីកូនស្ងួន
បានឃើញរស្មី ។
អ្នកម្ដាយឈឺណាស់ ហៅរងកម្មក្រាស់ ស្ទើរបាត់ស្មារតី
តែដើម្បីកូន ទាំងប្រុសទាំងស្រី ទោះបីម៉ែក្ស័យ
ក៏សុខចិត្តដែរ ។
ម៉ែស្ទើរមរណា ព្រោះលោហិតា ហូរចេញឥតល្ហែ
ស្រោចស្រប់ខ្លួនប្រាណ រាងកាយនៃម៉ែ ពេលកូនទើបតែ

ប្រសូតមកភ្លាម ។

ដូច្នេះហើយបានជានៅពេលម៉ែឆ្លងទន្លេនេះ វិស័យនៃស្ដេចមច្ចុរាជបានមករង់ចាំយកជីវិតរបស់ម៉ែ គ្រប់ពេលវេលា គ្រប់វិនាទីទាំងអស់ ។ការប្រសូតបុត្រនេះមានគ្រោះថ្នាក់ខ្លាំងណាស់ មានម៉ែមិនតិចនាក់ទេ ដែលត្រូវស្លាប់នៅក្នុងពេលនោះ។ ជួនកាលបើជីវិតកូនថ្លៃ ស្លាប់តែម៉ែប៉ុណ្ណោះ ចំណែកឯកូនវិញនៅរស់រានមានជីវិតក៏មាន ឬ ត្រូវស្លាប់តែកូន ឯម៉ែវិញនៅរស់ក៏មាន។ ជួនកាលទៀតត្រូវស្លាប់ទាំងពីរនាក់ គឺទាំងម៉ែទាំងកូន ក្នុងពេលជាមួយគ្នាតែម្ដងក៏មាន ។ ព្រោះហេតុដូច្នេះហើយ ទើបបានជាចាស់បុរាណលោកប្រៀបប្រដូចការសម្រាលកូននេះទៅនឹងការឆ្លងទន្លេ ។ យើងដឹងហើយថា ការឆ្លងទន្លេនេះមានគ្រោះថ្នាក់ មានភយន្តរាយច្រើនយ៉ាងច្រើនប្រការណាស់ រហូតដល់បាត់បង់ជីវិតទៅក៏មាន។ ព្រោះផ្ទៃនៃទឹកមើលទៅមិនឃើញកោះត្រើយសោះឡើយ មានសភាពល្វាល្វេវធំល្វឹងល្វើយ មានខ្សែទឹកហូរខ្ជួលខ្វាញ់ មានខ្យល់ព្យុះបោកបក់ធ្វើឱ្យផ្ទៃទឹករលកបែកផ្កាត្រែងមើលអ្វីមិនយល់។ ម្យ៉ាងទៀត

នៅក្នុងទឹកនោះ មានក្រពើ ត្រីឆ្លាម និងសត្វកាចសាហាវជាច្រើនទៀត ដែលបម្រុងនឹងញ៉ាំញីស៊ីយកជីវិតរបស់អ្នកឆ្លងទន្លេនោះ ធ្វើជាចំណីអាហារ។ នៅពេលនោះជីដូនជីតា ម៉ែឪ ញាតិមិត្របានមកប្រជុំគ្នាឱ្យរបហង់ ម្នាក់ៗមានទឹកមុខស្រងូតស្រងាត់ក្រៀមក្រំដកដង្ហើមចេញផុតចូលផុតគ្រប់ៗគ្នា ។ ចំណែកឯ ឪពុកភ័យស្លន់ស្លោធ្វើអ្វី ក៏លែងកើតដែរ ចេះតែដើរចុះដើរឡើង ហើយនិយាយតែម្នាក់ឯងថា " ហេតុអ្វីបានជាយូរយ៉ាងនេះ ? " សូមវត្ថុសក្តិសិទ្ធិគុណបុណ្យបារមីជួយប្រពន្ធខ្ញុំ និងកូនរបស់ខ្ញុំឱ្យបានរួចផុតពីគ្រោះអន្តរាយផង ។ បន្តិចក្រោយមកស្រាប់តែឮសម្លេងកូនតូចយំខ្លាំងឡើង មនុស្សគ្រប់គ្នា ក៏ស្រាលខ្លួនស្រាលចិត្តស្រឡះ កាយហើយលាន់មាត់ស្រែកសួរថា " ម៉េចទៅហើយ ! បានកូនប្រុស ឬ កូនស្រី ? " រួចចុះកាត់ទៅរកម៉ែវា ឬ ក៏កាត់ទៅរកឪវា ? មនុស្សគ្រប់គ្នាបានឱ្យពរជ័យលាន់ឮរងំពេញផ្ទះ ដោយក្តីសប្បាយរីករាយហើយម្នាក់ៗបាននិយាយឡើងថា "ម្តងនេះផុតគ្រោះហើយយើង"។ ចំណែកឯឪពុកវិញក្រោយពេលបានឮសម្លេងកូនរបស់ខ្លួន

ដូច្នេះហើយ ក៏ញញឹមញញែមត្រេកអរសប្បាយរីករាយនៅក្នុងចិត្តហើយបាននិយាយប្រាប់គេឯងខ្លាំងៗថា ខ្ញុំមានកូនហើយ ៗ ដូច្នេះជាដើម ។ ម៉ែគ្រាន់តែបានស្តាប់ឮសម្លេងកូនរបស់ខ្លួនយំឡើងភ្លាមការឈឺចុកចាប់ទាំងប៉ុន្មានដែលធ្លាប់មានពីមុនមក ក៏ហាក់បីដូចជារលាយសាបសូន្យអស់រលីងទៅភ្លាមមួយរំពេច ពីក្នុងខ្លួនរបស់ម៉ែព្រោះសេចក្តីទុក្ខ សេចក្តីឈឺចុកចាប់ទាំងអស់នោះ ហាក់បីដូចជាខ្លបខ្លាចនូវអំណាចនៃទឹកចិត្តមេត្តាករុណារបស់ម៉ែ ដែលទោរទន់ទៅរកកូនណាស់ ។ ពេលនេះម៉ែលែងតឹងទ្រូងទៀតហើយ ទ្រូងម៉ែរសាយចិត្តរបស់ម៉ែក៏បានសប្បាយរីករាយដែរ ។ម៉ែខំប្រឹងប្រែងត្រងត្រាប់ស្តាប់សម្លេងដ៏តូចឆ្មាររបស់កូន ដែលកំពុងតែស្រែកយំឮសូរផុតៗ មិនឱ្យសម្លេងនោះសូម្បីតែបន្តិចបន្តួចរសាត់ផុតចាកត្រចៀករបស់ខ្លួនឡើយ។ នៅពេលនេះសម្លេងយំរបស់កូនហាក់បីដូចជាសម្លេងទិព្វ(ទិព្វសទ្ទ) ដែលមានអានុភាពខ្លាំងក្លា អាចផ្សះផ្សាទ្រូងរបស់ម៉ែ ឱ្យបានធូរស្បើយ មានអំណាចអាចផ្សាយទៅកាន់សរីរៈទាំងមូលរបស់ម៉ែបានយ៉ាងឆាប់រហ័ស ។ តាំងតែពីម៉ែកើត

មក ម៉ែមិនដែលធ្លាប់បានឮបានស្ដាប់នូវសម្លេងណាដែលពីរោះស្មើនឹងសម្លេងកូននៅពេលនេះឡើយ ព្រោះម៉ែមិនដែលធ្លាប់មានកូនមកពីមុន ។ ពេលនេះទឹកមុខរបស់ម៉ែ ដែលធ្លាប់តែស្រពាប់ស្រពោននោះ ក៏បានប្រែក្លាយទៅជាស្រស់បស់ឡើងវិញ។ ម៉ែបានឆ្លងរួចផុតពីគ្រោះថ្នាក់ម្ដងនេះចាត់ទុកថា ជាសំណាងដ៏ធំធេងខ្លាំងណាស់របស់ម៉ែ ។ ឥឡូវនេះ ការឆ្លងទន្លេបានចប់សព្វគ្រប់រួចរាល់អស់ហើយ ប៉ុន្តែម៉ែត្រូវទទួលរ៉ាប់រងធ្វើភារកិច្ចមួយទៀត ដែលមនុស្សទាំងឡាយមិនអាចជួយធ្វើជំនួសម៉ែបាន ពោលគឺការអាំងភ្លើង។ រងើកភ្លើងដែលម៉ែកំពុងតែអាំងនេះ បានបញ្ចេញចំហាយដុតកំដៅខ្លួនប្រាណរបស់ម៉ែពីខាងក្រៅ ធ្វើឱ្យក្ដៅក្រហល់ក្រហាយពើតផ្សាស្ទើរតែមិនអាចទ្រាំទ្របានទៅហើយ ។មិនត្រឹមតែប៉ុណ្ណោះទេ សូម្បីតែម្ហូបអាហារដែលម៉ែទទួលទានទៅនោះ ក៏គេតម្រូវឱ្យម៉ែទទួលទានតែម្ហូបណាដែលមានជាតិហឹរ ជាតិក្ដៅ ដូចជាម្ហូបអាហារដែលផ្សំដោយម្រេច ម្ទេស ខ្ញី និងមើមខ្ទឹមជាដើម ហើយសុទ្ធសឹងតែជាធាតុក្ដៅយកមកដាំឱ្យម៉ែទទួលទានដើម្បីជំនួយដល់ការរំលាយឈាមរបស់ម៉ែទៀតផង ។ ក្នុងមួយរយៈកាលនេះ ម៉ែមានទុក្ខលំបាកខ្លាំងណាស់ ធាតុក្ដៅទាំងឡាយដែលម៉ែទទួលទានទៅហើយបានភាយចេញមកពីក្នុងខ្លួនរបស់ម៉ែជារឿយៗគ្រប់ពេលមកប៉ះផ្ទប់គ្នាទៅនឹងកំដៅនៃរងើកភ្លើងខាងក្រៅដែលម៉ែកំពុងតែសម្រាកអាំងសំដិលនោះ បានធ្វើឱ្យម៉ែស្ទើរតែស្លឈាមស្ទះដង្ហើមរកខ្យល់ម្ដងៗទៅហើយ ។ប៉ុន្តែដោយអំណាចនៃទឹកចិត្តព្រហ្មវិហារធម៌របស់ម៉ែ ដែលហូរទន់ទោរទៅរកកូនគ្មានថ្ងៃដែលត្រឡប់ថយក្រោយវិញនោះ ក៏បានជំរុញឱ្យម៉ែ តស៊ូអត់ទ្រាំបាន រហូតដល់ទីបំផុត ។

ចំណែកឯឪពុកវិញ ក្រោយពេលដែលម៉ែឆ្លងទន្លេរួចមក ក៏ចាប់ផ្ដើមធ្វើការងារគ្រប់មុខដោយមិនប្រកាន់ថា ការងារនេះជាការងាររបស់មនុស្សប្រុស ឬ ជាការងាររបស់មនុស្សស្រីនោះទេ គឺគាត់ធ្វើបានទាំងអស់។ ឪពុកភ្ញាក់ពីសម្រាន្តតាំងពីព្រលឹម ហើយស្ទុះស្ទារៀបចំបោសសំអាតផ្ទះសំបែង ហើយនិងបរិវេណជុំវិញទាំងខាងមុខទាំងខាងក្រោយ ឱ្យបានស្អាតល្អ គួរជាទីមនោរម្យនៃអ្នក

ផងទាំងឡាយ ដែលបានមកសួរសុខទុក្ខភរិយារបស់ខ្លួននោះឯង ។ ការងារទាំងឡាយណាដែលបុរសគ្រប់រូបតែងតែគិតថា ជាការងារសម្រាប់ស្ត្រីតែម្យ៉ាង ជាការងារគួរខ្មាសអៀន ជាការងារដែលបុរសធ្វើទៅហើយ នាំឱ្យគេសើចចំអក នាំឱ្យកិត្តិយសអន់ថយជាដើម ។ ពេលនេះ គាត់មិនគិតដូច្នោះទៀតទេ គាត់ធ្វើបានគ្រប់ការងារទាំងអស់ ។គាត់ធ្វើការងារបោកគក់សំពត់ខោអាវសារ៉ែស្បៃ កន្ទេល ភួយ មុង កន្ទប ជាវត្ថុគួរខ្ពើមរអើមយ៉ាងក្រៃលែងជាទីបំផុត ដែលមនុស្សដទៃមិនអាចធ្វើបាន តែសម្រាប់ឪពុកវិញគាត់ធ្វើបានយ៉ាងងាយ ធ្វើបានទាំងដែលសប្បាយចិត្តទៀតផង។ ពេលថ្ងៃបន្តិចគាត់ត្រូវទៅផ្សារដើម្បីរកទិញ នំ ចំណី ត្រីសាច់ បន្លែបង្ការផ្សេងៗ ទុកសម្រាប់ចំអិនធ្វើជាម្ហូបអាហារ ដើម្បីតម្រូវតាមសុខភាពរបស់ម៉ែ។ សូម្បីតែពេលដែលគាត់ទៅផ្សារនោះតម្រូវឱ្យគាត់ទិញបន្លែទិញត្រីសាច់តម្រូវឱ្យគាត់យួរកាន់របស់ទាំងអស់នោះឆ្លងកាត់តាមទីផ្សារ ធ្វើឱ្យអ្នកផងទាំងឡាយតាមមើលគាត់មិនដាច់កន្ទុយភ្នែកយ៉ាងណាក៏ដោយ ប៉ុន្តែគាត់លែងអៀនលែងខ្មាសអស់ហើយ ។ លុះពេលត្រឡប់មកដល់ផ្ទះវិញកាលណា គាត់រូតរះធ្វើម្ហូបអាហារសម្រាប់ប៉ូវសុខភាពភរិយារបស់ខ្លួន ដែលកំពុងតែអាំងភ្លើងនោះ។ គាត់ត្រូវដាំទឹកថ្នាំទុកសម្រាប់ឱ្យម៉ែពិសាទៀតផង ។ គាត់ត្រូវមើលថែភ្លើងចង្ក្រានដែលម៉ែកំពុងតែអាំងនោះ ដោយមិនឱ្យភ្លើងឆេះខ្លាំងពេកខ្លាចម៉ែក្តៅទ្រាំមិនបាន ឱ្យឆេះត្រឹមតែល្មមៗប៉ុណ្ណោះ ហើយគាត់ត្រូវមើលថែទាំកូនដែលនៅលើអង្រឹង ត្រូវយោលកុំឱ្យកូនយំ ព្រោះខ្លាចរំខានដល់ដំណេកម៉ែ។ គាត់អាណិតអាសូរម៉ែខ្លាំងណាស់ គាត់ចង់ជួយម៉ែជាទីបំផុត តែនឹងត្រូវធ្វើដូចម្តេចសម្រាប់គាត់ជាមនុស្សប្រុស គាត់មិនអាចធ្វើការងារទាំងអស់នេះបាន (ពផ្ទៃ ឆ្លងទន្លេ អាំងភ្លើង...) ដូច្នេះគាត់មានតែខំប្រឹងធ្វើការងារណាដែលគាត់អាចជួយធ្វើបានតែប៉ុណ្ណោះ។ គាត់ធ្វើការងាររាល់ថ្ងៃនេះ ទោះបីជាគាត់នឿយហត់យ៉ាងណាក្តី គាត់នៅតែញញឹមជានិច្ច ដើម្បីលើកទឹកចិត្តប្រពន្ធរបស់គាត់ ឱ្យបានសប្បាយចិត្តនឹងបានឆាប់មានកម្លាំងឡើងវិញ។ ម្យ៉ាងទៀតដោយអំណាចនៃទឹកចិត្តអាណិតស្រឡាញ់រាប់អានរបស់ឪពុក ដែលមានចំពោះ

ភរិយារបស់គាត់ និងមានចំពោះកូនរបស់គាត់ផង ទើបបានជាបណ្ដាលចិត្តរបស់គាត់ឱ្យធ្វើការងារមិនចេះហត់នឿយដូច្នេះ ។ ជារៀងរាល់ថ្ងៃ ឪពុកប្រកបកិច្ចការងារទោះបីនៅជិតផ្ទះក្ដីនៅឆ្ងាយផ្ទះក្ដី ប៉ុន្តែចិត្តរបស់គាត់នៅតែនឹកគិតមករកផ្ទះជានិច្ច គាត់គិតដល់កូន និងប្រពន្ធរបស់គាត់ដែលនៅឯផ្ទះ គាត់មិនចង់ឃ្លាតឆ្ងាយសូម្បីតែមួយវិនាទីនោះឡើយ ។ ប៉ុន្តែធ្វើដូចម្ដេច បើជីវភាពរបស់គាត់មានភាពក្សត់ខ្សោយ ដូច្នេះហើយ ទើបបានជាគាត់បង្ខំចិត្តចេញទៅប្រកបការងារដើម្បីយកកម្រៃមកផ្គត់ផ្គង់គ្រួសារ ។ លុះដល់ពេលល្ងាចកាលណា គាត់ក៏រូតរះរលះរលាំងវិលត្រឡប់មកផ្ទះវិញមានទាំងនំ ចំណីផ្លែឈើខ្លះៗ ទុកសម្រាប់ផ្ញើភរិយា ដែលនៅឯផ្ទះផងដែរ ។ មកដល់ផ្ទះគាត់រៀបចំនំចំណីផ្លែឈើនោះឱ្យប្រពន្ធរបស់គាត់ពិសា ទាំងពីរនាក់បានបង្ខំគ្នាឱ្យពិសាទៅវិញទៅមក ។ ឪពុកនិយាយថា " ម៉ែវាឯងហូបចុះ ព្រោះម៉ែវាឯងល្ហិតល្ហៃខ្លាំងណាស់នឹងឱ្យឆាប់មានកម្លាំងពលំ មានសាច់មានឈាមឡើងវិញបានមើលថែរក្សាកូនរបស់យើង"។ ចំណែកឯម៉ែវិញក៏បាននិយាយ

ថា " ឪវាឯងហូបខ្លួនឯងចុះ ព្រោះមួយរយៈកាលកន្លងមកនេះ ឪវាឯងហត់នឿយខ្លាំងណាស់ ធ្វើការងារទាំងយប់ទាំងថ្ងៃ សម្រាន្តក៏មិនបានគ្រប់គ្រាន់ ហើយទទួលទានរបស់អ្វីៗក៏មិនបានពេញមាត់ពេញ ក ទៀត ។ ឱហ្ន៎ ! គួរឱ្យអាសូរពេកណាស់ គិតទៅទឹកចិត្តរបស់មាតាបិតាគ្រប់រូបគឺយ៉ាងនេះឯង ។ សម្រាប់ខ្ញុំ អ្នកសរសេររៀបរៀងសៀវភៅនេះឡើងមកដល់ត្រង់ចំនុចនេះ ខ្ញុំក្ដុកក្ដួលខ្លាំងណាស់ ខ្ញុំស្ទើរតែមិនអាចចាប់ដងប៉ាក់កាសរសេរបន្តទៅមុខទៀតកើត ព្រោះដៃរបស់ខ្ញុំទាំងសងខាង ហាក់បីដូចជាទន់ល្វន់ល្វើយអស់ទៅហើយ ។ ខ្ញុំគិតថា សម្រាប់រូបខ្ញុំផ្ទាល់ ខ្ញុំមិនដែលធ្លាប់បានឆ្លងកាត់រឿងរ៉ាវទាំងអស់នេះឡើយ ដូច្នេះហើយខ្ញុំមិនអាចដើម្បីនឹងសរសេរពណ៌នារៀបរាប់ ឱ្យត្រឹមត្រូវទៅតាមជម្រៅនៃទឹកចិត្តរបស់លោកអ្នកដ៏មានគុណទាំងពីរអស់បានដែរ ។

សូមអ្នកអានទាំងឡាយ ! មេត្តាដាក់សៀវភៅចុះបន្តិចសិន សូមយកកន្សែងជូតទឹកភ្នែកឱ្យបានស្អាត ដកដង្ហើមមួយៗវែងៗ ហើយសូមតាំងចិត្តបង្អោនទៅរកមាតាបិតារបស់យើងឱ្យ

បានគ្រប់ៗគ្នា សូមគិតថា តើឥឡូវនេះពួកគាត់ទាំងពីរនាក់ទៅជាយ៉ាងណាហើយ ? ស្លាប់ ឬក៏ មានជីវិតនៅរស់មកដល់សព្វថ្ងៃនេះដែរ ។ សូមឱ្យអ្នកអានទាំងឡាយបិទភ្នែកតាំងចិត្តនឹកស្រមៃគិតដល់អតីតកាល គឺពេលដែលយើងទើបតែកើតមកបានអាយុ ៧ថ្ងៃ តើមាតាបិតារបស់យើងគាត់ធ្វើការងារអ្វីខ្លះ ? មនុស្សយើងគ្រប់គ្នា ដែលមានជីវិតមកដល់សព្វថ្ងៃនេះ មានខ្យល់ដង្ហើមចេញចូលមកដល់សព្វថ្ងៃនេះ ដែលមាននូវឱកាសកំពុងតែផ្ទាត់នូវទំព័រនៃសៀវភៅអាននាពេលនេះ ក៏អាស្រ័យមកអំពីមានមាតាបិតា ជាអ្នករួមគ្នាបង្កើតយើងដែលជាកូនមក ហើយព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សាយើងផងដែរ ។ បើសិនជាយើងប្រាសចាក( មិនមាន) នូវមាតានិងបិតាហើយ តើយើងនឹងអាចមានជីវិតរស់នៅរហូតមកដល់សព្វថ្ងៃនេះមកអំពីណាបាន ? តើមានព្រះអាទិទេពណាដែលមានចិត្តល្អប្រគល់អាយុជីវិតឱ្យយើងបានរស់នៅ បង្កើតរូបកាយយើងមកក្រៅតែអំពីព្រះគឺមាតាបិតារបស់យើងនោះ ? នៅក្នុងលោកនេះ គ្មានព្រះអាទិទេពណាដែលជាអ្នកបង្កើតមនុស្សលោកនោះទេ ផ្ទុយទៅវិញមានតែមនុស្សលោកទេ ទើបពិតជាអ្នកបង្កើតនូវព្រះអាទិទេពតែម្យ៉ាង។ កាលណាបើមនុស្សលោកមានជំនឿទៅលើអ្វីមួយទៅលើបុគ្គលណាម្នាក់ហើយនោះ គេតែងនាំគ្នាគោរពសន្មតលើកតម្កើងវត្ថុនោះបុគ្គលនោះថា ជាព្រះអាទិទេព ជាអ្នកបង្កើតនូវមនុស្សលោក ត្រង់ចំនុចនេះឯងហើយ ដែលមនុស្សលោកទើបពិតជាអ្នកបង្កើបនូវព្រះអាទិទេព ឬថា ព្រះអាទិទេពពិតជាបានកើតឡើងដោយសារតែមនុស្សលោកតែម្យ៉ាងប៉ុណ្ណោះ។ អ្នកខ្លះមានជីវិតរស់នៅរហូតមកទល់គ្នានឹងថ្ងៃនេះមែន ប៉ុន្តែសំណាងមិនល្អត្រូវមាតាបិតាស្លាប់បាត់បង់ជីវិតទៅចោលមានឈ្មោះថា ជាកូនកំព្រា រកម៉ែឪហៅនឹងគេគ្មាន ។ អ្នកខ្លះទៀតសំណាងយ៉ាងក្រៃលែង អាយុប៉ុណ្ណោះហើយ តែនៅមានមាតាបិតារស់នៅជួបជុំគ្នា បានស្រែកហៅរកពួកគាត់ពេញៗមាត់ គិតទៅគួរឱ្យសរសើរនូវលាភសំណាង បុណ្យកុសលរបស់ពួកគេពេកណាស់ ។

ក្រោយពេលឆ្លងទន្លេរួចមក ម្ដាយឪពុកទាំងពីរនាក់បានរួមគ្នាចិញ្ចឹមថ្នាក់ថ្នមបំពេរបីបមកូនឱ្យកូនបានសុខបានសប្បាយតទៅ

ទៀត ។ កូនដែលរស់នៅក្រោមម្លប់នៃសង្គហធម៌របស់មាតាបិតា ក៏ចេះតែបានសុខបានសប្បាយវិវឌ្ឍន៍ធំធាត់បន្តិចម្តងៗ ជាដរាប ។ មាតាបិតាដែលគាត់ចិញ្ចឹមកូន គឺប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត រួមគ្នាចិញ្ចឹមកូនដោយស្នេហ៍ក្រស្នោះអស់ពីដួងចិត្ត ក្រៃលែងជាងអ្នកបម្រើទៅទៀត។ ទឹកដោះដែលកូនកំពុងតែបៅបឺតជញ្ជក់នោះ គឺជាឈាមរបស់ម៉ែពិតៗ បានមកអំពីឈាមរបស់ម៉ែពិតៗ តែដោយអំណាចនៃទឹកចិត្តមេត្តាធម៌របស់ម៉ែ ដែលមានចំពោះកូននោះ ជាទឹកចិត្តដ៏បរិសុទ្ធថ្លៃថ្លាគ្មានពីរ ទើបបានជាបណ្តាលឱ្យឈាមរបស់ម៉ែដែលមានពណ៌ក្រហម បានក្លាយទៅជាទឹកដោះមានពណ៌សទៅវិញ ។ ព្រោះហេតុដូច្នេះហើយ បានជានៅថ្ងៃខ្លះកូនបៅជញ្ជក់ទឹកដោះពីទ្រូងរបស់ម៉ែច្រើនហួសប្រមាណពេកទៅ ម៉ែក៏ហាក់ដូចជារីងស្ងួតខ្សោះអស់ឈាមពីខ្លួន មានកាយល្ហិតល្ហៃ ធីងធោងរិលមុខជាដើម ។ ប៉ុន្តែកូនដែលបានបៅជញ្ជក់ក្រេបយកឱជារសនៃទឹកដោះម្តាយនោះ មិនបានដឹងថា ខ្លួនធ្វើបាបម្តាយយ៉ាងណានោះទេ ដូច្នេះហើយក៏ចេះតែខំបៅជញ្ជក់ទៅ ព្រោះទឹកដោះម្តាយនោះឯងជាអាហារដ៏បរិសុទ្ធ ជាអាហារធម្មជាតិ ជាអាហារទិព្វ ដែលប្រោសព្រំជីវិតរបស់កូនឱ្យបានរស់ ។ ម៉ែទោះបីជាគាត់បានដឹងខ្លួនប្រាកដថា កាលបើកូនបៅជញ្ជក់ទឹកដោះរបស់ខ្លួនច្រើនពេកទៅនឹងធ្វើឱ្យខ្លួនហត់ហេវអស់កម្លាំងយ៉ាងណាក៏ដោយ ក៏ម៉ែនៅតែពេញចិត្តឱ្យកូនបៅជញ្ជក់ជានិច្ច ម៉ែមិនដែលស្អប់កូនឡើយ ។ សូម្បីតែកូនបន្ទោបង់នូវមូត្រលាមកដាក់លើខ្លួនប្រាណរបស់ម៉ែ កូនយកដៃនិងជើងរបស់កូនទាំងពីរ មកប្រហាររូបរាងកាយ ខ្លួនប្រាណរបស់ម៉ែយ៉ាងណាក៏ដោយ ក៏ម៉ែនៅតែមិនខឹង មិនស្អប់នឹងកូនដែរ ថែមទាំងកូន បានជាទីស្រឡាញ់ពេញចិត្តយ៉ាងក្រៃលែងរបស់ម៉ែទៀតផង។

សូម្បីកូនដែលកើតមកនោះ មានរូបរាងមិនល្អមិនស្អាតខ្មៅក្រញេះក្រញាស់ ជួនកាលកូននោះ គ ថ្លង់ ខ្វាក់ខ្វិន វង្វេងវង្វាន់យ៉ាងណាក៏ដោយ ក៏ម៉ែឪនៅតែចិញ្ចឹមកូនជានិច្ច ។ ពេលកូនយំម្តងៗ ម៉ែឪលំបាកចិត្តស្អិតទ្រូងខ្លាំងណាស់ ព្រោះគាត់មិនបានដឹងថា ហេតុអ្វីបានជាកូនរបស់គាត់ចេះតែយំ ? កូនឈឺត្រង់ណា កូន

ចង់បានរបស់អ្វី កូនស្អប់របស់អ្វី ក៏ម៉ែមិនដឹង ព្រោះកូននៅមិនទាន់ចេះនិយាយនៅឡើយ។ ពេលឮសម្លេងកូនស្រែកយំម្ដងៗ ម៉ែឪភ័យខ្លាំងណាស់ ស្ទុះរត់ទៅលើកបីពឱបថើបថ្នាក់ថ្នមមើលនាយមើលអាយក្រែងមានសត្វល្អិតវាខាំវាទិចកូន។

ឱកូនមាសស្ងួនអ្នកម្ដាយអើយ យប់ជ្រៅណាស់ហើយកូនគេងទៅ
គេងឱ្យបានលក់ណាកូនពៅ កុំបីឆោមឆ្លៅនៅយំទៀត ។
ព្រោះពេលម៉ែឪឃើញកូនយំ ទ្រូងសែនរណ្ដំណែនចង្អៀត
ស្ទុះស្ទាម្ទីម្ទាដោយខ្វីឃ្វាត ព្រោះចិត្តមិនឃ្លាតពីកូនជាក់ ។
ម៉ែឪសប្បាយឃើញកូនគេង គាត់គិតខ្លាចក្រែងតែកូនភ្ញាក់
ទឹកចិត្តម៉ែឪមិនមានទាក់ ហូរត្រង់ទម្លាក់មករកកូន ។

ពេលខ្លះទៀតម៉ែឃើញសត្វល្អិតតូចៗដូចជាសង្អារស្រមោចជាដើមវារលើខ្លួនរបស់កូន ឬ គ្រាន់តែនៅក្បែខ្លួនរបស់កូនក៏ដោយ ក៏ម៉ែនៅតែតាមញីចតាមសម្លាប់វាដែរ ព្រោះម៉ែខ្លាចវាខាំវាទិចធ្វើបាបកូនរបស់ម៉ែ ។ ដើម្បីឱ្យកូនបានគេងលក់បានសប្បាយចិត្ត ម៉ែលួងលោមកូនដោយពាក្យសម្ដីពីរោះ ផ្អែមល្ហែម ម៉ែច្រៀងបំពេកូនលាន់ឮរំពងដល់ផ្ទះមួយផ្ទះពីរ ក៏ម៉ែមិនខ្មាសគេដែរ ឱ្យតែធ្វើឱ្យកូនបានសុខបានសប្បាយ ។ កាលពីមុនម៉ែមិនទាន់មានកូន ម៉ែស្រឡាញ់ខ្លួនប្រាណម៉ែណាស់ ម៉ែសំអាតខ្លួនប្រាណរបស់ម៉ែជានិច្ច ម៉ែប្រយ័ត្នខ្លាំងណាស់ ខ្លាចក្រែងខ្លួនប្រាណរបស់ម៉ែប្រលាក់ដោយគ្រឿងមន្ទិលសៅហ្មងរបស់ស្មោកគ្រោកដូចជាមូត្រ លាមក កំអួតនិងទឹកសំបោរជាដើម។ ដោយអំណាចនៃក្ដីមេត្តាករុណា ចំពោះរូបកូនខ្លាំងពេក ពេលខ្លះម៉ែលែងមានការខ្មាសអៀនអស់ហើយ ទោះបីជានៅកណ្ដាលជំនុំចំណោម ហ្វូងនៃមនុស្សជាច្រើននាក់ ក៏ដោយឱ្យតែកូនយំឃ្លានទារកបៅ ម៉ែអនុញ្ញាតឱ្យកូនបៅបឺតជញ្ជក់បានគ្រប់ពេលគ្រប់ទីកន្លែងទាំងអស់ ។ ពេលកូនឈឺម្ដងៗ ម៉ែឪភ័យមុខស្លាំងអស់ ទឹកមុខស្រងូតស្រងាត់ទឹកភ្នែករលីងរលោង មិនដឹងថា នឹងត្រូវធ្វើយ៉ាងណា ដើម្បីឱ្យកូនបានស្រាកស្រាន្តជាសះស្បើយឡើងវិញ ។ កូនឈឺកាន់តែយូរថ្ងៃ ម៉ែឪរឹងរឹតតែស្គមខ្លាំងឡើងៗ ព្រោះមិនបានសម្រាន្តទាល់តែសោះ បរិភោគបាយម្ដងៗ ក៏លេប

មិនចូលពោះដែរ  កាលណាបើនឹកឃើញដល់កូន។ ម៉ែឪព្យាយាមស្វះស្វែង រកថ្នាំពេទ្យ ថ្នាំសង្កូវមកព្យាបាលកូន ដោយការយកចិត្តទុកដាក់ជាទីបំផុត។ ក្រៅអំពីការព្យាបាលទាំងអស់នេះ ម៉ែឪបានអុជធូបបន់ស្រន់ព្រះសំពះវន្ទានឹករលឹកគុណបុណ្យបារមី  គុណព្រះពុទ្ធ គុណព្រះធម៌ គុណព្រះសង្ឃ បួងសួងបន់ស្រន់វត្ថុស័ក្តិសិទ្ធិនៅក្នុងលោកនេះ ជីដូនជីតាមេបាខាងប្រុសមេបាខាងស្រី សូមឱ្យជួយកូនឱ្យបានឆាប់ជាសះស្បើយឡើងវិញ។ ម៉ែឪចិញ្ចឹមបីបាច់ថែរក្សាថ្នាក់ថ្នមបំពេបីបមកូន  ចង់ឱ្យតែកូនបានសុខបានសប្បាយ  ទោះបីជាខ្លួនពួកគាត់ក្រខ្សត់អត់ឃ្លាន  តោកយ៉ាកលំបាកវេទនាយ៉ាងណាក៏ដោយចុះ។ សម័យខ្លះកូនបានកើតមកត្រូវចំស្រុកកើតទុរ្ភិក្សកើតសង្គ្រាមចំបាំងរាំងជល ទោះបីជាម៉ែឪក្រីក្រ កំសត់ អត់ឃ្លានយ៉ាងណាក៏ដោយ   មានបាយតែមួយម៉ាត់សុខចិត្តផ្តាច់ពីមាត់ពង្រាត់ពីកឱ្យកូនដើម្បីឱ្យកូនបានរស់។ ម៉ែឪបីពទ្រកូនរត់ឆ្លងកាត់គ្រាប់  និងសមរភូមិទាំងទឹកភ្នែកស្រក់ឱ្យរហាមលើទ្រូងរបស់កូន   ក៏មិនសុខចិត្តរត់ចោលកូនដែរ សុខចិត្តថា ទោះបីជាត្រូវស្លាប់ក៏ដោយចុះ ក៏ព្រមស្លាប់ជាមួយនឹងកូនដែរ។ រឿងទាំងអស់នេះហើយ ដែលចង់បញ្ជាក់ថា  នេះឯងគឺជាទឹកចិត្តរបស់មាតាបិតាគ្រប់រូប  ។

ពីមួយថ្ងៃទៅមួយថ្ងៃ រូបកាយរបស់កូន ក៏ចេះតែចម្រើនធំធាត់ឡើងជាលំដាប់ កូនចេះក្រឡាប់ ចេះសើច ចេះវារ ចេះអង្គុយ ចេះឈរ  និងចេះដើរតិះតះជាដើម  ។ ម៉ែសប្បាយចិត្តខ្លាំងណាស់ ម៉ែបង្រៀនកូនឱ្យចេះនិយាយពាក្យថា  ម៉ាក់ប៉ា  ម៉ែពុក  យាយតាជាដើម  ។ ម៉ែបង្រៀនកូនឱ្យចេះដើរ បង្រៀនកូនឱ្យចេះគោរពតាយាយជាដើម  ពេលកូនចេះមួយមុខ  ៗ  ម៉ែសប្បាយចិត្តម្តង  ម៉ែអួតប្រាប់គេម្តង។ ម៉ែឧស្សាហ៍ដឹកដៃកូនដើរលេង ម៉ែដេញបង្អើលចាបឱ្យកូនមើលជាដើម  ។ ម៉ែនាំកូនទៅស្រែនិងចំការក្នុងគោលបំណងមួយដែលគិតថា ចង់ឱ្យកូនរៀនដឹងអ្វីៗ ដែលនៅជិតជុំវិញខ្លួនឱ្យហើយ  ម្យ៉ាងវិញទៀត ដើម្បីធ្វើឱ្យរូបកូនបានសប្បាយចិត្តផង។ ម៉ែឪទៅធ្វើការនៅឯវាលស្រែនិងចំការ   ក៏បានផ្ញើកូននឹងជីដូននៅផ្ទះឱ្យមើលថែជំនួសខ្លួន។ ម៉ែឪទៅធ្វើការងារនៅឯស្រែចំការឆ្ងាយពីផ្ទះក៏ពិតមែន   ប៉ុន្តែចិត្តរបស់ពួកគាត់នៅនឹកមមៃស្រមៃមកកូន

ជានិច្ច ទោះបីជាគាត់ធ្វើការងារហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់ នៅឯវាលស្រែ មានការហត់នឿយយ៉ាងណាក៏ដោយ ក៏ម៉ែឪមិនដែលត្អូញត្អែរដែរ ។ លុះពេលមកដល់ផ្ទះវិញ ម៉ែឪគ្រាន់តែឃើញមុខកូនរត់មកទទួលចាប់ដៃចាប់ជើងប៉ុណ្ណឹងជាដើម សូម្បីគាត់ធ្វើការនឿយហត់អស់កម្លាំងយ៉ាងណាក៏ដោយ ម៉ែឪក៏បាត់អស់នូវការនឿយហត់ទៅហើយ ។ ពេលបាយល្ងាច ម៉ែឪបានម្ហូបត្រីសាច់បន្តិចបន្តួចក៏ដោយ បានកិនបេះយកទៅបញ្ចុកកូន ពេលឃើញកូនញ៉ាំបានច្រើន ម៉ែឪក៏រឹងរឹតតែសប្បាយខ្លាំងឡើង ។ ក្រោយពេលបាយល្ងាចរួចហើយ គាត់ទាំងពីរនាក់ក៏បានចងមុងរៀបចំកន្លែងសម្រាប់ឱ្យកូនគេង រួចហើយគាត់ក៏បានផ្ដេកខ្លួនទៅលើកន្ទេលថើបថ្ពាល់កូនដោយច្រមុះរបស់គាត់ប្រលែងលេងនឹងកូន ទាល់តែកូនងងុយគេង ។ មាតាបិតាទោះបីជាខ្លួនឯងអត់ងងុយយ៉ាងណាក៏ដោយ ក៏មិនព្រមសម្រាកសម្រាន្តដែរ នៅចាំបក់មូសមើលថែពិនិត្យកូនរហូតទាល់តែកូនគេងលក់ ទើបបានពួកគាត់សម្រាន្តតាមក្រោយ ។ ជារៀងរាល់ថ្ងៃ មាតាបិតាបានបង្រៀនកូនឱ្យចេះសំពះចាស់ទុំ

បង្រៀនកូនឱ្យស្គាល់របស់គ្រប់យ៉ាងដែលនៅក្នុងលោកយើងនេះ ។ មាតាបិតាឧស្សាហ៍នាំកូនទៅសាលារៀន ទៅលេងវត្តអារាមពេលមានបុណ្យទានជាដើម ។ កូនធំបន្តិច កូនចេះចាយលុយ ចាយកាក់ ពេលឃើញគេលក់របស់នេះរបស់នោះ នំនេះ នំនោះ កូនយំទាររកចង់បាន ចង់ញ៉ាំ ចង់លេងជាដើម ។មាតាបិតាជាធនាគារបើកប្រាក់ឱ្យកូនជារៀងរាល់ថ្ងៃ ទោះបីតិចក្ដីច្រើនក្ដីមិនដែលឱ្យអាក់ខានម្ដងណាទេ តែងតែបើកឱ្យជាប្រចាំ។ មាតាបិតាប្រឹងប្រែងធ្វើការងារជារៀងរាល់ថ្ងៃនេះ មិនមែនដើម្បីនរណាក្រៅតែអំពីកូនរបស់ខ្លួននោះឡើយ គឺដើម្បីតែកូនជាទីស្រឡាញ់ជាទីហួងហែងរបស់ខ្លួនតែប៉ុណ្ណោះបើសម្រាប់ខ្លួនគាត់ទាំងពីរនាក់នោះ មានតែពីរនាក់ប៉ុណ្ណឹងមាតាបិតាមិនព្រមទ្រាំលំបាកដល់ថ្នាក់នេះទេ ។ ប៉ុន្តែគាត់ខំហត់នឿយខំលំបាកសព្វថ្ងៃនេះ គឺដើម្បីតែកូន ព្រោះគាត់ខ្លាចទៅថ្ងៃក្រោយថ្ងៃមុខទៅ ក្រែងកូនលំបាកក្រខ្សត់អត់ឃ្លានជាដើម ។ សូមកូនប្រុសស្រីទាំងឡាយមើលចុះ ! មាតាបិតាបានបំពេញនូវមហា-ពលិកម្មដ៏ធំធេងនេះ ដើម្បីកូនសព្វគ្រប់បែបយ៉ាងទាំងអស់ ។ ពេល

ខ្លះពួកគាត់ត្រូវទៅរកស៊ីនៅស្រុកឆ្ងាយ ៗ យកជីវិតរបស់ខ្លួនទៅប្រថុយនឹងគ្រោះថ្នាក់សព្វបែបយ៉ាង។ ពេលខ្លះទៀត គាត់ត្រូវទៅរកស៊ីឆ្លងរហូតទៅដល់ខេត្តមួយខេត្តពីរ ឬ ឆ្លងទៅរកស៊ីនៅប្រទេសក្រៅជាដើម ត្រូវធ្វើដំណើរតាមផ្លូវទឹក តាមទន្លេគង្គា តាមឈូងសមុទ្រនានាជាដើម ដោយការជិះទូក ជិះកប៉ាល់ មួយថ្ងៃៗនៅតែកណ្ដាលសមុទ្រមិនដឹងកោះត្រើយនៅឯណា ក៏គាត់សុខចិត្តយកជីវិតទៅប្រថុយប្រថាននឹងគ្រោះថ្នាក់ទាំងអស់នេះដែរ ដើម្បីបានលុយបានប្រាក់មកចិញ្ចឹមកូន ឱ្យតែកូនបានសុខបានសប្បាយមាតាបិតាប្រថុយទាំងអស់។ មាតាបិតាខ្លះទៀតបានទៅរកស៊ីនៅតាមផ្លូវព្រៃព្រឹក្សាជ្រោះជ្រង ជ្រលងដងភ្នំនានា សូម្បីខ្លួនឯងបានដឹងប្រាកដហើយក៏ដោយថា នៅតាមព្រៃភ្នំនៅតាមទីនោះៗសម្បូរទៅដោយសត្វកាចសាហាវជាច្រើន មានដូចជា សត្វខ្លា ដំរី ពស់វែ្កប ខ្លួយ ជាដើម មិនតែប៉ុណ្ណឹងទេ នៅមានជំងឺផ្សេងៗគួរឱ្យខ្លាចដូចជា ជំងឺគ្រុនចាញ់ គ្រុនឈាមជាដើម ក៏គាត់នៅតែយកជីវិតទៅប្រថុយនឹងគ្រោះថ្នាក់ ឧបសគ្គភយន្តរាយ គ្រប់បែបយ៉ាងទាំងអស់

នេះដែរ។ សូម្បីតែគាត់ដឹងថាជំងឺទាំងអស់នេះអាចបណ្ដាលឱ្យគាត់ស្លាប់បាត់បង់ជីវិតបានយ៉ាងណាក៏ដោយ ក៏គាត់នៅតែយកជីវិតរបស់គាត់ទៅប្រថុយដែរ ដើម្បីការចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានរស់រានមានជីវិត ។ ប៉ុន្តែមានមាតាបិតាខ្លះ ពួកគាត់មិនបានចេញទៅរកស៊ីធ្វើការងារនៅទីឆ្ងាយ ៗ ដូចបានពោលពណ៌នាមកនេះទេ តែពួកគាត់ខិតខំធ្វើស្រែចំការបង្កបង្កើនផល ខំលើកភ្លឺស្រែទប់ទឹកខំស្ទូង ខំដក ខំដាំដំណាំផ្សេងៗ ខិតខំរែកពុនលីសែង នៅក្រោមកំដៅថ្ងៃ នៅក្រោមតំណក់នៃទឹកភ្លៀង ហាលថ្ងៃ ហាលភ្លៀងហាលខ្យល់ តាំងពីព្រលឹមទល់ព្រលប់ ញើសហូរសស្រាក់ជោគខ្លួនដូចទឹកក៏ដោយ មកដល់ផ្ទះវិញម៉ែឪនៅតែញញឹមដាក់កូនជានិច្ច ។ ដោយសារតែបញ្ហាជីវភាពខ្សត់ខ្សោយ ម៉ែឪខ្លះបានបង្ខំចិត្តទៅស៊ីឈ្នួលជួយដកស្ទូង ច្រូតកាត់ រែកពុន លីសែង ធ្វើការងារបំរើឱ្យគេទោះបីជាការងារស្រាលក្ដីធ្ងន់ក្ដី ត្រូវគេស្ដីថា គេជេរ គេប្រើរក់រឹយ៉ាងណាក៏ដោយ ក៏គាត់ទ្រាំបានទាំងអស់ ដើម្បីបានលុយបានប្រាក់មកចិញ្ចឹមកូន ។ គាត់នឹកឃើញហើយថា ការស្វែងរកលុយ

កាក់ ទម្រាំតែបានមួយរៀល១ មួយរយ១ មួយពាន់១ មួយម៉ឺន១ ដាក់ហោប៉ៅនោះ វាមានការនឿយហត់លំបាកខ្លាំងណាស់សម្រាប់ពួកគាត់ដែលគ្មាននូវចំណេះដឹងនោះ ។ ដូច្នេះគាត់មិនចេះតែចាយវាយផ្ដេសផ្ដាសនោះឡើយ មុននឹងចាយវាយមួយកាក់មួយសេននោះ ពួកគាត់បានគិតគូរវែងឆ្ងាយណាស់ ។ សូម្បីខ្លួនពួកគាត់មានជំងឺក៏ដោយចុះ បើគិតថា ជំងឺនោះបន្តិចបន្តួចនឹងអាចជាសះស្បើយ ពួកគាត់មិនហ៊ានឱ្យកូនដឹងទេ សុខចិត្តលាក់ពួនបិទបាំងឈឺចាប់តែម្នាក់ឯង ដើម្បីឱ្យតែកូនបានសុខបានសប្បាយ។ សូម្បីទិញថ្នាំពេទ្យលេប ក៏គាត់មិនចេះតែទិញផ្ដេសផ្ដាសដែរ គាត់សន្សំខ្លាំងណាស់ ។ ម្យ៉ាងទៀតមានមាតាបិតាខ្លះ ទោះបីជាពួកគាត់ឃ្លានរបស់អ្វី ចង់ទទួលទានរបស់អ្វី ចង់បានសម្លៀកបំពាក់ថ្មី នាឡិកាថ្មី ក៏គាត់ស៊ូអត់ស៊ូទ្រាំដែរ គាត់សុខចិត្តហូបបាយប្រហុក បាយអំបិល បាយសម្លបន្លែស្លឹកឈើជាដើមក៏បានដែរ ។ សម្លៀកបំពាក់មិនចាំបាច់ថ្មី១ណាស់ណានោះទេ គ្រាន់តែល្មម ១ ប្រហែលនឹងគេទៅបានហើយ។ ចំណែកឯកូននោះវិញ បើសិនជាមានជំងឺឈឺថ្កាត់ម្ដង ១ ម៉ែឪភ័យស្លន់ស្លោមុខស្លាំងអស់ មិនសុខមិនសប្បាយចិត្តទេ ។ បើកូននៅតែឈឺ និងក្ដៅខ្លួន នៅតែយំមិនឈប់យ៉ាងនេះ មាតាបិតាទោះបីជាពួកគាត់គ្មានលុយគ្មានប្រាក់ក៏ដោយ ក៏សុខចិត្តទៅខ្ចីទៅបុលបញ្ចាំគេ ដើម្បីយកលុយយកប្រាក់មកមើលថែជំងឺកូន រួចក៏ចាប់ផ្ដើមលក់របស់នេះ របស់នោះ លក់មាន់ លក់ទា ជ្រូកគោ ក្របី ដីស្រែចំការជាដើម ដើម្បីបានលុយយកទៅសងគេវិញ។ បើសិនជាកូននោះ ឈឺពេលយប់ពេលអធ្រាត្រ មាតាបិតារត់ទៅដាស់ញាតិមិត្តជិតខាង ដាស់គ្រូពេទ្យ ផ្លូវងងឹតចាក់ភ្នែកមិនយល់ស្វាត់ជ្រងំសូន្យឈឹងយ៉ាងណាក៏ដោយ ក៏ពួកគាត់លែងខ្លាចអស់ហើយ។ ម្យ៉ាងទៀតមាតាបិតា បើគាត់អាចផ្ទេរជំងឺពីកូនមកឈឺខ្លួនឯងបាន ពួកគាត់ប្រាកដជាមិនព្រមឱ្យកូនឈឺនោះទេ។ ពីមួយឆ្នាំទៅមួយឆ្នាំ កូនចេះតែធំឡើងជាលំដាប់ ហើយមិនមែនតែកូនមួយទេ លោកអ្នកអានជ្រាបស្រាប់ហើយ មាតាបិតាខ្លះមានកូនច្រើនណាស់ រហូតទៅដល់១០នាក់ក៏មានដែរ។ ដូច្នេះការចំណាយក្នុងគ្រួសារក៏មានចំនួនកាន់តែច្រើនឡើងទ្វេដងដែរ ។ មាតាបិតា

ត្រូវទិញសម្លៀកបំពាក់ថ្មីៗ ទិញប៊ិច ទិញសៀវភៅ និងទិញគ្រឿងសិក្សាផ្សេងៗទៀត សម្រាប់កូនគាត់គ្រប់ៗគ្នា ។ មាតាបិតានាំកូនឱ្យទៅរៀននៅតាមសាលាបឋមសិក្សាក្បែរៗភូមិ គាត់មិនទុកកូនប្រើនៅឯផ្ទះនោះទេ ពួកគាត់នឹករលឹកឃើញហើយថា កាលណាបើគ្មានចំណេះវិជ្ជានោះទេ វានាំឱ្យពូជពង្សវង្សត្រកូលអាប់ឱន នាំឱ្យគេមើលងាយ នាំឱ្យក្រីក្រលំបាកតោកយ៉ាកជាដើម ធ្វើដូចម្ដេចខ្លួនឯងកើតមកចំសម័យស្រុកមានសង្គ្រាមមិនបានរៀនសូត្រ ទើបវាក្រីក្រលំបាកមកដល់សព្វថ្ងៃនេះ ។ ដូច្នេះគាត់មិនសុខចិត្តទុកកូនរបស់ខ្លួនឱ្យនៅល្ងង់ខ្លៅជាមួយនឹងពួកគាត់នោះឡើយ ទោះបីជាពួកគាត់ក្រីក្រលំបាកវេទនាយ៉ាងណាក៏ដោយចុះ។

ម៉ែឪអ្នកក្រឱ្យកូនរៀន ខំប្រឹងស្មើរលៀនភ្នែកគ្រប់គ្នា
លក់គោក្របីជ្រូកមាន់ទា ដីស្រែចំការសឹងមិនសល់ ។
កូនខ្លះផ្ដេសផ្ដាសមិនខំរៀន ថែមហ៊ានយកលុយម៉ែឪផ្ដល់
ចាយវាយហ៊ឺហាហក់តាមខ្យល់ មិនមានគិតដល់ញើសឪម៉ែ។
កូនខ្លះពូកែខាងរៀនសូត្រ ស្ទុះលូតរបូតផុតដីស្រែ
ធ្វើការរាជការបានប្រាក់ខែ ប៉ុន្តែភ្លេចអស់រឿងក្រក្រី ។
ភ្លេចគុណមាតានិងបិតា លោកតែងឧស្សាហ៍ប្រោសប្រណី
ផ្ដល់លុយផ្ដល់កាក់រៀងរាល់ថ្ងៃ សន្សំសំចៃឱ្យខ្លួនរៀន ។

សូមលោកអ្នកអានទាំងឡាយជ្រាបថា កាលណាបើមាតាបិតាមានកូនហើយបង្ខាំងកូនទុកឱ្យនៅតែផ្ទះជួយសម្រាលការងាររបស់ខ្លួនតែម្យ៉ាង មិនបញ្ជូនកូនឱ្យទៅរៀនចំណេះរបៀននានានោះទេ មាតាបិតានោះឯងលោកចាត់ទុកថា ជាសត្រូវរបស់កូនដោយពិត។ ព្រោះហេតុអ្វី ? ព្រោះថា ក្រោយពេលដែលកូននោះធំពេញរូបពេញរាងហើយ រមែងធ្វើវង្សត្រកូលឱ្យអាប់ឱន កូននោះឯងងាយនឹងចាញ់បោកគេ ងាយនឹងជឿគេ ឆាប់ធ្លាក់ខ្លួនទៅប្រព្រឹត្តអំពើពាលាផ្ដេសផ្ដាសខុសទៅនឹងច្បាប់រដ្ឋច្បាប់សង្គមច្បាប់សាសនាជាដើម ដោយសារតែកូននោះគ្មាននូវចំណេះដឹងហ្នឹងឯង។ មាតាបិតាទោះបីជាជាប់រវល់យ៉ាងណាក៏ដោយចុះ ក៏នៅតែឆ្លៀតពន្យល់ណែនាំអប់រំកូនឱ្យស្គាល់បុណ្យ បាប អាក្រក់ ល្អ ស ខ្មៅ ឱ្យចេះគោរពចាស់ទុំ ចេះគោរពត្រកូលរៀមច្បងជាដើម ។ កូនខ្លះ

ពេលមាតាបិតាពន្យល់ណែនាំមិនធ្វើតាមទេ ទទឹងរឹងរូសនឹងពួកគាត់ដោយអាងលើជីដូន។ មាតាបិតាឃើញអញ្ចឹង គាត់ក៏អាក់អន់ស្រពន់ចិត្តវាយកូននឹងបាតដៃរបស់ខ្លួនខ្លះ វាយនឹងរំពាត់ខ្លះ ព្រោះគោលគំនិតមួយថា ខ្លាចកូនវាខិលខូចនិយាយវាលែងស្តាប់ទៅថ្ងៃមុខថ្ងៃក្រោយ ។ ម៉ែឪមិនចង់ធ្វើដូច្នេះទេ មិនចង់ប្រើអំពើហិង្សាដាក់កូន មិនចង់វាយវាត់ទាត់ធាក់កូននោះឡើយ។ មាតាបិតាខ្លះខឹងស្តីប្រដៅអប់រំពន្យល់ណែនាំកូន កូនមិនព្រមស្តាប់តាមបង្គាប់មិនព្រមធ្វើតាម ពួកគាត់ក៏បានស្តីប្រដៅអប់រំពន្យល់ណែនាំរហូតដល់ថ្នាក់វាយដំច្រំធាក់ក៏មានដែរ ។ មាតាបិតាខ្លះទៀតវាយវាត់ទាត់ធាក់កូន ខឹងកូននិយាយប្រដៅមិនស្តាប់ ពេលក្រោយមកនឹកឃើញកំហុសរបស់ខ្លួន សោកស្តាយខ្លាំងណាស់ អង្គុយយំទាំងពីរនាក់ប្តីប្រពន្ធថា " អញមិនគួរវាយវាត់កូនសោះ "។ ជួនកាលឪពុកវាយកូន ម៉ែឃើញដូច្នោះ ក៏បានឃាត់អង្វរឱ្យឈប់វាយ ពេលឃើញកូនយំ ម៉ែអត់ទ្រាំមិនបានក៏យំតាមកូនដែរ។ ជួនកាលទៀតមាតាបិតាវាយកូនពេលថ្ងៃ ដល់យប់ព្រលប់ឡើង នឹកអាណិតកូន

លុះពេលកូនដេកលក់ទៅ ពួកគាត់ទាំងពីរនាក់លបទៅបើកមុងបើកភួយមើលកូន ឃើញមានស្នាមរបួសស្នាមរំពាត់ដែលពួកគាត់វាយកាលពីថ្ងៃនោះ ម៉ែឪរត់ស្វះស្វែងកាត់ភក់កាត់ល្បាប់ទាំងយប់ទាំងអធ្រាត្រ ដើម្បីរកទិញប្រេងកូឡាលាបរឹតឱ្យកូន។ មាតាបិតាសូម្បីកាលពួកគាត់ធ្វើយ៉ាងនេះក៏ដោយ ប៉ុន្តែចិត្តរបស់ពួកគាត់មិនមានគិតអាក្រក់ សូម្បីបន្តិចបន្តួចទៅលើកូននោះឡើយ។ បើសិនជាគាត់មានគោលបំណងអាក្រក់ចំពោះកូនមែននោះ ពួកគាត់មិនចាំបាច់ចិញ្ចឹមមើលថែរក្សាបីបាច់យើងដែលជាកូន ឱ្យបានរស់រានមានជីវិត បានសុខបានសប្បាយ រហូតមកដល់សព្វថ្ងៃនេះឡើយ។ លោកសម្តែងថា បើសិនជាមាតាបិតា មិនចង់ឱ្យកូនមានជីវិតរស់នៅមែននុ៎ះ ពួកគាត់អាចសម្លាប់កូនរបស់ខ្លួនបានយ៉ាងងាយស្រួលជាទីបំផុតគឺអាចសម្លាប់តាំងតែពីកូននៅក្នុងផ្ទៃក៏បាន ឬពេលដែលកូនកើតមកថ្មីៗនៅជាទារកក៏បាន។ មាតាបិតាគ្រាន់តែចាប់ត្រង់កជើងរបស់កូន ហើយគ្រវែងចូលទៅក្នុងទឹកស្ទឹង កូននោះក៏នឹងអាចស្លាប់បានភ្លាម។ ប៉ុន្តែលោកមិនអាចធ្វើដូច្នេះបានទេ ព្រោះ

កូននេះ គឺជាសាច់ឈាម ជាដួងហឫទ័យ ជាអាយុជីវិតរបស់ពួកគាត់ទាំងពីរ ។ ដូចដែលយើងឃើញស្រាប់ហើយ គាត់ចិញ្ចឹមកូនគាត់មិនបានគិតយកកម្រៃថ្លៃឈ្នួលជាមាស ជាប្រាក់ ឬ ក៏ជារបស់អ្វីពីកូននោះឡើយ សូមឱ្យតែកូនរបស់គាត់បានជាមនុស្សល្អចេះគោរពចាស់ទុំ ចេះធ្វើបុណ្យធ្វើទាន ចេះស្រឡាញ់រាប់អានគ្នាទៅវិញទៅមក មានរបស់អ្វីក៏ចេះចែករំលែកដល់គ្នា មិនឈ្លោះទាស់ទែងគ្នាទៅ ម៉ែឪពេញចិត្តណាស់ទៅហើយ ។ នៅក្នុងលោកនេះតើមានមាតាបិតាណា ដែលមិនចង់ឃើញកូនរបស់ខ្លួនបានសុខបានសប្បាយនោះ ? តើមានមាតាបិតាណា ដែលចង់ឃើញកូនរបស់ខ្លួនជួបនូវសេចក្តីទុក្ខលំបាកនោះ ? មាតាបិតារកស៊ីរាល់ថ្ងៃនេះជួនកាលត្រូវកាប់សម្លាប់បំបាត់ជីវិតសត្វដទៃ ត្រូវលក់ដូរគេទាំងរស់ ឱ្យគេព្រាត់ប្រាសចាកមេ និងកូន ដែលជាទីស្រឡាញ់នៃគ្នានិងគ្នា ។ជួនកាលទៀត មាតាបិតារកស៊ីបានភូតភរកុហកបោកបញ្ឆោតកេងប្រវ័ញ្ចអ្នកដទៃ ដើម្បីបានលុយបានប្រាក់ទុកសម្រាប់ចិញ្ចឹមកូន ព្រោះតែចង់ឱ្យកូនបានរៀនសូត្រ បានសុខបានសប្បាយនឹងគេ។ មាតាបិតាដឹងប្រាកដណាស់ មិនមែនមិនដឹងនោះទេថា អំពើដែលខ្លួនកំពុងធ្វើនេះ ជាអំពើបាបខុសចាកសីលធម៌ ខុសទាំងច្បាប់សាសនា ខុសទាំងច្បាប់រដ្ឋច្បាប់សង្គម ក្រោយពេលខ្លួនស្លាប់ទៅបាបកម្មទាំងអស់នេះមិនបានបាត់បង់ទៅឯណាទេ នឹងនាំខ្លួនឱ្យចូលទៅកើតនៅក្នុងទុគ្គតិភពមាននរក ប្រេត អសុរកាយ និងតិរច្ឆានជាដើមមិនខានឡើយតែដើម្បីកូនជាទីស្រឡាញ់ជាទីហួងហែងនិងជាទីប្រាថ្នា ម៉ែឪទ្រាំធ្មេចភ្នែកធ្វើបានទាំងអស់។ ពេលខ្លះកូនមិនស្តាប់ម៉ែឪ ទៅប្រព្រឹត្តធ្វើអំពើបាបកម្មផ្សេង ៗ ខុសទៅនឹងច្បាប់សីលធម៌សង្គម ដូចជាទៅលួចគេ ឆបោកប្រាស់គេនិងវាយតប់កាប់ចាក់អ្នកដទៃជាដើម ត្រូវគេចាប់យកទៅដាក់ខ្នោះ ដាក់គុក ដាក់ច្រវាក់ គេវាយដំច្រំធាក់កូន គេប្តឹងយកលុយប៉ុណ្ណោះម៉ឺន ប៉ុណ្ណោះសែន ប៉ុណ្ណោះលានជាដើម។ ម៉ែឪដឹងប្រាកដថា កូនរបស់គាត់ខុសដោយពិត ប៉ុន្តែពួកគាត់មានមេត្តាចំពោះកូន ពួកគាត់សន្តោសប្រោសប្រណីចំពោះកូន ពួកគាត់មិនអាចទ្រាំមើលគេវាយធ្វើបាបកូនរបស់ខ្លួនបានទេ។ ដូច្នេះហើយមាតាបិតាបានកាត់កេរ្តិ៍កាត់ខ្មាស

ទៅខ្ចីបុលបញ្ចាំចងការប្រាក់គេ ដើម្បីយកទៅសុំលស់កូនយកពីគេមកវិញ មិនហ៊ានបង្អង់ទុកយូរទេ ព្រោះខ្លាចគេធ្វើបាបកូនរបស់ខ្លួន ។ ម្ដាយឪពុកឱ្យតែកូនបានរួចខ្លួនផុតចាកទុក្ខភ័យ សូម្បីគេមានអាយុតិចជាងខ្លួនវ័យនៅក្មេងជាងខ្លួនក៏ដោយ ក៏សុខចិត្តទៅសំពះអង្វរគេ សូមឱ្យគេដោះលែងកូនរបស់ខ្លួនថា លោកអើ្ហយ ! សូមលោកដោះលែងកូនរបស់ខ្ញុំមក ខ្ញុំសូមអង្វរ លោកកុំយកទោសពៃរ៍វាអី វានៅក្មេងណាស់ វាមិនដឹងការណ៍រាក់ជ្រៅនោះទេ លោកត្រូវការរបស់អ្វី ចង់បានប្រាក់ចំនួនប៉ុន្មាន ឱ្យតែលោកដោះលែងកូនរបស់ខ្ញុំ ខ្ញុំជូនលោកបានទាំងអស់។ ពេលខ្លះទៀតម៉ែឪឃើញកូនធ្វើខុស ចង់កែតម្រូវកូន ក៏បានពន្យល់ណែនាំស្ដីជេរប្រដៅកូនដោយពាក្យធ្ងន់ខ្លះស្រាលខ្លះ កូនវាអាក់អន់ចិត្តខឹងនឹងមាតាបិតា វារត់គេចចេញពីផ្ទះបាត់ទៅ។ ដល់ពេលបាយថ្ងៃត្រង់ បាយល្ងាចក្ដី មាតាបិតាធ្លាប់តែបាយជុំគ្នាជាមួយកូន ដល់ពេលបាត់មុខកូនទៅ លេបបាយលែងចូលអស់ ទទួលទានអាហារម្ដងៗ ធ្លាប់តែមានរសជាតិឆ្ងាញ់ពិសា ឥឡូវនេះប្រែក្លាយទៅជាចត់ ជាល្វីងអស់ហើយ លេបបាយស្រូបជាមួយទឹកភ្នែក ។ពេលយប់ឡើង ដល់ពេលសម្រាន្តម្ដាយឪពុកធ្លាប់តែឃើញកូន ធ្លាប់តែចងមុង ដណ្ដប់ភួយឱ្យកូនគេង ឥឡូវនេះមិនឃើញមុខកូន គ្រួសារដែលធ្លាប់តែមានភាពសប្បាយរីករាយកក់ក្ដៅមុនពេលគេងលឺសំឡេងសើចប្រលែងគ្នាមិនដាច់នោះ បានប្រែក្លាយទៅជាមានសភាពស្ងប់ស្ងាត់ ពោរពេញទៅដោយទុក្ខកង្វល់ ។ មាតាបិតានឹកស្ដាយកំហុសរបស់ខ្លួនខ្លាំងណាស់ យំខ្សឹបខ្សួលអួលអាក់ទឹកភ្នែកស្រក់កាត់ផែនថ្ពាល់ហូរមកមិនដាច់ នឹកឃើញហើយថ្ងៃនេះកូនធ្លាប់តែបានសុខ ធ្លាប់តែបានសប្បាយ ឥឡូវនេះមិនដឹងជាកូនទៅដេកពួននៅឯណា កូនបានរបស់អ្វីហូប កូនទុក្ខលំបាកយ៉ាងណា ក៏ម៉ែឪមិនដឹង កូនអើ្ហយ ! កូននៅក្មេងណាស់ កូនមិនគួរអីចិត្តដាច់យ៉ាងនេះទេ។ មាតាបិតាគ្រប់រូបនៅមិនសុខទេ កាលបើបាត់កូនពីផ្ទះយ៉ាងនេះ ដើរស្វែងរកកូនទាំងយប់ទាំងអធ្រាត្រខ្វាត់ខ្វែងគ្រប់ទីកន្លែងទាំងអស់ សូម្បីតែយប់ងងឹតស្ងាត់សូន្យឈឹងភ្លៀងធ្លាក់ពពិចប៉ប៉ាច់ ផ្លូវសុទ្ធតែភក់ល្បាប់យ៉ាងណាក៏ដោយ ក៏មាតាបិតាសុខចិត្តដែរ ដើម្បីដើររកកូន

ឱ្យបានឃើញយកមកផ្ទះវិញ។មាតាបិតាចិញ្ចឹមកូនរាល់ថ្ងៃនេះ មិនចង់ឱ្យកូនហត់នឿយលំបាកនោះឡើយ ចង់ឱ្យតែកូនបានសុខបានសប្បាយរកស៊ីមានបានទៅ ម៉ែឪពេញចិត្តណាស់ទៅហើយ។ ពេលកូនធ្វើអំពើល្អ កូនរកស៊ីមានបាន សូម្បីកូនមិនបានឱ្យរបស់អ្វីដល់មាតាបិតាក៏ដោយ ឱ្យតែកូនធ្វើល្អបានសុខបានសប្បាយទៅ ពួកគាត់ក៏បានត្រេកអរសប្បាយចិត្តខ្លាំងណាស់ហើយ។ សូម្បីពេលខ្លះម៉ែឪដែលចិញ្ចឹមកូន កូននោះមានសេចក្តីទុក្ខលំបាកខ្លះៗ ព្រោះមាតាបិតាមិនអាចធ្វើឱ្យកូនបានសុខ បានសប្បាយ រីករាយ គ្រប់ពេលគ្រប់វេលាក៏ដោយ ប៉ុន្តែទឹកចិត្តរបស់មាតានិងបិតាគ្រប់រូបក្រៅអំពីមិនចង់ឱ្យខ្លួនលំបាកហើយ ពិសេសជាងនេះទៅទៀត ពួកគាត់មិនចង់ឱ្យកូនរបស់ខ្លួនមាននូវសេចក្តីលំបាកផងដែរ។ លោកអ្នកអានទាំងឡាយត្រូវដឹងថា ចំនុចត្រង់នេះ គឺជាមេរៀនមួយដ៏សំខាន់បំផុត ដែលមាតាបិតាគ្រប់រូបត្រូវតែបង្រៀនដល់កូនប្រុសស្រីជាទីស្រលាញ់និងជាទីប្រាថ្នារបស់ខ្លួន។ ព្រោះហេតុអ្វី ? ព្រោះថា មាតាបិតាដែលស្រឡាញ់កូនទុកកូនឱ្យទំនេរ មិនឱ្យកូនហត់នឿយលំបាកតាំងតែពីក្មេងមកបែបនេះ គឺធ្វើបាបកូនទៅវិញទេ។ ផ្ទុយទៅវិញមាតាបិតាខ្លះទៀត គាត់ហ្វឹកហាត់កូនឱ្យចេះហត់ ចេះលំបាកតាំងតែពីកូននៅក្មេងៗ ឱ្យរៀនធ្វើស្រែចំការ រៀនរកស៊ីលក់ដូរ និងរៀនរស់នៅរកលុយរកកាក់ដោយខ្លួនឯងប៉ុណ្ណោះជាដើម ។ មាតាបិតាគ្រប់រូបទាំងអស់នៅលើលោកនេះ គាត់គិតឃើញច្បាស់លាស់ហើយ ទើបបានជាគាត់ធ្វើបែបនេះ។ ពួកគាត់គិតឃើញថាខ្លួនគាត់ទាំងពីរនាក់ មានអាយុកាន់តែច្រើន មានវ័យកាន់តែចាស់ទ្រុឌទ្រោមគ្រាំគ្រាពីមួយឆ្នាំទៅមួយឆ្នាំ នឹងនៅចិញ្ចឹមកូនរហូតនោះមិនបានឡើយ។ ដូច្នេះហើយគាត់ក៏បានបង្រៀនកូន ឱ្យចេះសព្វបែបយ៉ាងឱ្យហើយ ដើម្បីឱ្យកូនចេះរស់នៅក្នុងសង្គម ចេះព្យាយាមប្រឹងប្រែងរកស៊ីដោយខ្លួនឯង។ កូនដែលធ្លាប់ទទួលការហ្វឹកហាត់មេរៀនបែបនេះអំពីមាតាបិតា ក្រោយពេលពួកគាត់លាចាកលោកនេះទៅ កូននោះក៏ចេះរស់នៅបានសុខបានសប្បាយដោយខ្លួនឯងទៅបាន។ នៅក្នុងលោកយើងនេះ មានកូនមិនតិចនាក់ទេ មិនដែលធ្លាប់ហត់នឿយ មិនដែលធ្លាប់លំបាកពីក្មេងៗមក

ធ្វើអ្វីក៏ដោយ ធ្លាប់តែពឹងពាក់លើមាតាបិតាជានិច្ចនោះ ដល់ពេលមាតាបិតាស្លាប់ទៅ កូននោះមិនចេះធ្វើការងារ រកស៊ីអ្វីក៏មិនចេះ ជួញប្រែអ្វីក៏មិនកើត ចាប់នេះរបូត ចាប់នោះរបូត នឹងទីពឹងម៉ែឪទៀតក៏មិនបានឡើយ ។ នៅទីបំផុតក៏នឹកសោកស្តាយនូវកំហុសរបស់ខ្លួន ទម្រាំតែភ្ញាក់ខ្លួនឡើង វាយឺតពេលបាត់ទៅហើយ ។ មាតាបិតាដែលចិញ្ចឹមកូន គឺចិញ្ចឹមដោយទឹកចិត្តដ៏បរិសុទ្ធ ប្រកបដោយព្រហ្មវិហារធម៌និងសង្គហធម៌ចំពោះកូនគ្រប់ពេលគ្រប់វេលាទាំងអស់ ។ យើងបានឃើញហើយនូវមហាពលិកម្មដ៏ធំធេងដែលមាតាបិតាគ្រប់រូបបានបំពេញទាំងអស់នេះ គឺដើម្បីកូន ៗ របស់គាត់គ្រប់គ្នា ។ តើមានកូនប៉ុន្មាននាក់ទៅ ដែលពិចារណាឃើញយ៉ាងនេះ ?

សរុបសេចក្តីមកមហាពលិកម្មទាំងអស់នេះ មិនងាយនឹងមានបុគ្គលណាម្នាក់អាចធ្វើបាននោះឡើយ ។ ប៉ុន្តែសម្រាប់មាតាបិតាវិញ ពួកគាត់អាចធ្វើបានដោយសព្វគ្រប់ទាំងអស់ ។ យើងអាចមើលឃើញបានតែខាងក្រៅប៉ុណ្ណោះ ចំណែកឯទឹកចិត្តដ៏បរិសុទ្ធខាងក្នុងរបស់ពួកគាត់ យើងមិនអាចមើលឃើញបាននោះទេ។ ដូច្នេះ សូមកូនប្រុសស្រីទាំងឡាយ កុំវាយតម្លៃទឹកចិត្តរបស់មាតាបិតាឱ្យសោះ កុំគិតប្រទូស្តនឹងមាតាបិតាឡើយ សូម្បីមានរឿងរ៉ាវអ្វីក៏ដោយចុះ ត្រូវតែគោរពឱនលំទោនជានិច្ច ទុំះនឹងបានសុខបានចម្រើន។ បើមិនដូច្នោះទេ នឹងមានបាបកម្មធ្ងន់ណាស់ ជួបនូវសេចក្តីទុក្ខអស់កាលជាអង្វែង និងជាអ្នកដល់នូវសេចក្តីវិនាសទាំងបច្ចុប្បន្នជាតិនិងអនាគតជាតិមិនខានឡើយ។ ព្រោះមាតាបិតា គឺព្រះបង្កើតរូបយើង និងប្រគល់អ្វីៗគ្រប់យ៉ាងនៅក្នុងលោកនេះ ឱ្យដល់យើងគ្រប់គ្នា ។ បើយើងមិនបានអាស្រ័យនឹងព្រះមាតាបិតាហើយ តើយើងនឹងអាចកើតមកបានយ៉ាងដូចម្តេច ? តើមនុស្សលោកនឹងមានមកអំពីណាបាន ? បើមាតាបិតាមិនមានហើយ កូនប្រុសស្រីទាំងឡាយក៏មិនមាន កាលណាបើកូនប្រុសស្រីទាំងឡាយមិនមានហើយ តើមនុស្សលោកដទៃទៀតនឹងមានមកពីណាបាន? ដូច្នេះយើងអាចនិយាយបានថា មាតាបិតា គឺ ជាព្រះបង្កើតនូវមនុស្សលោកផង បង្កើតនូវអ្វីៗគ្រប់យ៉ាង ដែលមនុស្សលោកកំពុង

តែមាន កំពុងតែប្រើប្រាស់រាល់ថ្ងៃនេះផង ។ ម្យ៉ាងទៀត មាតាបិតាគឺជាម្ចាស់នៃទ្វីបលោកទាំងមូល ដែលយើងកំពុងតែរស់នៅ កំពុងតែស្ថិតនៅនេះ និងជាម្ចាស់របស់គ្រប់យ៉ាង ដែលមាននៅលើលោកនេះផងដែរ ។

សូឱ្យកូនទាំងឡាយ បានក្លាយទៅជាទាយាទដ៏ល្អរបស់មាតាបិតា។ សូមឱ្យកូនទាំងឡាយ បានក្លាយទៅជាក្តីសង្ឃឹមរបស់មាតាបិតាគ្រប់រូប ។ សូមឱ្យកូនទាំងឡាយបានក្លាយទៅជាអ្នកស្នងត្រកូលដ៏ល្អរបស់មាតាបិតា សមដូចពាក្យមួយឃ្លាថែងថា " ទំពាំងស្នងឫស្សី ឯកូនប្រុសស្រីស្នងត្រកូល " ។ សូមឱ្យកូនប្រុសស្រីទាំងឡាយរស់នៅបានសុខសប្បាយ ក្រោមម្លប់នៃព្រហ្មវិហារធម៌របស់មាតាបិតា ។ សូមឱ្យព្រហ្មវិហារធម៌ និងសង្គហធម៌ ព្រមទាំងគុណធម៌ដទៃទៀតរបស់មាតាបិតា ជួយអភិសេកកូនប្រុសស្រីគ្រប់រូបឱ្យបានក្លាយទៅជាកូនដ៏ល្អរបស់មាតាបិតា និងក្លាយទៅជាប្រជាពលរដ្ឋដ៏ល្អរបស់សង្គមជាតិ ។ សូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ ។/

## សុភាសិត

សុរិយាបំភ្លឺត្រឹមតែពេលថ្ងៃ ច័ន្ទពេញបូណ៌មីបំភ្លឺពេលយប់
រីឯព្រះធម៌សែនល្អលើសលប់ បំភ្លឺថ្ងៃយប់ឥតបង់រស្មី ។
បំភ្លឺដល់ជនដែលប្រព្រឹត្តល្អ គោរពព្រះធម៌សន្សំបារមី
រក្សាកិត្តិយសរស់នៅមានន័យ ទោះចាប់ភពថ្មីក៏មិនងងឹត ។/

## បុរាណភាសិត

អំណត់កើតអំណាច ខឹងច្រើនពេកកើតទោសា
ប៉ោចៗអាប់ប្រាជ្ញា យូរៗថាថ្លៃដូចមាស ។/

## មាតាបិតាមានឈ្មោះហៅ៤យ៉ាង

បុរសស្ត្រីណាដែលបានបង្កើតកូននិងបានចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យរស់រានមានជីវិត បុរសស្ត្រីនោះឈ្មោះថា **មាតាបិតា** ។ បើយើងហៅឈ្មោះមាតាបិតាទៅតាម **សម្មតិនាម** គឺឈ្មោះដែលកើតឡើងដោយការសន្មតិហៅគ្នាទៅវិញទៅមកថា បុគ្គលនេះឈ្មោះនេះ បុគ្គលនោះឈ្មោះនោះ យាយនេះឈ្មោះសុខ តានោះឈ្មោះសំជាដើម យើងឃើញថា មានច្រើនណាស់ទៅតាមស្រុក ភូមិ តំបន់និងប្រទេសនីមួយៗ ។ ប៉ុន្តែនៅក្នុងព្រះពុទ្ធសាសនា មាតាបិតាលោកឱ្យឈ្មោះ ៤ យ៉ាងគឺ ព្រះព្រហ្ម ១ បុព្វទេវា ១ បុព្វាចារ្យ ១ អាហុនេយ្យបុគ្គល ១ ។ សមដូចន័យ ដែលលោកសម្តែងបញ្ជាក់ក្នុងគម្ពីរមង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រភាគ ២ ត្រង់មាតាបិតុ-ឧបដ្ឋានកថាទុកមកថា " **ឧភោបិ ចេតេ ព្រហ្មា បុព្វទេវា បុព្វា-ចរិយា អាហុនេយ្យាតិ ច វុច្ចន្តិ** " *ប្រែថា* : លោកអ្នកប្រាជ្ញទាំងឡាយឱ្យឈ្មោះមាតាបិតាទាំងពីរនាក់នោះថា ជាព្រះព្រហ្មផង ជាបុព្វទេវាផង ជាបុព្វាចារ្យផង ជាអាហុនេយ្យបុគ្គលផង របស់កូនប្រុសស្រីគ្រប់រូប ។ មានន័យមួយកន្លែងទៀត ដែលលោកសម្តែងបញ្ជាក់ទុកនៅក្នុងគម្ពីរដដែលនោះដែរថា **ព្រហ្មាតិ មាតា-បិតរោ បុព្វាចរិយាតិ វុច្ចរេ អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកាតិ** " *ប្រែថា* : មាតាបិតាលោកហៅថា ជាព្រះព្រហ្មផង ជាបុព្វាចារ្យផង ជាអាហុនេយ្យបុគ្គលផង របស់បុត្រទាំងឡាយ ព្រោះជាអ្នកធ្វើនូវការអនុគ្រោះដល់ពពួកសត្វទាំងឡាយ ។

## សេចក្តីអធិប្បាយ

**១ / មាតាបិតាជាព្រះព្រហ្មរបស់កូនប្រុសស្រី :** ព្រោះគាត់មាននូវព្រហ្មវិហារធម៌ទាំង ៤ ប្រការចំពោះកូនប្រុសស្រី ។ មហា-ព្រហ្ម ដែលមនុស្សលោកច្រើនតែយល់ថា មានមុខ ៤ នោះ ព្រោះប្រកបដោយធម៌របស់ព្រហ្មគឺ ភាវនាធម៌ទាំង ៤ ប្រការ : **មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** ចំពោះពពួកសត្វទាំងឡាយយ៉ាងណាមិញ មាតាបិតាដែលឈ្មោះថា ព្រះព្រហ្មរបស់កូនប្រុសស្រី ព្រោះលោកប្រកបដោយព្រហ្មវិហារធម៌ទាំង ៤ ប្រការគឺ **មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** ចំពោះកូនប្រុសស្រីទាំងឡាយក៏យ៉ាងនោះ

ដែរ ។ ព្រះព្រហ្មមានមុខ ៤ (ចតុម្មុខ) ព្រោះលោកប្រកបដោយភាវនាធម៌ទាំង ៤ ចំពោះពពួកសត្វទាំងឡាយយ៉ាងណាមិញ មាតាបិតាដែលប្រកបដោយព្រហ្មវិហារធម៌ ៤ យ៉ាងចំពោះកូនប្រុសស្រីទាំងឡាយក៏មានមុខ ៤ ដូចជាព្រះព្រហ្មនោះដែរ ។ ពាក្យថា "**ព្រហ្មវិហារធម៌** " ជាភាសាបាលី បើប្រែមកជាភាសាខ្មែរទៅឃើញថា ងាយស្តាប់បានជាង **ព្រហ្មវិហារធម៌** = ( **ព្រហ្ម** + **វិហារ** + **ធម៌** )

**ព្រហ្ម** : ប្រែថា ប្រសើរ វិសេស ថ្លៃថ្លា ។

**វិហារ** : ប្រែថា ជម្រក កន្លែងជាទីជ្រកកោនកន្លែងជាទីនៅអាស្រ័យ ។

**ធម៌** : ប្រែថា ធម៌ សភាវៈដែលទ្រទ្រង់នូវសត្វទាំងឡាយ ។

សរុបសេចក្តីមកពាក្យថា " **ព្រហ្មវិហារធម៌** " ប្រែថា ធម៌ជាជម្រកដ៏ប្រសើររបស់កូនប្រុសស្រីទាំងឡាយ ។ មានន័យថា កាលបើមាតាបិតាគ្មាននូវព្រហ្មវិហារធម៌នេះទេ កូនប្រុសស្រីទាំងឡាយនឹងមិនមាននូវជម្រកដ៏ប្រសើរឡើយ ។ ផ្ទះសំបែងនិងទីប្រក់ទីបាំងផ្សេងៗ លោករាប់ថា ជាជម្រករបស់មនុស្សសត្វ ព្រោះមនុស្សសត្វមិនអាចគ្មានជម្រកបានទេ ត្រូវតែមានផ្ទះ មានទីបិទបាំងសម្រាប់ស្នាក់អាស្រ័យនៅទើបបាន ។ ប៉ុន្តែជម្រកទាំងអស់នេះ លោកមិនបានរាប់ថា ជាជម្រកដ៏ប្រសើរនោះឡើយ មានតែព្រហ្មវិហារធម៌មួយទេ ដែលលោករាប់ថា ជាជម្រកដ៏ប្រសើរ ។ ព្រោះកាលណាបើ មាតាបិតាគ្មាននូវព្រហ្មវិហារធម៌ទាំង ៤ ប្រការនេះទេ ឬមានដែរ តែមិនគ្រប់ទាំង ៤ នោះ កូនប្រុសស្រីទាំងឡាយនឹងមិនអាចមានជីវិតរស់នៅបានឡើយ ឬថា រស់បានដែរ តែរស់ទាំងលំបាក ។ ចំណែកឯកូន ដែលបានសុខសប្បាយបានចម្រើន រហូតមកដល់សព្វថ្ងៃនេះបាន លុះណាតែមាតាបិតាប្រកបដោយព្រហ្មវិហារធម៌ទាំង៤យ៉ាងនេះឯង ។ ឯព្រហ្មវិហារធម៌ទាំង៤យ៉ាងនោះគឺ ១ : **មេត្តា** ប្រែថា សេចក្តីស្រឡាញ់រាប់អាន មាតាបិតាកើតមាននូវមេត្តាធម៌នេះ ចំពោះកូនប្រុសស្រីទាំងឡាយតាំង

តែពីកូននៅក្នុងផ្ទៃមកម្ល៉េះ។ ២ : **ករុណា** ប្រែថា សេចក្ដីអាណិតអាសូរ មាតាបិតាកើតមាននូវករុណាធម៌នេះ ចំពោះកូនប្រុសស្រីទាំងឡាយ តាំងតែពីកូនទើបនឹងប្រសូតចាកផ្ទៃម្ដាយមកម្ល៉េះ។ ៣ : **មុទិតា** ប្រែថា សេចក្ដីត្រេកអរតាម មាតាបិតាកើតមាននូវមុទិតាធម៌នេះ ចំពោះកូនប្រុសស្រីទាំងឡាយតាំងតែពីកូនចេះរត់លេងទៅមក ចេះដើរ ចេះនិយាយ ស្ថិតនៅក្នុងវ័យដែលគួរឱ្យស្រឡាញ់ ។ ព្រោះមាតាបិតាគ្រប់រូបមានចិត្តត្រេកអរ សប្បាយរីករាយខ្លាំងណាស់ចំពោះកូនប្រុសស្រីរបស់ខ្លួន នៅពេលដែលពួកគាត់បានឃើញកូន ទើបតែចេះនិយាយ ចេះរត់លេងជាដើម ។

៤ : **ឧបេក្ខា** បើប្រែតាមស័ព្ទថា ការសំឡឹងមើលជាកណ្ដាល ប៉ុន្តែនៅក្នុងទីនេះយើងគួរប្រែថា " ការរំពៃមើល ការសង្កេតមើល ការតាមគយគន់មើលរឿយៗ" ប៉ុណ្ណោះជាដើម មាតាបិតាកើតមាននូវឧបេក្ខាធម៌នេះ ចំពោះកូនប្រុសស្រីទាំងឡាយ នៅក្រោយពេលដែលកូនប្រុសស្រីទាំងឡាយនោះបានរៀបនូវមង្គលការរួចហើយ។

មាតាបិតាឈ្មោះថា ព្រះព្រហ្មរបស់កូនប្រុសស្រីទាំងឡាយ ព្រោះគាត់ទាំងពីរនាក់មាននូវព្រហ្មវិហារធម៌គ្រប់ទាំង ៤ ប្រការ ចំពោះកូនប្រុសស្រីទាំងឡាយ ហាក់បីដូចជាព្រហ្មមាននូវភាវនាធម៌គ្រប់ទាំង ៤ ប្រការ ចំពោះសព្វសត្វទាំងឡាយយ៉ាងនោះឯង។

**២ / មាតាបិតាជាបុព្វទេវារបស់កូនប្រុសស្រី :** ព្រោះគាត់មាននូវឧបការគុណមុនជាងទេព្ដាណាដទៃទៀតទាំងអស់។ ទេវតាមែនៗមានច្រើនណាស់រាប់មិនអស់ទេ មានដូចជា : **ភុម្មទេវតា** ទេវតាដែលអាស្រ័យនៅតាមទីស្រែចំការ តាមស្រុកភូមិជាដើម **រុក្ខទេវតា** ទេវតាដែលអាស្រ័យនៅតាមដើមឈើនានា **បព្វត-ទេវតា** ទេវតាដែលអាស្រ័យនៅតាមបពិត ព្រៃភ្នំក្រមថ្មជាដើម **សមុទ្រទេវតា** ទេវតាដែលអាស្រ័យនៅរក្សាតាមសមុទ្រ ផ្ទៃទឹកទន្លេគង្គានានា **អាកាសទេវតា** ទេវតាដែលអាស្រ័យនៅតាមទីអាកាស ទីវាល ទីលំហនានាជាដើម ឬ ទេវតាដែលស្ថិតនៅក្នុងឋានចាតុម្មហារាជិកា១ តាវតឹង្ស១ យាមា១ តុសិតា១ និម្មានរតី១ បរនិម្មិតវសវត្តី ១ ប៉ុណ្ណោះជាដើម។ ទេវតាទាំងអស់នេះ ខ្លះនៅ

ជាបុថុជ្ជន ខ្លះជាព្រះអរិយបុគ្គល ដែលមានតួនាទីខាងមើលថែរក្សានូវមនុស្សលោក ។ ចំណែកឯមាតាបិតាវិញនោះ បានជាលោកឱ្យឈ្មោះថា **បុព្វទេវា** ជាទេវតាខាងដើម របស់កូនប្រុសស្រីនោះ ព្រោះលោកទាំងពីរនាក់ ក៏មាននាទីខាងមើលថែរក្សាកូនប្រុសស្រី ដូចជាទេវតាដែលមាននាទីខាងមើលថែរក្សានូវមនុស្សលោកនោះដែរ ។ ទេវតាដែលនៅចាំមើលថែរក្សាមនុស្សលោកនោះ អាចនៅមានខ្វះចន្លោះ មិនគ្រប់ជ្រុងជ្រោយដូចជានាង **មេខលា** ដែលមាននាទីចាំយាមរក្សានូវផ្ទៃមហាសមុទ្រ ដោយមិនឱ្យមនុស្សណាដែលមាននូវធមិកតញ្ញូកតវេទី ១ មាននូវសីលបរិសុទ្ធ ១ មាននូវអាជីព គឺ ការចិញ្ចឹមជីវិតបរិសុទ្ធ ១ លង់ស្លាប់នៅក្នុងផ្ទៃនៃទឹកមហាសមុទ្រនោះបានឡើយ ។ ស្រាប់តែនៅសម័យថ្ងៃមួយនោះ ទេវតា（នាង **មេខលា**） នោះឯងជាប់រវល់បំពេញការងារដទៃទៀត ក៏បានភ្លេចនូវតួនាទីរបស់ខ្លួន ដោយបណ្តោយទុកឱ្យព្រះ **មហាជនក** ដែលជាតួអង្គនៃព្រះពោធិសត្វ ហែលឆ្លងកាត់នូវផ្ទៃនៃទឹកមហាសមុទ្រ ដែលគ្មានកោះត្រើយនោះ អស់រយៈពេល ៧ យប់ ៧ ថ្ងៃ ទើបនាងបាននឹកឃើញថា នាងបានបោះបង់ចោលសមុទ្រអស់រយៈពេល ៧ ថ្ងៃមកហើយ ។ រួចហើយនាងក៏បានវិលត្រឡប់មកកាន់សមុទ្រនោះវិញ ហើយនាងក៏បានឃើញ**មហាជនក** កំពុងតែព្យាយាមហែលឆ្លងកាត់សមុទ្រ ដែលគ្មានកោះត្រើយនោះ នាងក៏បានចាប់បីទ្រព្រះមហាជនកនោះ ហោះតម្រង់ទៅកាន់ **មិថិលា** នគរបាត់ទៅ ។ នេះគ្រាន់តែចង់បញ្ជាក់ឱ្យឃើញថា ទេវតាដែលមាននាទីខាងមើលថែរក្សានូវមនុស្សលោកនោះ ក៏គង់មានការភ្លេចភ្លាំងដែរ ។ ប៉ុន្តែមាតាបិតាមើលថែរក្សាកូនបានសព្វពេលសព្វវេលា គ្រប់ជ្រុងជ្រោយទាំងអស់ ក្រៃលែងជាងទេវតាដែលរក្សានូវមនុស្សលោកទៅទៀត ។ ដូច្នេះហើយបានជាលោកឱ្យឈ្មោះមាតាបិតាថាជា **បុព្វទេវា** ទេវតាខាងដើមរបស់កូនប្រុសស្រីទាំងឡាយ ។

ម្យ៉ាងវិញទៀត កូនប្រុសស្រីទាំងឡាយដែលអាចស្គាល់ទេវតាផ្សេងៗដទៃទៀតបាន ក៏ដោយសារអំណាចនៃមាតាបិតានោះជាមុនដែរ ។ ដូច្នេះហើយ បានជាមាតាបិតាមានឈ្មោះថា

**បុព្វទេវា** ទេវតាខាងដើមរបស់កូនប្រុសស្រីទាំងឡាយ ព្រោះគាត់ជាអ្នកមាននូវឧបការគុណមុនគេ ។ ចំណែកឯទេវតាផ្សេងៗទៀត មិនបានឈ្មោះថា " **បុព្វទេវា** " នោះទេ លោកគ្រាន់តែឱ្យឈ្មោះថា "**បច្ឆាទេវា**" ទេវតាខាងក្រោយបន្ទាប់បន្សំ ព្រោះជាអ្នកធ្វើនូវឧបការៈក្រោយ ជាអ្នក គឺកូនប្រុសស្រីទាំងឡាយស្គាល់ក្រោយ ។

**៣ / មាតាបិតាជាបុព្វាចារ្យរបស់កូនប្រុសស្រី :** ពាក្យថា **បុព្វាចារ្យ = ( បុព្វ + អាចារ្យ )**

**បុព្វ :** ប្រែថា ខាងដើម មុន

**អាចារ្យ :** ប្រែថា គ្រូ អ្នកបង្រៀនចំណេះដឹងដល់គេ អ្នកដែលប្រព្រឹត្តល្អត្រឹមត្រូវ អ្នកដែលសិស្សត្រូវគោរពជាដើម ។មាតាបិតាជាគ្រូដើមរបស់កូនប្រុសស្រី ព្រោះគាត់ជាអ្នកញ៉ាំងកូនឱ្យបានសិក្សារៀនសូត្រមុនជាងគ្រូដទៃទៀតទាំងអស់ ។ ចាប់តាំងពីពេលដែលកូនបានកើតមក មាតាបិតាទាំងពីរនាក់បានយកចិត្តទុកដាក់បង្រៀនកូន ឱ្យកូនរៀនស្គាល់របស់ណាដែលគួរស្គាល់ ឱ្យកូនរៀនដឹងរបស់ណាដែលគួរដឹង និង ឱ្យកូនរៀនវិជ្ជាណាដែលគួររៀនជាដើម ។ មាតាបិតាបង្រៀនកូន ឱ្យចេះនិយាយ ចេះដើរ ចេះឈរ ចេះអង្គុយ ចេះស្គាល់ចាស់ទុំជាដើម ។ ពួកគាត់បង្រៀនកូនមុនជាងនរណាៗទាំងអស់ ព្រោះថា គាត់ទាំងពីរនាក់នៅជិតក្បែរកើយនឹងកូនជាងគេ ។ បន្ទាប់មកមាតាបិតាញ៉ាំងកូនឱ្យទៅសិក្សារៀនសូត្រនៅតាមសាលា ពោលគឺ មាតាបិតាជាអ្នកបញ្ជូនកូន ឱ្យបានរៀនលេខនព្វន្ត រៀនអក្សរជាដើម ជាមួយនឹងលោកគ្រូអ្នកគ្រូក្នុងកាលជាខាងក្រោយ ។ កូនដែលបានចេះដឹងមកដល់សព្វថ្ងៃនេះ ដោយសារតែមានគ្រូអាចារ្យ ជាអ្នកបង្ហឹកបង្ហាត់បង្រៀនឱ្យកូនចេះលេខចេះអក្សរវិជ្ជាការផ្សេងៗក៏ពិតមែន ប៉ុន្តែក៏ព្រោះតែមានមាតាបិតាជាគ្រូដើមផងដែរ ជាអ្នកបង្រៀនឱ្យកូនចេះដឹងអំពីបញ្ហារឿងរ៉ាវផ្សេងៗ ។ មាតាបិតាដែលគាត់បង្រៀនកូន គឺគាត់បង្រៀនដោយទឹកចិត្តដ៏បរិសុទ្ធក្រៃលែង ចំពោះកូនប្រុសស្រីទាំងឡាយចង់ឱ្យកូនរបស់គាត់ចេះពិតៗ គាត់មិនមានប្រាក់ខែ មិនមានគំនិតសម្លឹងឃើញរបស់អ្វីមួយអំពីកូននោះឡើយ ។ ពួកគាត់បង្រៀនកូនតាំង

តែពីកូននៅតូច១ យើងអាចនិយាយបានថា ពួកគាត់មានបំណង
ចង់ឱ្យកូនចេះតាំងតែពីកូននៅក្នុងផ្ទៃម្ដាយមិនទាន់បានប្រសូតមក
ម៉្លេះ ។ ព្រោះថា នៅពេលខ្លះ មាតាបិតាគាត់ប្រឹងប្រែងធ្វើការងារ
ឧស្សាហ៍ព្យាយាម មិនហ៊ានខ្ជិលច្រអូសឡើយ ដោយសារតែខ្លាច
កូនដែលនៅក្នុងផ្ទៃនោះឆ្លង ឬ កាត់តាមពួកគាត់ ។ ចំណែកឯគ្រូ
ដទៃក្រៅអំពីមាតាបិតា លោកគ្រាន់តែឱ្យឈ្មោះថា " **បច្ឆាចារ្យ** "
គ្រូខាងក្រោយ បន្ទាប់បន្សំអំពីគ្រូដើម ព្រោះជាអ្នកធ្វើឧបការៈ
គុណក្រោយ ជាអ្នកបង្រៀនដល់កូនប្រុសស្រីទាំងឡាយក្នុងពេល
ជាខាងក្រោយ ។ យើងរៀននៅតាមសាលាខាងក្រៅជាមួយលោក
គ្រូអ្នកគ្រូសាស្ត្រាចារ្យជាដើម ក្រោយពេលដែលយើងរៀនចប់វគ្គ
សិក្សានីមួយ១ ចប់ឆ្នាំសិក្សានីមួយ១ ឬក៏នៅក្រោយពេលដែល
យើងបានប្រលងជាប់ យើងនឹងទទួលបាននូវសញ្ញាប័ត្រដែលបោះ
ត្រាបញ្ជាក់ដោយមន្ទីរក្រសួងអប់រំជាដើម ដើម្បីបញ្ជាក់នូវសមត្ថ-
ភាព ឬ ចំណេះដឹងរបស់យើង ។ ក្រោយពេលទទួលបានសញ្ញាប័ត្រ
នេះហើយ ប្រសិនបើយើងមានបំណងចង់ស្វែងរកការងារធ្វើ យើង
អាចយកវាទៅដើរស្វែងរកដាក់ពាក្យសុំចូលបម្រើការងារនៅតាម
អង្គការ ឬក្រុមហ៊ុននានាបានតាមសេចក្ដីត្រូវការ ។ ចំណែកឯយើង
រៀនជាមួយគ្រូដើមពោលគឺមាតាបិតារបស់យើងវិញ មិនមានថ្ងៃ
ចប់នោះទេ ហើយក៏មិនទទួលបាននូវសញ្ញាប័ត្រ ដែលបោះត្រា
បញ្ជាក់ពីក្រសួងអប់រំនោះដែរ ។ ប៉ុន្តែយើងនឹងទទួលបាននូវសញ្ញា
ឃើញដែលបោះត្រាបញ្ជាក់អំពីមហាជនជាច្រើននាក់គ្រប់មជ្ឈដ្ឋាន
ថា យើងជាកូនល្អ ជាប្រជាពលរដ្ឋល្អ ជាមនុស្សល្អ ជាមិត្តភក្ដិល្អ
ជាដើម ទៅណាមកណា គេស្រឡាញ់ចូលចិត្ត គេចង់រាប់អាន ។
សញ្ញាឃើញដែលបោះត្រាបញ្ជាក់អំពីមហាជននេះ មានតម្លៃខ្លាំង
ណាស់ ព្រោះយើងអាចយកវាទៅស្វែងរកការងារធ្វើនៅទីកន្លែង
ណា ទៅរស់នៅតាមទីកន្លែងណា ក៏គេទទួលស្គាល់ដែរ ។ មាតា
បិតាបង្រៀនកូនគ្មានថ្ងៃបញ្ចប់ បង្រៀនដោយទឹកចិត្តដ៏បរិសុទ្ធ
គ្មានទាមទារប្រយោជន៍ ឬក៏ ការតបស្នងសងគុណអ្វីអំពីកូននោះ
ឡើយ ។ ព្រោះហេតុដូចបានពោលមកនេះហើយ បានជាលោកឱ្យ
ឈ្មោះថា មាតាបិតា គឺ ជាគ្រូដើមបង្អស់របស់កូនប្រុសស្រីទាំង

ឡាយ ។

**៤ / មាតាបិតាជាអាហុនេយ្យបុគ្គលរបស់កូនប្រុសស្រីទាំងឡាយៈ** ពាក្យថា " **អាហុនេយ្យបុគ្គល** " មានន័យថា "បុគ្គលដែលសមគួរឱ្យយើងគោរពឱ្យយើងបូជា ឬបុគ្គលដែលសមគួរនឹងទទួលយកនូវការគោរពបូជាអំពីសំណាក់បុគ្គលដទៃ។ ការគោរពគឺយើងត្រូវគោរពទៅដោយកាយ គោរពទៅដោយវាចា និងគោរពទៅដោយចិត្ត ។ គោរពទៅដោយកាយពោលគឺ អវយវៈតូចធំទាំងប៉ុន្មានមានដៃពីរ ជើងពីរ និងក្បាលមួយជាដើម។ យើងត្រូវចេះឱនលំទោន ចេះលើកដៃសំពះ និង ចេះក្រាបថ្វាយបង្គំមាតាបិតាប៉ុណ្ណេះជាដើម លោកឱ្យឈ្មោះថាគោរពទៅតាមផ្លូវកាយ ។គោរពទៅដោយវាចា ពោលគឺពាក្យសម្ដីដែលយើងនិយាយទៅរាល់ថ្ងៃនេះ យើងដែលជាកូនមិនត្រូវប្រើពាក្យសម្ដីមិនគប្បី មិនសមរម្យនិយាយទាំងគំរោះគំរើយ គំហកគំរាមកំហែង សម្លុតខ្លាំង១ ដាក់ពួកគាត់នោះឡើយ។ យើងត្រូវចេះប្រើពាក្យសម្ដីផ្អែមល្ហែម ទន់ភ្លន់ល្អួងលោមថ្នាក់ថ្នមលើកទឹកចិត្តពួកគាត់ប៉ុណ្ណេះជាដើម លោកឱ្យឈ្មោះថា គោរពទៅតាមផ្លូវវាចា។ គោរពទៅដោយចិត្តពោលគឺចិត្តរបស់យើងគិតឃើញតែរឿងល្អ១ ពិចារណាឃើញតែសេចក្ដីល្អពិត១ របស់មាតាបិតាសម្ដែងនូវការគោរពពេញចិត្ត ពេញថ្លើមត្រេកអរចំពោះពួកគាត់ប៉ុណ្ណេះជាដើម លោកឱ្យឈ្មោះថា គោរពទៅតាមផ្លូវចិត្ត ។ ចំណែកឯការបូជាគឺយើងត្រូវបូជាទៅដោយវត្ថុទាំងឡាយមានបាយ ទឹក នំ ចំណី ត្រីសាច់ សំពត់ខោអាវជាដើម ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ជា អាហុនេយ្យបុគ្គល របស់ទេវតានិងមនុស្សទាំងឡាយ ព្រះអង្គសមគួរជាទីបំផុត ដើម្បីទទួលយកនូវការគោរពបូជាពីសំណាក់បុគ្គលទាំងឡាយ ។ នៅក្នុងលោកនេះនិងទេវលោក មារលោក ព្រមទាំងព្រហ្មលោក គ្មានបុគ្គលណាម្នាក់ ដែលសមគួរឱ្យយើងគោរពបូជាក្រៃលែងជាងព្រះសម្មាសម្ពុទ្ធនោះឡើយ។ បុគ្គលណាម្នាក់ដែលបានគោរព បានបូជាចំពោះព្រះសម្មាសម្ពុទ្ធរមែងទទួលបាននូវផល និង អានិសង្សយ៉ាងច្រើនក្រៃលែង មិនអាចគណនាបានយ៉ាងណាមុំញ កូនប្រុសស្រីដែលបានគោរពបូជាចំពោះមាតាបិតាបង្កើតរបស់ខ្លួននោះ ក៏រមែង

ទទួលបានផល និង អានិសង្សច្រើនយ៉ាងនោះដែរ ។ មាតាបិតាលោកបានបំពេញធ្វើនូវមហាពលិកម្មដ៏ធំធេង ចំពោះកូនប្រុសស្រីទាំងឡាយដូចដែលបានពោលមកខាងដើមរួចមកហើយ។ ដូច្នេះហើយបានជាលោកពោលថា មាតាបិតាគឺជា **អាហុនេយ្យបុគ្គល** របស់កូនប្រុសស្រីគ្រប់រូប ។ មាតាបិតាគ្រប់រូបដែលបានចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសស្រី រមែងបាននូវឈ្មោះគ្រប់ទាំង៤ យ៉ាង ដូចដែលបានពោលពណ៌នាមកនោះឯង ។ សមដូចមានព្រះពុទ្ធដីកាមួយកន្លែងដែលទ្រង់ត្រាស់សម្តែងទុកមក នៅក្នុងសព្រហ្មកសូត្រ ត្រង់ តិកនិបាត និងចតុក្កនិបាត អង្គុត្តរនិកាយថា :

**ព្រហ្មាតិ ភិក្ខវេ មាតាបិតូនមេតំ អធិវចនំ បុព្វទេវាតិ បុព្វ-ចរិយាតិ អាហុនេយ្យាតិ ភិក្ខវេ មាតាបិតូនមេតំ អធិវចនំ ។ តំ កិស្ស ហេតុ ។ ពហុការា ភិក្ខវេ មាតាបិតរោ បុត្តានំ អា-បាទកា បោសកា ឥមស្ស លោកស្ស ទស្សេតារោ ។** *ប្រែថា* "ម្នាលភិក្ខុទាំងឡាយពាក្យថា "ព្រហ្ម" នុ៎ះ ជាឈ្មោះរបស់មាតាបិតា ពាក្យថា "បុព្វទេវា.........ពាក្យថា"បុព្វាចារ្យ.........ពាក្យថា" អាហុនេយ្យបុគ្គល" នុ៎ះ ជាឈ្មោះរបស់មាតាបិតា។ សេចក្តីនោះព្រោះហេតុដូចម្តេច ? ម្នាលភិក្ខុទាំងឡាយព្រោះថា មាតាបិតាជាអ្នកមាននូវឧបការៈច្រើន បីបាច់ថែរក្សាចិញ្ចឹមកូន ជាអ្នកឱ្យកូនបានឃើញនូវលោកនេះ ។/

# សុភាសិត

រដូវភ្ជុំបិណ្ឌតែងតែទៅវត្ត ទោះជាក្រខ្សត់ក៏ឥតហ៊ានខាន
ទោះបាយមួយវែកសម្លមួយចាន ទៅវត្តឥតខានព្រោះខ្លាចញាតិជេរ ។
ឧទ្ទិសឱ្យប្រេតប្រុងខ្លួនផងទៅ កុំឱ្យធ្លាក់ផ្លូវទៅប្រេតដូចគេ
ស្លាប់ទៅជាប្រេតពុំអាចដឹងទេ តែខ្លាចជាងគេគឺប្រេតទាំងរស់ ។/

# បុរាណភាសិត

ច្រវាក់និងគុកចោរអ្នកបង្កើត ឱសថល្អឆើតកើតពីរោគ
ដំណោកកើតពីការងុយងោក សត្វលោកកើតពីកម្មតាក់តែង ។/

# មាតាបិតាមានគុណ៤យ៉ាង

ពាក្យថា " គុណ " ជាភាសាបាលី ដែលមានន័យជាភាសាខ្មែរថា "សេចក្តីល្អ សេចក្តីចម្រើនរុងរឿង" ។ ដូច្នេះ មាតាបិតាដែលមានគុណចំពោះកូនប្រុសស្រីទាំងឡាយ គឺ ពួកគាត់មាននូវសេចក្តីល្អ សេចក្តីចម្រើននេះឯង ។ បើនិយាយពីសេចក្តីល្អរបស់មាតាបិតាដែលមានចំពោះកូនប្រុសស្រីនោះ គឺ មានចំនួនច្រើនណាស់ គ្មានបុគ្គលណាម្នាក់អាចរាប់អាចកំណត់បានឡើយ។ មួយថ្ងៃ ៗ មាតាបិតាធ្វើសេចក្តីល្អពោលគឺគុណរាប់មិនអស់ ចំពោះកូនប្រុសស្រីទាំងឡាយ គ្មានកូនប្រុសស្រីណាម្នាក់អាចរៀបរាប់គុណមាតាបិតាឱ្យអស់បានឡើយ។ មាតាបិតាមានគុណច្រើនលើសលប់ច្រើនរកអ្វីផ្ទឹមគ្មាន សមដូចពាក្យចាស់បុរាណបានពោលទុកមកថា

ម៉ែឪមានគុណ ធ្ងន់អើយសែនធ្ងន់ ធ្ងន់ជាងធរណី
គ្មានអ្វីនឹងសង គុណលោកទាំងពីរ មាសប៉ុនគិរី
ថ្លៃពុំស្មើហោង ។

បើដូច្នេះ មាតាបិតាមានគុណធ្ងន់ណាស់ សូម្បីតែព្រះធរណីពោល គឺភពផែនដី ដែលជារបស់មានទម្ងន់លើសរបស់អ្វី ៗ ក៏គង់នៅចាញ់គុណមាតាបិតាដែរ។ របស់គ្រប់យ៉ាងនៅលើផែនដីនេះដូចជាផ្ទះសំបែង ព្រៃឈើ និងភ្នំជាដើម ជារបស់មានទម្ងន់ធ្ងន់ណាស់ តែទោះជាធ្ងន់យ៉ាងណា ក៏នៅតែចាញ់ទម្ងន់នៃភពផែនដីនេះដែរ ។ សេចក្តីថា បើរបស់ទាំងអស់នោះធ្ងន់ជាងផែនដីនោះ គឺផែនដីមិនអាចទ្រនូវរបស់ទាំងអស់នោះបានឡើយ ឬថា របស់ទាំងអស់នោះមិនអាចតាំងនៅ ឋិតនៅ លើផែនដីនេះបានឡើយ ព្រោះវាធ្ងន់ជាងផែនដីទៅហើយ ។ របស់ទាំងអស់នោះធ្ងន់យ៉ាងណា ក៏នៅតែមិនដល់ផែនដី ផែនដីធ្ងន់យ៉ាងណា ក៏នៅតែមិនដល់គុណមាតាបិតាដែរ ។ យើងអាចនិយាយបានថា គុណមាតាបិតាធ្ងន់ជាងគេ បន្ទាប់មកផែនដី បន្ទាប់មកទៀតរបស់អ្វីៗគ្រប់យ៉ាងនៅលើផែនដី ។ ***សំនួរៈ*** របស់អ្វីៗគ្រប់យ៉ាងដែលនៅលើផែនដីនេះ ទោះបីជាធ្ងន់យ៉ាងណាក៏ដោយ ក៏នៅតែមិនអាចធ្ងន់ជាងផែនដីបានដែរ ព្រោះផែនដីមិនអាចទ្រទ្រង់របស់អ្វីដែលធ្ងន់ជាងខ្លួនវា

បានឡើយ ចុះហេតុអ្វីបានជាមាតាបិតាមានគុណធ្ងន់ជាងផែនដីហើយ គាត់នៅតែអាចរស់នៅបាន ឬ ហេតុអ្វីបានជាផែនដីនៅតែអាចទ្រទ្រង់គុណមាតាបិតាដែលធ្ងន់ជាងវាបាន ? ***ចម្លើយ :*** បានជាផែនដីនៅតែអាចទ្រគុណមាតាបិតា ដែលមានទម្ងន់ធ្ងន់ជាងខ្លួនវាបាននោះ ព្រោះគុណមាតាបិតាជានាមធម៌ ជាសភាវៈមានតែឈ្មោះ គ្មានរូបរាង។ គុណគឺសេចក្តីល្អនេះ ជាគុណធម៌ ជាសច្ចធម៌ ជាសភាវៈធម៌ដ៏ល្អពិតៗ ដ៏បរិសុទ្ធថ្លៃថ្លា ដែលមាននៅក្នុងចិត្តក្នុងសន្តាននៃមាតាបិតាគ្រប់រូប។ នៅក្នុងខ្លួនយើងម្នាក់ៗ កាលណាបើមានគុណគឺសេចក្តីល្អនេះកាន់តែច្រើនរឹតតែល្អ គ្មានកំណត់ចំនួនប៉ុណ្ណេះប៉ុណ្ណោះឡើយ ឬក៏ ខ្លាចក្រែងច្រើនពេកធ្ងន់ទ្រមិនរួចនោះក៏ទេដែរ ។ម្យ៉ាងវិញទៀត គុណមាតាបិតានេះមានតម្លៃខ្លាំងណាស់ សូម្បីតែមាសប៉ុនគីរីទៅហើយ ក៏នៅថ្លៃចាញ់ដែរ ។ពាក្យថា" **គីរី** " លោកប្រែថា "**ភ្នំ** " ចំណែកឯមាសជារបស់មានតម្លៃណាស់ ប៉ុន្តែយើងយកមាសទៅគរជាគំនរឱ្យបានច្រើនធំហើយខ្ពស់ប៉ុនភ្នំ ក៏នៅតែមានតម្លៃមិនស្មើនឹងគុណមាតាបិតាដែរ ។ ប៉ុន្តែនៅមានអ្នកខ្លះ

ទៀតយល់ថា មាតាមានគុណត្រឹមតែ ១២ ចំណែកឯបិតាមានគុណត្រឹមតែ ២១ ប៉ុណ្ណោះ។ ដូច្នេះហើយ ប្រសិនបើគេមានកូនប្រុស ពេលកូនប្រុសនោះមានអាយុបាន ១២ ឆ្នាំ គេឱ្យបួសជាសាមណេរសងគុណម្តាយ ដល់ពេលកូននោះមានអាយុ២១ឆ្នាំ គេឱ្យបួសជាភិក្ខុសងគុណឪពុក។ គិតទៅគួរឱ្យអាណិតមាតាបិតាខ្លាំងណាស់ខំចិញ្ចឹមកូនហត់ពន់ប្រមាណ នៅទីបំផុតមាតាទទួលបានគុណត្រឹមតែ១២ ចំណែកឯបិតាគ្រាន់បើជាងមាតាបន្តិចទទួលបានគុណរហូតដល់ ២១។ ប្រសិនបើមាតាបិតាមានគុណ ១២ និង ២១ មែននោះ កូនប្រុសស្រីទាំងឡាយមិនចាំបាច់ពិបាកនៅក្នុងការតបស្នងសងគុណមាតាបិតានោះឡើយ គ្រាន់តែយើងធ្វើនូវសេចក្តីល្អមួយថ្ងៃពីរថ្ងៃឱ្យបានគ្រប់ចំនួន១២ ដង ឬ ២១ដងទៅ វារួចគ្នាបាត់ទៅហើយ។ ប៉ុន្តែមិនមែនដូច្នោះទេ មាតាបិតាមានគុណច្រើនរាប់មិនបានប្រមាណមិនអស់ ហើយកូនប្រុសស្រីទាំងឡាយក៏មិនអាចនឹងតបស្នងសងគុណមាតាបិតាឱ្យរួចបានដែរ ។ សមដូចព្រះពុទ្ធដីកា ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងទុកមកនៅក្នុង

ព្រះសូត្រមួយកន្លែងដែលមានឈ្មោះថា មាតាបិតុគុណសូត្រ ដែលមានមកនៅក្នុងគម្ពីរអង្គុត្តរនិកាយត្រង់ទុកនិបាតថា :

**ទ្វិន្នាហំ ភិក្ខវេ ន សុប្បដិការំ វទាមិ ។ កតមេសំ ទ្វិន្នំ ។ មាតុ ច បិតុ ច ។ ឯកេន ភិក្ខវេ អំសេន មាតរំ បរិហរេយ្យ ឯកេន អំសេន បិតរំ បរិហរេយ្យ វស្សសតាយុកោ វស្សសតជីវី សោ ច នេសំ ឧច្ឆាទនបរិមទ្ទនន្ហាបនសម្ពាហនេន តេ ច តត្ថេវ មុត្តករីសំ ចជេយ្យុំ ន ត្វេវ ភិក្ខវេ មាតាបិតូនំ កតំ វា ហោតិ បដិកតំ វា ។** *ប្រែថា* " ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កុលបុត្រមិនងាយនឹងធ្វើការតបគុណដល់បុគ្គលពីរពួកបានឡើយ ។ បុគ្គលពីរពួកនោះ តើបានដល់នរណាខ្លះ ? ។ បានដល់មាតា ១ បិតា ១ ។ ម្នាលភិក្ខុទាំងឡាយបុត្រមានអាយុ ១០០ ឆ្នាំ រស់នៅអស់១០០ឆ្នាំ គប្បីបញ្ជិះមាតាដោយស្មាម្ខាង បញ្ជិះបិតាដោយស្មាម្ខាង ហើយបុត្រនោះគប្បីបម្រើមាតាបិតាទាំងពីរនាក់នោះដោយការដុសជម្រះបំបាត់ក្លិនអាក្រក់ រឹតអង្អែលដៃ ផ្ងូតទឹក គក់ច្របាច់ដៃជើង ឯមាតានិងបិតាទាំងពីរនាក់នោះ ក៏គប្បីបន្ទោរបង់នូវមូត្រនិងលាមកដាក់លើស្មានៃបុត្រនោះឯង , ម្នាលភិក្ខុទាំងឡាយហេតុមានប្រមាណប៉ុណ្ណេះ គង់មិនទាន់ហៅថា បុត្រធ្វើតបដល់មាតាបិតាបានឡើយ ។

សង្ខេបមកវិញគុណរបស់មាតាបិតាលោកអ្នកប្រាជ្ញទាំងឡាយឱ្យឈ្មោះ ៤ យ៉ាងទៅតាម អត្ថន័យគឺ :

១ / **អនន្តគុណ** : គុណគ្មានទីបំផុត

២ / **អនេកប្បគុណ** : គុណច្រើនជាអនេក

៣ / **អសមគុណ** : គុណគ្មានអ្វីប្រៀបស្មើ

៤ / **អបរិមាណគុណ** : គុណប្រមាណមិនបាន ។

# សេចក្តីអធិប្បាយ

**១ / អនន្តគុណ :** គុណគ្មានទីបំផុត ។ បានសេចក្តីថា គុណមាតាបិតាវែងឆ្ងាយណាស់ គ្មានបុគ្គលណាម្នាក់អាចរកឃើញថាមានប្រវែងចម្ងាយនេះចម្ងាយនោះបានឡើយ ។សម័យសព្វថ្ងៃនេះ

វិទ្យាសាស្ត្រគេជឿនលឿនខ្លាំងណាស់ សូម្បីតែភពផែនដីទាំងមូល ឬក៏ប្រទេសនីមួយៗដែលនៅលើពិភពលោកនេះ មានឧទាហរណ៍ ដូចជាប្រទេសកម្ពុជាយើងជាដើម អ្នកប្រាជ្ញរកឃើញថា មានផ្ទៃដី ចំនួន ១៨១.០៣៥ គ.ម$^{២}$ មានទទឹងពីជើងទៅត្បូងប្រវែង ៤៤០ គ.ម និង មានបណ្តោយពីលិចទៅកើតប្រវែង ២៦០០ គ.ម ដែលមានរាងជាពហុកោណស្ទើរស្មើជ្រុង ។ មិនត្រឹមតែភពផែនដី នេះទេ សូម្បីភពដទៃទៀតផ្សេងៗទៀតជាច្រើន ក៏គេអាចរកឃើញបាន ដែរ។ ចំណែកឯគុណមាតាបិតាវិញនោះ គ្មានបុគ្គលណាម្នាក់អាច រកឃើញថា មានព្រំដែនព្រំប្រទល់ត្រឹមណេះ មានទទឹងប្រវែង ប៉ុណ្ណេះ មានបណ្តោយប្រវែងប៉ុណ្ណោះបានឡើយ ។ សូម្បីតែព្រះ សម្មាសម្ពុទ្ធដែលព្រះអង្គជាកំពូលនៃអ្នកប្រាជ្ញទាំងឡាយ ទ្រង់ជា អគ្គបុគ្គលជាបុគ្គលឯកនៅលើលោកនេះ ទ្រង់ជាអ្នកត្រាស់ដឹងសព្វ ត្រាស់ដឹងគ្រប់គ្មានខ្វះចន្លោះសល់ត្រង់ណានោះ ព្រះអង្គទ្រង់បាន ត្រាស់សម្តែងអំពីបញ្ហាគុណមាតាបិតានេះដែរថា សូម្បីតែតថាគត ក៏ពិចារណារកមើលមិនឃើញថា គុណមាតាបិតានេះ មានទីបំផុត

ត្រឹមណាដែរ ។ ***សំនួរ :*** គួរឱ្យឆ្ងល់ខ្លាំងណាស់ ព្រះសម្មាសម្ពុទ្ធទ្រង់ ជាអ្នកត្រាស់ដឹងសព្វគ្រប់ ចុះហេតុអ្វីក៏បានជាព្រះអង្គទ្រង់នៅតែ ពិចារណារកមើលមិនឃើញថា គុណមាតាបិតាមានទីបំផុតត្រឹម ណា ? ***ចម្លើយ :*** បានជាព្រះសម្មាសម្ពុទ្ធទ្រង់ពិចារណារកមើលមិន ឃើញថា គុណមាតាបិតានេះមានទីបំផុតត្រឹមណានោះ ព្រោះ គុណរបស់មាតាបិតាគ្មានទីបំផុតទៅហើយ តើឱ្យព្រះអង្គទ្រង់ ពិចារណារកឱ្យឃើញទីបំផុតដូចម្តេចកើត ? របស់ទាំងឡាយណា ដែលវាគ្មានទៅហើយ ទោះបីជាមានអ្នកពូកែរកយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចរកឃើញបានដែរ ឧទាហរណ៍ដូចជាកាំភ្លើងដែល វាគ្មានគ្រាប់ស្រាប់ទោះបីជាបុគ្គលអ្នកកាន់កាំភ្លើងនោះជាជើងឯក លេខមួយខាងបាញ់កាំភ្លើងក៏ដោយជាអ្នកស្ទាត់ជំនាញក្នុងការបាញ់ កាំភ្លើងយ៉ាងណាក៏ដោយ ក៏បុគ្គលនោះនៅតែមិនអាចដើម្បីបាញ់ កាំភ្លើងនោះឱ្យផ្ទុះបានដែរ សេចក្តីនេះមានឧបមាយ៉ាងណា គុណ របស់មាតាបិតាដែលគ្មានទីបំផុតនោះ ក៏មានឧបមេយ្យយ៉ាងនោះ ដែរ ។ប៉ុន្តែព្រះសម្មាសម្ពុទ្ធព្រះអង្គប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ

ព្រះអង្គជាកំពូលនៃអ្នកប្រាជ្ញទាំងឡាយ ព្រោះទ្រង់ពិចារណារកឃើញទៅតាមសភាវៈពិត (សច្ចធម៌) ថា គុណមាតាបិតាមិនមានទីបំផុត ហើយព្រះអង្គទ្រង់បានប្រកាសប្រាប់ដល់មនុស្សសត្វទាំងឡាយថា គុណមាតាបិតានេះឯងឱ្យឈ្មោះថា **អនន្តគុណ** គឺគុណដែលគ្មានទីបំផុត ។

**២ / អនេកប្បគុណ :** គុណច្រើនជាអនេក ។ ពាក្យថា **អនេក** ( **ន + ឯក** ) បានសេចក្តីថា ចំនួនមិនមែនមួយ ចំនួនខុសពីមួយ ចំនួនច្រើនជាងមួយ ។ គុណរបស់មាតាបិតានេះមានច្រើនជាអនេក ច្រើនហួសពីការស្មាន ច្រើនហួសគណនា ច្រើនលើសលប់ជាដើម ។

**៣ / អសមគុណ :** គុណគ្មានអ្វីប្រៀបស្មើ ។ បានសេចក្តីថា គុណមាតាបិតាមានចំនួនច្រើនពេកមិនអាចយករបស់អ្វីមួយដូចជាភ្នំដូចជាទឹកក្នុងមហាសមុទ្រទាំង ៤ ឬដូចជាសម្ភារៈប្រើប្រាស់គ្រប់យ៉ាង ដែលមាននៅលើលោកយើងនេះ មកប្រៀបផ្ទឹមឱ្យស្មើ ឬឱ្យច្រើនលើសជាងគុណមាតាបិតាបានឡើយ ។

**៤ / អបរិមាណគុណ :** គុណប្រមាណមិនបាន ។ បានសេចក្តីថា គុណគឺសេចក្តីល្អរបស់មាតាបិតា ដែលគាត់បានធ្វើទៅលើកូនប្រុសស្រីគ្រប់គ្នានោះជាអបរិមាណគុណ ជាគុណដែលប្រមាណមិនបាន ។ យើងមិនអាចប្រមាណគុណមាតាបិតាថា មានតម្លៃប៉ុណ្ណេះ មានទំហំប៉ុណ្ណេះ មានទម្ងន់ប៉ុណ្ណេះ មានរូបរាងយ៉ាងនេះ ជាដើមបានឡើយ ។

សរុបសេចក្តីមកវិញ គុណមាតាបិតាដែលមានឈ្មោះទាំង ៤ យ៉ាងនេះ ក៏មានន័យគ្រប់គ្រាន់គ្របដណ្តប់ទៅលើអត្ថន័យនៃពាក្យថា **គុណរបស់មាតាបិតា** អាចល្មមស្តាប់បានហើយ ។ គុណមាតាបិតាទោះបីជាហៅឈ្មោះ ៤ យ៉ាងនេះក្តី មិនហៅឈ្មោះ ៤ យ៉ាងនេះក្តី ក៏នៅតែមានន័យថា គុណដែលមានចំនួនច្រើនលើសលប់ដដែល ។/

## បុរាណភាសិត

គល់ឈើបៀមទឹកឆាប់ពុក មនុស្សបៀមទុក្ខឆាប់ស្លាប់ ។/

# មរតករបស់មាតាបិតា៣យ៉ាង

ពាក្យថា " **មរតក** "បានសេចក្ដីថា "ទ្រព្យសម្បត្តិ ឬក៏អ្វីៗ ដទៃទៀតជារបស់បុគ្គលដែលស្លាប់ទៅហើយ"។ ពាក្យថា "**មរតករបស់មាតាបិតា** " មានសេចក្ដីថា អ្វីៗដែលសល់អំពីមាតាបិតា ឬ អ្វីៗដែលមាតាបិតាបន្សល់ទុកឱ្យកូនប្រុសស្រី ។ កូនប្រុសស្រីគ្រប់រូបគប្បីជាអ្នកប្រព្រឹត្តធ្វើខ្លួនឱ្យសមគួរ ដើម្បីទទួលយកនូវមរតករបស់មាតាបិតា។ ព្រោះថាមរតករបស់មាតាបិតា សូម្បីមានចំនួនតិចតួចក៏ដោយ ក៏វាមានតម្លៃជាទីបំផុត ព្រោះវាជាទឹកចិត្តដ៏បរិសុទ្ធ ជាញើសឈាមរបស់ពួកគាត់ ។ មរតករួមមានទាំងទ្រព្យសម្បត្តិទាំងឱវាទជាពាក្យទូន្មានប្រៀនប្រដៅរបស់មាតាបិតាដែលគាត់បានបន្សល់ទុកមកឱ្យយើងដែលជាកូននេះឯង ។ កូនប្រុសស្រីទាំងឡាយកុំគប្បីឱ្យតម្លៃទៅលើតែទ្រព្យសម្បត្តិថា ជាមរតកតែម្យ៉ាង ចំណែកឯពាក្យទូន្មានប្រៀនប្រដៅដែលមាតាបិតាបានខិតខំពន្យល់ណែនាំអប់រំកូនយ៉ាងណា យើងមិនឱ្យឈ្មោះថា ជាមរតក នោះ ការឱ្យតម្លៃយ៉ាងនេះមិនត្រឹមត្រូវនោះទេ ។ ដូចជាព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់បានបន្សល់នូវមរតក ទុកសម្រាប់ចែកឱ្យសត្វលោក។ តើព្រះអង្គទ្រង់បានបន្សល់នូវមរតកអ្វីខ្លះទុកសម្រាប់ចែកឱ្យសត្វលោក ? ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សម្ដែងនូវព្រះធម៌អស់រយៈកាល ៤៥ ព្រះវស្សា ហើយទ្រង់បានបន្សល់នូវ**ព្រះធម្មមរតក** ពោលគឺព្រះធម៌ជាពាក្យឱវាទទូន្មានប្រៀនប្រដៅទុកសម្រាប់ចែកឱ្យសត្វលោក។ មរតករបស់មាតាបិតាមានច្រើនបែបច្រើនយ៉ាងណាស់ ប៉ុន្តែបើនិយាយអំពីមរតក ដែលសំខាន់ៗមាន ៣ យ៉ាងគឺៈ

**១ / មរតក គឺ អាយុជីវិត**

**២ / មរតក គឺ ទ្រព្យសម្បត្តិ**

**៣ / មរតក គឺ ឱវាទពាក្យទូន្មានប្រៀនប្រដៅរបស់មាតាបិតា ។**

## សេចក្ដីអធិប្បាយ

**១ / មរតកគឺអាយុជីវិត :** ដែលមាតាបិតាបានប្រគល់មកឱ្យដែលជាកូនហ្នឹងឯង ។ សូម្បីតែរូបរាងកាយពោលគឺសាច់ឈាមសរសៃឆ្អឹងរបស់យើងទាំងប៉ុន្មាននេះក៏បានរាប់បញ្ចូលថា ជាមរតករបស់មាតាបិតា ដែលគាត់បានបន្សល់ទុកមកឱ្យយើងដែលជាកូនផងដែរ។ ព្រោះហេតុអ្វី ? ព្រោះថាមាតាបិតាទាំងពីរនាក់នេះបានរួមគ្នាចិញ្ចឹមបីបាច់ថែរក្សាកូនដោយស្នេហ៍គ្រស្នេហ៍ ។ ពេលអ្នកម្ដាយកំពុងតែពពោះនៅឡើយ ឪពុកបានខិតខំធ្វើការរកស៊ីព្រឹកល្ងាចដើម្បីសន្សំលុយកាក់ទ្រព្យសម្បត្តិយកមកចិញ្ចឹមភរិយា ហើយអាហារជារបស់បិតាដែលខិតខំរកស៊ីហ្នឹង គួបផ្សំទៅនឹងការបរិភោគ ការព្យាយាមរបស់ម្ដាយផង អាហារក៏បានចូលទៅក្នុងផ្ទៃនៃម្ដាយរួមគ្នាចិញ្ចឹមកូនដែលនៅក្នុងផ្ទៃនោះឯង ។ ក្រោយមកទៀត មាតាបិតាចិញ្ចឹមកូនស្រឡាញ់ណាស់កូនប្រុសស្រី តាំងតែពីកូនទើបនឹងប្រសូតមកបានថ្មីៗ ពេលនោះរូបកាយរបស់កូនតូចខ្លាំងណាស់ ។ ម៉ែសុខចិត្តកាប់សម្លាប់បំបាត់ជីវិតសត្វដទៃ ដើម្បីឱ្យតែកូនបានសុខដើម្បីការពារជីវិតរបស់កូន។ មាតាបានព្យាយាមបំបៅដោះកូនជារៀងរាល់ថ្ងៃរហូតដល់កូនបានធំបន្តិច គាត់ព្យាយាមបញ្ចុកបាយទឹកនំចំណីត្រីសាច់សព្វបែបយ៉ាងឱ្យដល់កូនដើម្បីឱ្យកូនបានរស់រានមានជីវិតឱ្យរូបរាងកាយរបស់កូនបានចម្រើនធំធាត់ឡើង។ មាតាដែលអាចធ្វើយ៉ាងនេះទៅកើត ក៏អាស្រ័យដោយឪពុកជាអ្នកមានឧបការៈ ជាអ្នកចាំជួយឧបត្ថម្ភគាំទ្រផងដែរ ។ លុះដល់ពេលកូនធំពេញរូបពេញរាង ពេញកម្លោះ ពេញក្រមុំ សាច់ឈាមរបស់កូនស្រស់ស្អាតគួរឱ្យស្រឡាញ់ពេញចិត្តពេញថ្លើមយ៉ាងណាក៏ដោយ ក៏គង់តែជាចំណែកនៃសាច់ឈាមរបស់មាតាបិតាដោយពិត ។ យើងមិនអាចថា រូបរាងកាយ និងអាយុជីវិតនេះ ជារបស់យើងដាច់មុខបានទេ ព្រោះអាយុជីវិតរូបរាងកាយរបស់យើងនេះ ចម្រើនធំធាត់រស់រានទៅបានដោយសារតែអាហារ បាយ ទឹក នំចំណី របស់ម៉ែឪទាំងសាច់ទាំងឈាមរូបរាងកាយ ព្រមទាំងអាយុជីវិតរបស់កូនផងដែរ គឺពិតជារបស់មាតាបិតាដោយពិត។ ពីព្រោះគ្មានកូនណាម្នាក់ដែលអាចមានអាយុជីវិតរស់នៅបានឃើញពិភពលោកសព្វថ្ងៃនេះដោយប្រាសចាកនូវមាតាបិតានោះបានឡើយ ។ ពេលខ្លះកូនមាន

ជំងឺឈឺថ្កាត់ធ្ងន់ស្រាលយ៉ាងណា ទោះបីជាយប់ព្រលប់ដូចម្ដេចក្ដី ក៏គាត់សុខចិត្តទៅតាមហៅគ្រូពេទ្យ គ្រូខ្មែរឱ្យមកព្យាបាលកូនដើម្បីយកថ្នាំមកដុសឱ្យកូនផឹកដែរ ។ ពេលយប់ជ្រៅស្ងាត់ឱ្យសូន្យឈឹងឆ្ងាយពីផ្ទះ ពីភូមិស្រុក ដាច់ស្រយាលយ៉ាងណាក៏ដោយ ក៏គាត់ត្រូវតែទៅដែរ ។ បើសម្រាប់អ្នកដទៃវិញ គាត់ក៏មិនខ្វល់ខ្វាយដល់ថ្នាក់ហ្នឹងទេ ប៉ុន្តែសម្រាប់កូនរបស់គាត់ គាត់ត្រូវតែខ្វល់ខ្វាយដោយខានមិនបាន ព្រោះគាត់ដឹងប្រាកដថា នេះជាសាច់ជាឈាមរបស់គាត់បង្កើត ។មាតាបិតាដែលចិញ្ចឹមកូន បង្កើតកូន ហើយស្រឡាញ់កូនស្មើដោយជីវិតរបស់ខ្លួននោះ តើមកពីហេតុអ្វី ? មិនមកពីហេតុតែដឹងថា កូនហ្នឹងជាសាច់ជាឈាមបង្កើតរបស់គាត់ សមដូចសុភាសិតខ្មែរមួយកន្លែងបានពោលថា "កាត់ទឹកមិនដាច់ កាត់សាច់មិនបាន"នោះអី ។ បើសម្រាប់អ្នកដទៃវិញ គាត់អាចកាត់បានយ៉ាងណានោះ ក៏មកតែពីគាត់បានដឹងថា មិនមែនជាសាច់ឈាមបង្កើតរបស់គាត់ហ្នឹងឯង ។ ដូច្នេះអាយុជីវិតរូបរាងកាយនេះ គឺជាមរតកម្យ៉ាងសំខាន់បំផុត ដែលមាតាបិតាគ្រប់រូបតែងតែប្រគល់ឱ្យដល់កូនប្រុសស្រីទាំងឡាយ ។ កាលបើកូនប្រុសស្រីគ្រប់រូបបានថែរក្សាអាយុជីវិតរបស់យើងនេះឱ្យបានល្អប្រសើរឡើងទៅឈ្មោះថា បានថែរក្សាមរតករបស់មាតាបិតាបានមួយផ្នែកហើយ ។ កូនប្រុសស្រីគ្រប់ៗប្រាណ ត្រូវចេះស្រឡាញ់អាយុជីវិតរូបរាងកាយរបស់ខ្លួន កុំយកជីវិតរបស់យើងនេះ ទៅភ្លើតភ្លើនជាមួយនឹងអំពើអបាយមុខផ្សេងៗ ផ្ដេសផ្ដាស ដើរខុសកាលខុសវេលា ប្រព្រឹត្តអំពើខុសច្បាប់រដ្ឋច្បាប់ស្រុកទេស ត្រូវគេចាប់ចងយកទៅដាក់ខ្នោះដាក់គុកដាក់ច្រវាក់ដាក់ពន្ធនាគារ គេវាយដំច្រំធាក់ជាដើម ។ កូនខ្លះទៀតបានយកជីវិតជាមរតកដ៏មានតម្លៃ ដែលមាតាបិតាបានប្រគល់ឱ្យនេះទៅប្រព្រឹត្តធ្វើអំពើបាបកម្មផ្សេងៗ ដែលសង្គមគេស្អប់ខ្ពើមដូចជាយកជីវិតនេះទៅកាប់ទៅចាក់គ្នាវាយវាត់ទាត់ធាក់កាប់សម្លាប់គ្នាហូរឈាមសស្រាក់ មានខ្លះរហូតដល់ស្លាប់បាត់បង់ជីវិតក៏មានដែរ បង្កទៅជាកម្មពៀរវេរាវែងឆ្ងាយ សព្វបើគ្រាន់តែទាស់ពាក្យសម្ដីគ្នាបន្តិចបន្តួចចង់ឈ្នះចាញ់គ្នា ឬក៏ ថាចង់សម្ដែងនូវភាពអស្ចារ្យថាខ្លួនជាអ្នកខ្លាំងជាងគេជាដើម ។ បើយើងម្នាក់ៗធ្វើយ៉ាងនេះ តើ

យើងឈ្មោះថា ជាអ្នកស្រឡាញ់អាយុជីវិតរបស់យើងទេ ? តើយើងសមជាកូនល្អដែលស្រឡាញ់មរតករបស់មាតាបិតាទេ ? តើយើងបានឈ្មោះថា ជាកូនដែលធ្វើខ្លួនឱ្យសមគួរដើម្បីទទួលយកនូវមរតករបស់មាតាបិតាយើងទេ បើយើងប្រព្រឹត្តធ្វើខ្លួនរបស់យ៉ាងនេះនោះ ?

ដូច្នេះមរតកពោលគឺអាយុជីវិតនេះ ជាមរតកដ៏សំខាន់ដំបូងគេបង្អស់ដែលមាតាបិតាបានប្រគល់ឱ្យមកយើងដែលជាកូន យើងត្រូវចេះថែរក្សាអាយុជីវិតនេះឱ្យបានល្អ ទើបមាតាបិតាគាត់បានសប្បាយចិត្ត។ មាតាបិតាដែលគាត់សួរកូនដំបូងបង្អស់គឺសួរចង់ដឹងអំពីសុខទុក្ខរបស់កូន ទោះបីជាពួកគាត់ទៅណាមកណាជិតឆ្ងាយយ៉ាងណាក៏ដោយ ពេលបានឮដំណឹងថា កូនរបស់ខ្លួនបានសុខបានសប្បាយនោះ មាតាបិតាសប្បាយចិត្តខ្លាំងណាស់ ។ សូម្បីពួកគាត់ឱ្យពរដល់កូនមុនដំបូងបង្អស់ ក៏ឱ្យកូនរបស់ខ្លួនបានសុខសប្បាយដែរ។ ដូច្នេះរឿងដែលសំខាន់ជាងគេរបស់មាតាបិតា គឺសេចក្ដីសុខរបស់កូនៗ គាត់តែងតែយកចិត្តទុកដាក់ទៅលើតែសេចក្ដីសុខទុក្ខរបស់កូន ទោះជាគាត់ទៅដល់ទីណាក្ដី ទៅវត្តធ្វើបុណ្យឱ្យទានក្ដី ក៏តែងតែបួងសួងប្រាថ្នានឹកដល់កូនជាទីស្រលាញ់របស់ខ្លួន សុំឱ្យកូនបានសុខសប្បាយផងដែរ។ ចំណែកឯរឿងមាសប្រាក់ទ្រព្យសម្បត្តិជារឿងសំខាន់ខាងក្រោយ ប៉ុន្តែរឿងដែលសំខាន់ដំបូងបង្អស់គឺឱ្យកូនបានសុខសប្បាយជាមុនសិន ។

**២ / មរតកគឺទ្រព្យសម្បត្តិ :** ជារបស់មាតាបិតាដែលគាត់បានចែករំលែកប្រគល់ឱ្យដល់កូនប្រុសស្រី ដែលជាទីស្រលាញ់ហួងហែងរបស់គាត់គ្រប់ ៧ ប្រាណ។ មរតកគឺទ្រព្យសម្បត្តិនេះ លោកបានរាប់បញ្ចូលទាំងសវិញ្ញាណកទ្រព្យ និង អវិញ្ញាណកទ្រព្យផងដែរ ។ **សវិញ្ញាណកទ្រព្យ :** គឺទ្រព្យទាំងឡាយណាដែលមានវិញ្ញាណបានដល់ ទាសៈកម្មករ អ្នកបម្រើប្រុសស្រី ជ្រូក ក្ដាន់ លា អូដ្ឋ គោក្របី ដំរីសេះជាដើម។ **អវិញ្ញាណកទ្រព្យ :** គឺទ្រព្យទាំង-ឡាយណាដែលគ្មានវិញ្ញាណ បានដល់ដីស្រែចំការច្បារដំណាំរថយន្ត

កង់ ម៉ូតូ ស៊ិក្លូ ឡាន គ្រឿងសំណាក់អាស្រ័យ ផ្ទះសំបែងលុយកាក់ ប្រាក់ មាស កែវកង ពិទូរ្យសូរ្យកាន្តជាដើម ។មរតកពោលគឺទ្រព្យសម្បត្តិរបស់មាតាបិតាដែលគាត់បានចែកឱ្យដល់កូនជាទីស្រឡាញ់ហួងហែងរបស់គាត់ ទោះបីជាមានចំនួនតិចក្តីច្រើនក្តី ប៉ុន្តែវាក៏ជាញើសឈាមរបស់គាត់ ជាទឹកចិត្តរបស់គាត់ ដែលខំប្រឹងរកស៊ីតាំងតែពីចាប់ដៃគ្នាដំបូងករើកកឆ្នាំងមកម្ល៉េះ ។ កូនប្រុសស្រីគ្រប់រូបគួរតែសម្តែងនូវការពេញចិត្ត រីករាយ ត្រេកអរ ចំពោះមរតករបស់មាតាបិតាដែលគាត់បានបន្សល់ទុកឱ្យយើងដែលជាកូននេះ ។ទ្រព្យសម្បត្តិរបស់មាតាបិតា ទោះបីជាមានចំនួនតិចតួចក៏ដោយ យើងកុំយកទៅប្រៀបធៀបជាមួយនឹងមរតករបស់មាតាបិតាគេអ្នកដទៃដែលជាអ្នកមានឱ្យសោះ ។ យើងកុំជាកូនដែលមានសេចក្តីប្រមាថមើលងាយបន្តុះបង្អាប់មិនពេញចិត្តចំពោះមរតក ដែលមាតាបិតាបានប្រគល់ឱ្យថា មានចំនួនតិចតួចនោះឡើយ ។សម្រាប់មាតាបិតាដែលពួកគាត់ជាអ្នកក្រ ពួកគាត់មានជីវភាពខ្វះខាត គាត់ឱ្យយើងតែកង់ចាស់មួយគ្រឿង ផ្ទះចាស់មួយខ្នង ដើមឈើពីរបីដើម ឬដីភូមិស្រែចំការបន្តិចបន្តួចនោះ វាប្រសើរណាស់ទៅហើយ ។ យើងជាកូនត្រូវធ្វើខ្លួន ឱ្យសមគួរទទួលយកនូវមរតករបស់មាតាបិតា ។ យើងត្រូវចេះថែរក្សានូវមរតករបស់ពួកគាត់ឱ្យបានគង់វង្ស កុំយកមរតកគឺទ្រព្យសម្បត្តិដែលពួកគាត់បានប្រគល់មកឱ្យយើងនេះទៅលក់លេងល្បែងពាលាផ្តេសផ្តាស ប្រព្រឹត្តអំពើអបាយមុខផ្សេង ៗ មានល្បែងស្រី ល្បែងស្រា និងល្បែងភ្នាល់ ជាហេតុនាំឱ្យវិនាសខាតបង់នូវទ្រព្យសម្បត្តិលុយកាក់ជាដើម ។យើងត្រូវចេះពិចារណាមើលឱ្យឃើញនូវគុណតម្លៃនៃមរតករបស់មាតាបិតាថា ជារបស់ដ៏អស្ចារ្យក្រៃលែង ត្រូវពិចារណាថា " ទំរាំតែពួកគាត់រកបានមរតកប៉ុណ្ណេះទុកឱ្យយើង តើពួកគាត់មានសេចក្តីលំបាកហត់នឿយយ៉ាងណាទៅ ? ទំរាំតែពួកគាត់រកលុយមកទិញកង់មួយគ្រឿងឱ្យកូនជិះ

បានទៅរៀននឹងគេ តើមានការហត់នឿយយ៉ាងណាទៅ ? ទំរាំតែពួកគាត់រកលុយបានមកសម្រាប់ទិញប៊ិច សៀវភៅ គ្រឿងសិក្ខូបករណ៍ គ្រឿងសម្លៀកបំពាក់របស់របរប្រើប្រាស់ផ្សេងៗ សម្រាប់កូនៗរបស់គាត់គ្រប់គ្នានោះ តើពួកគាត់ជួបសេចក្ដីទុក្ខលំបាកយ៉ាងណាទៅ ? ទំរាំតែពួកគាត់រកស៊ីសន្សំលុយបាន ដើម្បីមកសង់ផ្ទះសំបែង សម្រាប់ឱ្យកូនៗរបស់គាត់មានទីលំនៅសម្រាប់ជ្រកកោននឹងគេ តើមាតាបិតាហត់នឿយយ៉ាងណាទៅ ? មានមាតាបិតាខ្លះគាត់សុខចិត្តឈ្លោះប្រកែកគ្នាជាមួយនឹងអ្នកដទៃ សុខចិត្តប្ដឹងផ្ដល់ឡើងតុលាការដល់ស្រុកខេត្តយ៉ាងណាក៏គាត់ព្រមដែរ ដោយហេតុថា អ្នកដទៃបន្លំបោកប្រាស់គាត់យកលុយប៉ុណ្ណេះរយ ប៉ុណ្ណេះពាន់ប៉ុណ្ណេះម៉ឺនជាដើម ឬដោយហេតុថា អ្នកដទៃបានធ្វើរបងខិតចូលដីគាត់ប៉ុណ្ណេះប៉ុណ្ណោះម៉ែត្រជាដើម ។ ប៉ុន្តែជាមួយកូនៗវិញ គាត់បានឱ្យទាំងអស់គ្មានប្ដឹងផ្ដល់ឈ្លោះទាស់អ្វីទេ ថែមទាំងពេញចិត្តនឹងប្រគល់ឱ្យទៀតផង ។ សូមឱ្យកូនប្រុសស្រីទាំងអស់គិតថា " យើងអាចរកស៊ីមានទ្រព្យសម្បត្តិបានច្រើនៗនេះ គឺអាស្រ័យមកពីមានមរតករបស់មាតាបិតាសម្រាប់ធ្វើជាដើមទុនរកស៊ីដែរ ទើបអាចមានបានមកដល់សព្វថ្ងៃនេះ " ។ អ្វីៗគ្រប់យ៉ាងនៅលើលោកនេះសុទ្ធតែមានចំណុចចាប់ផ្ដើមទាំងអស់ដូចជាភ្លើងឆេះផ្ទះ ឆេះព្រៃជាដើម ដំបូងបង្អស់គឺបណ្ដាលមកពីដុំនៃរងើកភ្លើងដ៏តូចមួយ ឬក៏អណ្ដាតភ្លើងដ៏តូចមួយ នៅទីបំផុតកាលបើមានហេតុដល់ព្រមភ្លើងនោះក៏អាចឆេះកំទេចផ្ទះ ឬព្រៃឱ្យក្លាយទៅជាធូលីផេះបានយ៉ាងណាមិញ កូនប្រុសស្រីទាំងឡាយដែលរកស៊ីមានទ្រព្យសម្បត្តិទៅបាន ក៏បណ្ដាលមកពីមានមរតករបស់មាតាបិតាសម្រាប់ធ្វើដើមទុនរកស៊ីជាចំនុចចាប់ផ្ដើមដែរ ។ សូមឱ្យកូនប្រុសស្រីទាំងឡាយពិចារណាមើលចុះថា " តើសេចក្ដីទុក្ខលំបាក ការហត់នឿយរបស់មាតាបិតាទាំងប៉ុន្មាននេះ តើដើម្បីនរណា ?មិនមែនដើម្បីតែកូនៗរបស់គាត់ទេឬ ? បើសម្រាប់គាត់ទាំងពីរនាក់ មាត់ពីរ ក្រពះពីរប៉ុណ្ណឹង មាតាបិតាគាត់មិនខំប្រឹងប្រែងព្យាយាមហត់នឿយដល់ថ្នាក់ហ្នឹងទេ" ។ ដូច្នេះហើយបានជាមាតាបិតាខ្លះ ក្រោយពេលពួកគាត់ស្លាប់ទៅបានទៅកើតក្នុងនរក ជាប្រេត ជាអសុរកាយ ជាសត្វ

តិរច្ឆាន ទៅកើតជាឆ្កែ ជាឆ្មា ជាជ្រូក ក្តាន់ មាន់ទា គោក្របី ដំរីសេះ ឬក៏បានទៅកើតក្នុងកំណើតមិនសមរម្យជាដើម ដោយសារតែបាបកម្មរកស៊ីចិញ្ចឹមកូនមែន ហើយទ្រព្យសម្បត្តិទាំងប៉ុន្មានត្រូវធ្លាក់មកលើកូនទាំងអស់ ។ រឿងទ្រព្យសម្បត្តិកេរ្តិ៍មរតករបស់មាតាបិតានេះ ទោះបីជាមានចំនួនតិចក៏ពិតមែន ប៉ុន្តែទឹកចិត្តរបស់ពួកគាត់ដែលប្រកបដោយមេត្តាករុណា សេចក្តីប្រឹងប្រែងខិតខំព្យាយាមទាំងប៉ុន្មាន វាបានបង្កប់ទៅជាមួយនឹងទ្រព្យសម្បត្តិនេះឯង ។ បើយើងប្រៀបធៀបរបស់ច្រើន ឬតិចនោះ យើងពិតជាពិចារណារកមើលគុណតម្លៃមិនឃើញនោះឡើយ ។ ដូច្នេះយើងសប្បាយរីករាយខ្លាំងណាស់ ក្នុងការទទួលយកនូវមរតកដែលពួកគាត់បានបន្សល់ទុកមកឱ្យយើង ហើយត្រូវប្រឹងប្រែងរក្សាដោយយកចិត្តទុកដាក់ទៅ នោះយើងនឹងមានឈ្មោះថា ជាកូនល្អ ជាកូនប្រកបតាមគន្លងធម៌ ហើយនៅទីបំផុតមាតាបិតាក៏បានសមតាមបំណងប្រាថ្នារបស់ខ្លួន ពួកគាត់ស្លាប់ទៅក៏បិទភ្នែកជិត ដោយសារតែយើងដែលជាកូននេះឯង ។

**៣ / មរតកគឺឱវាទពាក្យទូន្មានប្រៀនប្រដៅរបស់មាតាបិតា :** ដែលគាត់បានពន្យល់ណែនាំផ្តែផ្តាំកូនចៅយ៉ាងណា ក៏ព្រោះតែគាត់ចង់ឱ្យកូនរបស់គាត់ជាកូនល្អ ។ សូមឱ្យមាតាបិតាគ្រប់រូបដែលបានបង្កើតបុត្រមកហើយ ប្រឹងប្រែងព្យាយាមអប់រំពន្យល់ណែនាំកូនចៅតាំងពីក្មេងៗឱ្យហើយ ។មាតាបិតាត្រូវពន្យល់ណែនាំកូនឱ្យអស់ពីសមត្ថភាពទើបបាន កុំគិតឱ្យសោះថា ទូន្មានមិនបាន។ យើងត្រូវប្រឹងប្រែងអប់រំកូនឱ្យអស់ពីសមត្ថភាព កុំចេះតែបណ្តែតបណ្តោយទុកកូនឱ្យខិលខូច ឱ្យកូនក្លាយទៅជាមនុស្សអាក្រក់ ។ មាតាបិតាត្រូវទូន្មានប្រៀនប្រដៅពន្យល់ណែនាំអប់រំកូន ឱ្យឆ្ងាយចាកអំពើបាប អំពើអាក្រក់គ្រប់យ៉ាង ( **បាបា និវារេន្តិ** ) ឱ្យកូនឆ្ងាយអំពីមនុស្សបាប មនុស្សអាក្រក់ ឆ្ងាយពីបុគ្គលពាល ឆ្ងាយអំពីល្បែងភ្នាល់ទាំងឡាយនិងឆ្ងាយពីគ្រឿងស្រវឹងជាដើម ត្រូវហាមប្រាមកូន ត្រូវរវាំងឃ្លាំមើលកូនជានិច្ចថា អំពើដែលកូនកំពុងធ្វើ វាជាហេតុនាំមកនូវសេចក្តីចម្រើន ឬ សេចក្តីវិនាស។ មាតាបិតាត្រូវហាមឃាត់កូន កុំចេះតែបណ្តោយ អនុញ្ញាតឱ្យកូន ដើរលេង រាំ

ច្រៀង ស៊ីផឹក យប់ព្រលប់ខុសកាលខុសវេលា ដោយហេតុថា ជាអ្នកស្រឡាញ់កូននោះ ធ្វើយ៉ាងនេះមិនត្រឹមតែមានឈ្មោះថា មិនស្រឡាញ់កូនទេ ថែមទាំងឈ្មោះថា ជាអ្នកស្អប់កូនទៅវិញទៀតផង។ ព្រោះយើងកំពុងតែច្រានទម្លាក់កូនឱ្យទៅកាន់ទីដ៏ថោកទាបឱ្យកូនយើងធ្លាក់ទៅកាន់សង្គមមិនល្អ ទៅកាន់អបាយភូមិ ( នរកប្រេត អសុរកាយ តិរច្ឆាន) ជាដើម ឬក៏ច្រានកូនរបស់យើងហ្នឹងឱ្យទៅជាសត្រូវរបស់សង្គម ឱ្យក្លាយទៅជាមនុស្សម្នាក់ដែលសង្គមគេស្អប់ខ្ពើមដូចជាដុំលាមក គេភ័យខ្លាចដូចជាសត្វអសិរពិសយ៉ាងណា ក៏ដោយសារតែយើងជាមាតាបិតាអាណាព្យាបាលហ្នឹងដែរ ។ ដូច្នេះមាតាបិតាត្រូវតែពន្យល់ណែនាំកូន ឱ្យតម្កល់នៅក្នុងអំពើល្អនៅក្នុងអំពើជាកុសល ( **កល្យាណេ និវេសេន្តិ** ) ត្រូវឱ្យកូនប្រកបដោយគន្លងធម៌ ។ មាតាបិតាត្រូវជម្រុញកូន ត្រូវបង្រៀនបង្ហឹកបង្ហាត់កូនឱ្យចេះស្រឡាញ់អំពើល្អ ចេះឱ្យទាន ចេះធ្វើបុណ្យដាក់បាត្រព្រះសង្ឃ ចេះទៅវត្ត ចេះស្តាប់ធម៌ជាដើម ត្រូវចេះប្រើពាក្យសម្តីលួងលោមកូនរបស់យើង ឱ្យចេះទៅវត្តថ្ងៃបុណ្យក្តី ថ្ងៃសីលក្តី ត្រូវឧស្សាហ៍នាំកូនទៅវត្ត ឱ្យកូនរបស់យើងរៀនធ្វើបុណ្យឱ្យហើយ។ ពេលមកដល់វត្តអារាមត្រូវបង្រៀនកូនឱ្យចេះឱនលំទោនអបចាយនៈគោរពចាស់ព្រឹទ្ធាចារ្យត្រកូលរៀមច្បង ដឹកនាំកូនចៅឱ្យជំរាបសួរយាយ ជំរាបសួរតា អ៊ំពូ មីងមា ពេលស្តាប់ព្រះធម៌ទេសនាក៏ដោយ ត្រូវចេះហៅរកកូនមកឱ្យស្តាប់ធម៌ជាមួយយើងដែលជាម៉ែជាឪហ្នឹងដែរ។ សូមមាតាបិតាគ្រប់រូបប្រគល់នូវមរតកគឺឱវាទពាក្យទូន្មានប្រៀនប្រដៅឱ្យដល់កូនឱ្យបានគ្រប់ៗគ្នា ធ្វើឱ្យខួរក្បាលរបស់កូនជិតជាប់នូវអំពើល្អ ធ្វើឱ្យកូនរបស់យើងយល់អំពីគុណតម្លៃនៃអំពើល្អ សុជីវធម៌ សីលធម៌ គុណធម៌ ក្នុងភាពជាមនុស្ស ជាធម៌ដែលប្រព្រឹត្តទៅក្នុងជីវិតប្រចាំថ្ងៃ ។ យើងដែលជាកូនត្រូវតែសិក្សាត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់ទើបបាន។

*កាលណាបើមាតាបិតាគ្រប់រូប នៅក្នុងសមាគមស្រុកទេសយើង សុទ្ធតែបានដឹកនាំកូនឱ្យបានធ្វើយ៉ាងនេះ សុទ្ធតែបានបណ្តុះនូវពូជគឺសេចក្តីល្អក្នុងខ្លួនរបស់កូន សុទ្ធតែបានបំពេញឱ្យត្រឹមត្រូវតាមតួនាទីរបស់ខ្លួនដែលជាមាតាបិតា នោះនៅក្នុងសង្គមរបស់*

*យើងនឹងមានមនុស្សអាក្រក់មកអំពីណាបាន មានកូនអាក្រក់ដែលមិនដឹងគុណឪពុកម្តាយមកអំពីណាបាន* ។ ប៉ុន្តែនៅកន្លែងខ្លះទៀត មាតាបិតាមិនបានធ្វើយ៉ាងនេះទេ ពួកគាត់បណ្តែតបណ្តោយឱ្យកូនធ្វើតាមអំពើចិត្តរបស់ខ្លួន ពួកគាត់កាន់ជើងកូនទាំងដែលកូនរបស់ខ្លួនជាអ្នកខុស ជាអ្នកធ្វើអំពើអាក្រក់ទៀតផង ។ ជារៀងរាល់ថ្ងៃពួកគាត់គិតតែខំរកស៊ីយកលុយកាក់ ធ្វើម៉េចឱ្យតែក្លាយទៅជាអ្នកមានទៅបានហើយ ។មាតាបិតាខ្លះទៀត កូនសុំទៅវត្តស្តាប់ធម៌ សុំទៅធ្វើបុណ្យធ្វើសេចក្តីល្អ ហាមកូន រារាំងកូន ឱ្យកូននៅចាំផ្ទះជួយធ្វើការងាររបស់ខ្លួនជាដើម អត់ឱ្យកូនមកវត្តសោះ។ ផ្ទុយទៅវិញពេលមាន ធុងបាស រាំច្រៀង យប់ព្រលប់យ៉ាងណាក៏ដោយ ក៏ចេះតែអនុញ្ញាតឱ្យកូនទៅលេងសប្បាយនឹងគេដែរ ។ កាលបើយើងធ្វើយ៉ាងនេះ យើងនឹងឈ្មោះថា ជាចោរលួចប្លន់បុណ្យកុសល ប្លន់សេចក្តីល្អរបស់កូន តើយើងជាមនុស្សអាក្រក់យ៉ាងណាទៅ ? កូនយើងចង់ធ្វើសេចក្តីល្អ ចង់បំពេញសេចក្តីល្អ តែបែរជាយើងហាមឃាត់កូនមិនឱ្យធ្វើ ។ យើងនឹងមានឈ្មោះថា ជាអ្នកសម្លាប់កូនដោយផ្ទាល់ដៃ ទាំងចិត្តគំនិតកូនរបស់យើង ដែលគិតចង់ធ្វើល្អទាំងប៉ុន្មាន ក៏ត្រូវយើងដែលជាមាតាបិតាសម្លាប់ឱ្យស្លាប់នូវចិត្តគំនិតដែលល្អៗទាំងនេះអស់ ឱ្យកូនរបស់យើងស្លាប់ទាំងរស់ស្អុយទាំងស្រស់ ស្លាប់ទាំងដែលជីវិតនៅមាន។ យើងនឹងបានឈ្មោះថាជាអ្នករុញច្រាននូវកូនរបស់យើង ឱ្យចេញឆ្ងាយអំពីទីពឹងមួយដែលជាទីពឹងដ៏ប្រសើរថ្លៃថ្លា តើយើងហ្នឹងឈ្មោះថា ជាបុគ្គលអាក្រក់យ៉ាងណាទៅ ? នៅទីបំផុតកូនរបស់យើងឡើងចាង មានអំនួតពេញខ្លួន ធំលុបគុណម៉ែឪអស់រលីង ធំលែងស្តាប់មាតាបិតា ធំជាងមាតាបិតាទៅទៀត ។ ការហ្វឹកហាត់អប់រំបន្ទុំចិត្តកូនៗរបស់យើងនេះសំខាន់ខ្លាំងណាស់ ដែលក្នុងនាមជាមាតាបិតាគ្រប់រូប ត្រូវតែណែនាំកូនឱ្យហើយ កុំឱ្យសាសនាដទៃចូលមកពន្យល់យ៉ាងនេះពន្យល់យ៉ាងនោះ ឱ្យរបស់នេះ ឱ្យរបស់នោះ ហើយគេអូសទាញឱបក្រសោប សាបព្រោះនូវមនោគមវិជ្ជារបស់ពួកគេ វប្បធម៌របស់ពួកគេ ឱ្យជ្រាបចូលមកក្នុងខួរក្បាលកូនរបស់យើង។ ពួកគេបានយកកូនរបស់យើង ធ្វើជាកូនរបស់គេ ធ្វើជាសាវ័ករបស់គេជា

ដើម ។ នៅទីបំផុតកូនដែលយើងខំប្រឹងចិញ្ចឹមបីបាច់ថែរក្សាអស់ ១០ ឆ្នាំ ២០ ឆ្នាំ ដោយគ្មានគិតថ្លៃឈ្នួលប្រាក់កម្រៃមួយកាក់មួយសេនសោះនោះ ក៏បានពោលឡើងថា : ម៉ែឯងគ្មានគុណអ្វីបន្តិចសម្រាប់ខ្ញុំទេ ឪឯងគ្មានគុណអ្វីបន្តិចសម្រាប់ខ្ញុំទេ។ ស្រាប់តែអ្វីៗគ្រប់យ៉ាង ដែលយើងខំប្រឹងដើម្បីកូនត្រូវអស់រលីងទៅ ទឹកចិត្តដែលស្រឡាញ់កូន ទៅជាស្រងាកវង្វេងវង្វាន់ភ្លេចភ្លាំងស្មារតី រកនិយាយអ្វីក៏និយាយមិនចេញដែរ ។ ព្រោះហេតុនេះហើយ មាតាបិតាគ្រប់រូបត្រូវតែប្រុងប្រយ័ត្ន ត្រូវអូសទាញឱបក្រសោបកូនឱ្យមកស្តាប់ធម៌ បដិបត្តិធម៌ រៀនធម៌ ក្នុងជីវិតប្រចាំថ្ងៃឱ្យបានច្រើនកុំរុញច្រានកូនរបស់យើងឱ្យឆ្ងាយចាកអំពើល្អឱ្យសោះ ។ ដូច្នេះមរតកដែលប្រសើរជាងគេបង្អស់ ប្រសើរជាងទ្រព្យសម្បត្តិទៅទៀតនោះ គឺពាក្យទូន្មានប្រៀនប្រដៅ សីលធម៌ សុជីវធម៌ ប្រចាំថ្ងៃ ដែលមាតាបិតាគ្រប់រូប ត្រូវតែប្រគល់ឱ្យដល់កូនប្រុសស្រីឱ្យបានគ្រប់ ៗ គ្នាដោយខានមិនបាន ព្រោះជាមរតកដ៏ប្រសើរថ្លៃថ្លាទៅណាមកណា ក៏គេគោរពស្រលាញ់រាប់អាន គេលើងតម្កើងគ្រប់គ្នាដែរ ។

សរុបសេចក្តីមក មរតករបស់មាតាបិតាទាំង ៣ យ៉ាងនេះ កូនប្រុសស្រីគ្រប់រូបត្រូវតែថែរក្សាលើកតម្កើងទើបមាតាបិតាបានសប្បាយចិត្តបានសមតាមបំណងប្រាថ្នារបស់ខ្លួន ព្រោះបានឃើញកូនជាមនុស្សល្អហ្នឹងឯង ។/

## កំណាព្យ

ព្រះធម៌មិនស្តាប់ច្បាប់មិនអាន ចេះចាំនឹងមានមកពីណា
ខ្លួនឯងមិនស្វែងជោគវាសនា សង្ឃឹមទេព្តាណាជួយអាណិត ។/

## កំណាព្យ

អ្នកក្រធ្វើចោរលួចព្រោះឃ្លាន ចុះចោរអ្នកមានលួចព្រោះអ្វី
មានពិសដូចពស់រស់នាំភ័យ ស្លាប់ទៅអវិចីព្រោះតណ្ហា ។/

# បុត្រមានប្រភេទ៣យ៉ាង

ធម្មតាមាតាបិតាគ្រប់រូបនៅក្នុងលោកនេះ គ្មានមាតាបិតាណាម្នាក់ ដែលប្រាថ្នាចង់ឱ្យកូនរបស់ខ្លួនក្លាយទៅជាមនុស្សខិលខូចនោះឡើយ ។ ពួកគាត់ទាំងពីរនាក់តែងតែបួងសួងបន់ស្រន់ប្រាថ្នាសុំមានកូនមក ជាមនុស្សល្អ ជាកូនមានធម៌កតញ្ញូ ចេះដឹងគុណមាតាបិតា ចេះស្គាល់យាយតា ចាស់ទុំញាតិមិត្តជិតខាងជាដើម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កូនដែលកើតមកនោះឯង តែងមានប្រភេទលក្ខណៈខុសៗគ្នា មានចរិតឫកពាកិរិយាមារយាទផ្សេងៗគ្នា ទៅតាមអធ្យាស្រ័យរបស់ខ្លួនមកពីកំណើត។ កូនខ្លះកើតមកហើយប្រឹងប្រែងព្យាយាមសិក្សារៀនសូត្របានចេះដឹងលើកតម្កើងពូជពង្សវង្សត្រកូលរបស់ខ្លួន ឱ្យបានថ្កុំថ្កើងរុងរឿង មានកិត្តិយសកេរ្តិ៍ឈ្មោះល្បីល្បាញខ្ទរខ្ទារសុះសាយនៅក្នុងសង្គមស្រុកភូមិ ធ្វើឱ្យមាតាបិតាបានសប្បាយចិត្ត ញាតិមិត្តជិតខាងគេស្រឡាញ់ចូលចិត្តតែងពោលសសើរមិនដាច់ពីមាត់។ កូនខ្លះទៀតមិនដូច្នោះទេ កើតមកហើយធ្វើបាបមាតាបិតាឱ្យរងទឹកភ្នែក រងការឈឺចាប់មិនដែលបានសប្បាយចិត្តម្តងណាសោះ មិនគិតខិតខំប្រឹងប្រែងសិក្សារៀនសូត្រទេ គិតតែដើរលេងសេពគប់មិត្តភក្តិបង្កើតជាបក្សពួកនៅក្នុងសង្គមដើរវាយធ្វើបាប កាប់សម្លាប់ លួចប្លន់ ឆក់យកទ្រព្យសម្បត្តិអ្នកដទៃ ធ្វើឱ្យមនុស្សទាំងឡាយគេស្អប់ខ្ពើម ជេរប្រទេចផ្តាសាដោយប្រការៈផ្សេងៗ។ ពូជពង្សវង្សត្រកូល ធ្លាប់តែមានមុខមាត់មានកិត្តិយស កេរ្តិ៍ឈ្មោះពីរោះពិសា ក៏ត្រូវធ្លាក់ដុនដាបចុះដល់ចំណុចសូន្យ ដោយសារតែកូនប្រភេទនេះក៏មានមិនតិចនាក់ដែរទេ ។ ហេតុអ្វីបានជាកូនដែលកើតមកមានប្រភេទខុស ៗ គ្នាយ៉ាងនេះ ? បានជាកូនដែលកើតមកហើយមានប្រភេទខុសប្លែកពីគ្នាយ៉ាងនេះ ពីព្រោះកូនលោកចែកទៅឃើញថា មាន ៣ ប្រភេទប្លែកៗពីគ្នាគឺ :

១ / **អតិជាតបុត្ត** : បុត្រប្រសើរក្រៃលែងមានគុណធម៌ខ្ពស់ជាងមាតាបិតា ។

២ / **អនុជាតបុត្ត** : បុត្រថ្នាក់មធ្យមមានគុណធម៌ស្មើ

គ្នានឹងមាតាបិតា ។

៣ / **អវជាតបុត្ត** : បុត្រជាន់ទាបបំផុតមិនស្តាប់បង្គាប់មាតាបិតា ។

សមដូចព្រះពុទ្ធដីកា ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងបញ្ជាក់ចំពោះភិក្ខុទាំងឡាយថា :

**ភិក្ខវេ បុត្តោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អតិជាតោ អនុជាតោ អវជាតោតិ ។ កថញ្ច ភិក្ខវេ បុត្តោ អតិជាតោ អនុជាតោ អវជាតោ ហោតិ ។** *ប្រែថា* : ម្នាលភិក្ខុទាំងឡាយ បុត្រទាំងពពួកនេះឯង រមែងមានប្រាកដក្នុងលោក ។ បុត្រទាំង ៣ ពួកនោះ តើដូចម្តេចខ្លះ ?។ គឺ អតិជាតបុត្រ ១ អនុជាតបុត្រ ១ អវជាតបុត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអតិជាតបុត្រ អនុជាតបុត្រ និង អវជាតបុត្រ តើដូចម្តេច ?។

## សេចក្តីអធិប្បាយ

១ / **អតិជាតបុត្ត** : បុត្រប្រសើរក្រៃលែងមានគុណធម៌ខ្ពស់ជាងមាតាបិតា។ បុត្រប្រភេទអតិជាតបុត្រនេះ បើមានប្រាកដក្នុងក្រុមគ្រួសារណាហើយ ក្រុមគ្រួសារនោះនឹងដល់នូវសេចក្តីចម្រើនរុងរឿងមិនខានឡើយ ។ ព្រោះថា បុត្រប្រភេទនេះ ជាអ្នកមាននិស្ស័យមានវាសនាប្រសើរខ្ពង់ខ្ពស់ជាងមាតាបិតា អាចដឹកនាំអូសទាញមាតាបិតាមកកាន់ផ្លូវត្រូវបាន ។ បុត្រប្រភេទនេះឯង ចេះពន្យល់ណែនាំមាតាបិតាឱ្យឈប់ធ្វើអំពើបាប អំពើអាក្រក់ អំពើដែលមិនមែនជាហេតុនាំមកនូវសេចក្តីចម្រើនជាដើម។ ពួកគេចេះប្រើពាក្យសម្តីផ្អែមល្ហែម ទន់ភ្លន់ចំពោះមាតាបិតា ចេះឱនលំទោនសុភាពរាបសារគោរពលើកតម្កើងមាតាបិតា ទាំងក្នុងទីចំពោះមុខនិងទាំងក្នុងទីកំបាំងមុខ ចេះពន្យល់ដោយលើកយកឧទាហរណ៍ជាក់ស្តែងនឹងភ្នែកឱ្យមាតាបិតាបានយល់អំពីទោសនៃអំពើបាប ឬគុណវិបត្តិនៃអំពើអបាយមុខជាដើមថាៈ កាលណាបើយើងប្រព្រឹត្តធ្វើយ៉ាងនេះ វានាំឱ្យយើងបាត់បង់លុយកាក់មាសប្រាក់ និងទ្រព្យសម្បត្តិកិត្តិយសកេរ្តិ៍ឈ្មោះជាដើម។ រឿងទ្រព្យសម្បត្តិមាសប្រាក់លុយកាក់នេះ កាលណាបើវាបាត់បង់ទៅហើយ ឱ្យតែជីវិតយើង

នៅមាន យើងអាចប្រឹងប្រែងស្វែងរកបានមកវិញ ។ ប៉ុន្តែរឿងសុខភាពរឿងកិត្តិយសកេរ្តិ៍ឈ្មោះនេះ កាលណាបើខាតបង់ទៅហើយមិនងាយនឹងស្វះស្វែងរកមកវិញបានឡើយ ។ បាត់បង់លុយកាក់ឈ្មោះថាខាតបង់តិច បាត់បង់មាសពេជ្រឈ្មោះថារលីងដល់ទាប បាត់បង់សុខភាពឈ្មោះថាមានគ្រោះ បាត់បង់កិត្តិយសឈ្មោះថាបាត់សព្វអ្វី ៗ ។ មិនត្រឹមតែពន្យល់មាតាបិតាឱ្យបានយល់អំពីអំពើបាបឈប់ធ្វើអំពើបាបនោះទេ ថែមទាំងបានពន្យល់មាតាបិតាឱ្យបានយល់អំពីផលប្រយោជន៏នៃអំពើល្អ ញ៉ាំងមាតាបិតាឱ្យបានដល់នូវព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃជាទីពឹងជាទីរលឹកទៀតផង ។ បើមាតាបិតានៅជាមនុស្សកំណាញ់មិនចេះធ្វើទាន មិនចេះស្តាប់ធម៌ មិនទាន់មានសីលនៅក្នុងខ្លួនទេ កូនចេះដឹកនាំពន្យល់ឱ្យគាត់ចេះធ្វើទាន ចេះរក្សាសីល ទិញវិទ្យុម៉ាញ៉េជូនគាត់ ជាវកាសែតធម៌សៀវភៅធម៌ជូនគាត់ ពន្យល់ឱ្យគាត់ចេះស្តាប់ធម៌ ចេះរៀនធម៌ចេះសូត្រធម៌ជាដើម ។ម្យ៉ាងវិញទៀតកូនប្រភេទនេះ ចេះជួយសម្រាលការងារឪពុកម្តាយ ថ្ងៃបុណ្យថ្ងៃសីលនិយាយជាមួយឪពុកជាមួយម្តាយថា " ម៉ែឪចាស់ហើយទុកការងារនេះឱ្យកូនធ្វើចុះ " ចេះរៀបចំម្ហូបសម្លទៀនធូបផ្កាភ្ញីជូនមាតាបិតាទៅវត្ត ឱបគាត់ទៅវត្ត ជូនលុយកាក់គាត់សម្រាប់ទុកធ្វើបុណ្យធ្វើទានជាដើម ។ បុត្រប្រភេទនេះឯង ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា **អតិជាតបុត្ត** ជាបុត្រប្រសើរថ្លៃថ្លាបំផុតចេះដឹកនាំមាតាបិតាឱ្យធ្វើបុណ្យធ្វើទានរក្សាសីលស្តាប់ធម៌យ៉ាងនេះ អស្ចារ្យខ្លាំងណាស់ តើមានកូនដូច្នេះប៉ុន្មាននាក់ទៅនៅលើលោកយើងនេះ ?

**២ / អនុជាតបុត្ត :** បុត្រថ្នាក់មធ្យមមានគុណធម៌ស្មើគ្នាទៅនឹងមាតាបិតា ។ បុត្រប្រភេទអនុជាតបុត្រនេះជាបុត្រថ្នាក់កណ្តាលមាននិស្ស័យ មានវាសនា មានគុណធម៌ស្មើគ្នាទៅនឹងមាតាបិតាមាតាបិតាអាចដឹកនាំអូសទាញបាន ។ បើសិនមាតាបិតាជាអ្នកដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរឭក កូននោះក៏លុះក្នុងអំណាចនៃការទូន្មានប្រៀនប្រដៅរបស់មាតាបិតា បានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរឭកដែរ ។ ម្យ៉ាងវិញទៀត បើថា មាតាបិតាជាអ្នកមានសទ្ធា មានសីលនៅក្នុងខ្លួន ចេះធ្វើបុណ្យ

ឱ្យទាន រក្សាសីល ជឿកាន់ព្រះពុទ្ធសាសនា កូននេះឯងក៏ចេះធ្វើបុណ្យធ្វើទាន ចេះទៅវត្តស្តាប់ធម៌រក្សាសីលដូចជាមាតាបិតាដែរ ។ ដោយហោចទៅសូម្បីតែកូនដែលចេះឱនលំទោន ចេះគោរពចាស់ព្រឹទ្ធាចារ្យត្រកូលរៀមច្បងប្រហាក់ប្រហែលគ្នាទៅនឹងលំនាំនៃពូជពង្សវង្សត្រកូលរបស់ខ្លួន ដែលមាតាបិតាជីដូនជីតាធ្លាប់តែប្រព្រឹត្តធ្វើពីមុនមកក៏ដោយ ក៏ឱ្យឈ្មោះថា **អនុជាតបុត្ត** ដែរ ។

**៣ / អវជាតបុត្ត :** បុត្រជាន់ទាបបំផុតមិនស្តាប់តាមបង្គាប់មាតាបិតា ។បុត្រប្រភេទនេះជាបុត្រពាលមិនស្គាល់បុណ្យបាបគុណទោសខុសត្រូវមិនស្តាប់តាមដំបូន្មានពាក្យប្រៀនប្រដៅរបស់មាតាបិតាឡើយ ។បើសិនមាតាបិតាជាអ្នកជឿកាន់តាមព្រះពុទ្ធសាសនាជាអ្នកដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរឭក ស្គាល់បុណ្យស្គាល់បាប ចេះធ្វើទានរក្សាសីល ជាអ្នកមានកល្យាណធម៌នៅក្នុងខ្លួន ។ចំណែកឯកូនវិញជាមនុស្សប្រទូស្តនឹងសាសនា ប្រទូស្តនឹងព្រះពុទ្ធ ប្រទូស្តនឹងព្រះធម៌ ប្រទូស្តនឹងព្រះសង្ឃ ជាបុគ្គលទ្រុស្តសីល មិនជឿលើធម៌អាថ៌ មិនជឿលើសាសនា មិនជឿលើបុណ្យបាបគុណទោសជាដើម ។ បុត្រប្រភេទនេះសែនអាក្រក់ខ្លាំងណាស់មិនដឹងគុណមាតាបិតា ហ៊ានប្រទូស្តតបនឹងមាតាបិតា រហូតដល់អាចវាយដំច្រំធាក់ធ្វើបាបមាតាបិតាក៏មានដែរ ។កូនខ្លះទៀតមាតាបិតាខំប្រឹងសន្សំលុយកាក់ខ្លាំងណាស់ ទម្រាំតែបានបន្តិចបន្តួច មិនហ៊ានចាយវាយទិញបារីម្លូស្លា ទិញនំចំណីហូបចុកទេ ទុកសម្រាប់គ្រាន់តែធ្វើបុណ្យធ្វើទានស្រាប់តែកូននេះទៅឃើញសម្លុតគម្រាមដណ្តើមយកលុយកាក់ពីមាតាបិតាបង្ហើយទៅទៀត ។ មាតាបិតាដែលមានកូនប្រភេទនេះច្រើនតែរងកម្មក្រាស់ រងការឈឺចាប់ រងទឹកភ្នែកមិនចេះអស់មិនចេះហើយ ។ កាលពីដើមឡើយ ពូជពង្សវង្សត្រកូលធ្លាប់តែមានកិត្តិយស មានកេរ្តិ៍ឈ្មោះល្អ ស្រាប់តែមានកូនប្រភេទនេះមក ធ្វើឱ្យក្រុមគ្រួសារទាំងមូលត្រូវធ្លាក់ដុនដាបចុះ រហូតដល់ងើបមុខមិនរួច ។ អវជាតបុត្រនេះ ជាបុត្រដែលប្រទូសរ៉ាយនឹងត្រកូល ផ្តាច់បង់នូវត្រកូល និងបំផ្លិចបំផ្លាញនូវត្រកូលរបស់ខ្លួនជាដើម ។ មាតាបិតាគ្រប់រូបនៅក្នុងលោកនេះតែងតែប្រាថ្នាចង់បាននូវអតិជាតបុត្រ និង អនុជាតបុត្រយ៉ាងក្រៃលែង

គ្មានមាតាបិតាណាម្នាក់ដែលថា ត្រូវការប្រាថ្នាចង់បាននូវអវជាតបុត្រដែលជាកូនផ្តាច់បង់នូវត្រកូលរបស់ខ្លួននោះឡើយ ។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កូនទាំងអស់នេះឯងតែងមានយ៉ាងប្រាកដនៅក្នុងលោកយើងនេះ ។ សូមឱ្យអស់លោកអ្នកអានទាំងឡាយពិចារណាដោយខ្លួនឯងមើលចុះថា តើអស់លោកអ្នកចង់ក្លាយខ្លួនទៅជាកូនប្រភេទណា ? ។/

## បុរាណភាសិត

បើចង់ស្រណុកកុំបាច់សិក្សា ចង់បានវិជ្ជាត្រូវលះក្តីសុខ
វិជ្ជាម្តេចមានដល់អ្នកស្រណុក ម្តេចមានក្តីសុខដល់អ្នកសិក្សា ។/

## បុរាណភាសិត

អ្នកធ្វើទោះត្រូវពិត មិនពេញចិត្តអ្នកចាំថា
អ្នកមិនធ្វើបានខុសត្រង់ណា អ្នកចាំតែថាគង់វិនាសធំ ។/

# រឿងព្រះបាទអជាតសត្រូវ

បានឮមកថា ព្រះបាទអជាសត្រូវជាព្រះរាជបុត្ររបស់ព្រះបាទពិម្ពិសារ ដែលជាស្តេចធំនៅក្នុងដែនមគធៈ។ លុះមានវ័យចម្រើនកាលណា ព្រះបាទពិម្ពិសារក៏បានតែងតាំងព្រះអង្គ ឱ្យស្ថិតនៅក្នុងតំណែងជាព្រះឧបរាជ ។ ព្រះរាជកុមារអង្គនេះ មានឧបនិស្ស័យក្នុងបច្ចុប្បន្នជាតិ គួរនឹងបានសម្រេចនូវសោតាបត្តិផល ប៉ុន្តែដោយសារតែ ការសេពគប់ជាមួយនឹងព្រះភិក្ខុឈ្មោះទេវទត្ត ក៏បានកាត់ផ្តាច់នូវឧបនិស្ស័យនៃមគ្គ និង ផលអស់រលីង ។ ជារៀងរាល់ថ្ងៃ ព្រះបាទអជាសត្រូវ តែងយាងទៅកាន់ទីឧបដ្ឋាករបស់ភិក្ខុទេវទត្តទាំងព្រឹកទាំងល្ងាច ព្រោះទ្រង់ជ្រះថ្លានៅក្នុងឫទ្ធិលោកិយរបស់ភិក្ខុអង្គនោះ ។ នៅថ្ងៃមួយភិក្ខុឈ្មោះទេវទត្តក៏បានចូលទៅរកព្រះបាទអជាសត្រូវដល់ព្រះរាជដំណាក់ ហើយលោកក៏បានពន្យល់ដល់ព្រះរាជកុមារនោះថា : បពិត្រព្រះរាជកុមារ

ក្នុងកាលមុនមនុស្សទាំងឡាយជាអ្នកមានអាយុវែង តែឥឡូវនេះមនុស្សទាំងឡាយជាអ្នកមានអាយុខ្លីណាស់ បើដូច្នោះសូមព្រះអង្គធ្វើគត់ព្រះរាជបិតារបស់ព្រះអង្គទៅនឹងបាន ឡើងគ្រងរាជជាស្ដេចចំណែកឯអាត្មាវិញ នឹងធ្វើគត់ព្រះដ៏មានព្រះភាគ ហើយឡើងជាព្រះពុទ្ធ ។ ព្រះរាជកុមារជឿតាមរួចក៏កាន់យកកាំបិតស្នៀតយាងសំដៅចូលទៅក្នុងរាជបូរី ទាំងកណ្ដាលថ្ងៃ ត្រង់ដើម្បីធ្វើគត់ព្រះវរបិតាដណ្ដើមយករាជសម្បត្តិ ប៉ុន្តែស្រាប់តែនៅក្នុងខណៈនោះពួកអាមាត្រទាំងឡាយដឹងរឿងទាន់ ក៏បានចាប់ព្រះរាជកុមារនាំយកទៅថ្វាយដល់ព្រះរាជា ។ ក្រោយពីព្រះបាទពិម្ពិសារទ្រង់បានជ្រាបនូវសេចក្ដីនោះហើយ ទ្រង់ក៏បានព្រះរាជទាននូវរាជសម្បត្តិឱ្យដល់ព្រះរាជកុមារក្នុងពេលនោះឯង ។ ព្រះរាជកុមារលុះបានសម្រេចតាមបំណងរបស់ខ្លួនហើយ ក៏បានចូលទៅរកភិក្ខុទេវ-ទត្តក្រាបទូលតាមដំណើរសេចក្ដី ។ ភិក្ខុទេវទត្តគ្រាន់តែឮព្រះបាទអជាសត្រូវប្រាប់ដូច្នោះហើយក៏បានពោលឡើងភ្លាមថា បពិត្រព្រះរាជកុមារទ្រង់មិនបានជ្រាបទេថា ព្រះវររាជបិតារបស់ទ្រង់នឹងឱ្យអាត្មាយល់ថា ប្រហែលជាបាន ២ ឬ ៣ថ្ងៃប៉ុណ្ណោះ ព្រះវររាជបិតារបស់ព្រះអង្គ ក៏នឹងឡើងគ្រងរាជសម្បត្តិវិញដោយពិតប្រាកដ ។ បើដូច្នោះ ចូរព្រះអង្គធ្វើគត់ព្រះវររាជបិតារបស់ព្រះអង្គចុះ ដើម្បីកុំឱ្យមានរឿងនោះកើតឡើង ។ ក្រោយមកព្រះបាទអជាតសត្រូវទ្រង់ក៏បានជឿតាមភិក្ខុទេវទត្តម្ដងទៀត រួចទ្រង់បានត្រាស់បញ្ជាឱ្យរាជបុរសចាប់ព្រះវររាជបិតារបស់ខ្លួន យកទៅឃុំឃាំងទុកនៅក្នុងគុកងងឹត គឺ គុកដែលមានតែផ្សែងងងឹតទ្រុបទ្រុលស្មើរតែដកដង្ហើមចេញចូលមិនកើត ហើយទ្រង់បានហាមអ្នកយាមគុកថា អ្នកណាក៏មិនអនុញ្ញាតឱ្យចូលជាដាច់ខាត លើកលែងតែព្រះវរមាតារបស់យើងចេញ ។ ព្រះនាងទេវីទ្រង់បានជ្រាបរឿងនោះហើយ ក៏បានដាក់ព្រះក្រយាស្ងោយក្នុងផ្ដិលមាស នាំយកទៅថ្វាយដល់ព្រះរាជា ។ លុះព្រះបាទអជាតសត្រូវជ្រាបរឿងនោះហើយ ក៏បានប្រាប់ដល់អ្នកយាមគុកថា ហាមមិនឱ្យព្រះវរមាតារបស់យើងយកព្រះក្រយាស្ងោយមកថ្វាយដល់ព្រះវររាជបិតាឡើយ ។ ក្រោយមកព្រះ

នាងទ្រង់បានដាក់ព្រះក្រយាស្ងោយនៅក្នុងផ្នួងសក់ ប៉ុន្តែត្រូវអ្នកយាមគុកតាមដានដឹងចាប់ដកហូតយកអស់ ។ ក្រោយមកទៀតព្រះនាងបានដាក់នឹងស្បែកជើងមាស តែត្រូវអ្នកយាមគុកចាប់ដកយកអស់ទៀត ។ ព្រះនាងទេវីទ្រង់ទាល់ព្រះតម្រិះមិនដឹងត្រូវធ្វើយ៉ាងណា ព្រះនាងទ្រង់ក៏បានសម្រេចព្រះទ័យថា ស្រង់ជម្រះព្រះវរកាយឱ្យស្អាតដោយទឹកមានក្លិនក្រអូប រួចទ្រង់លាបលននូវព្រះកាយដោយអាហារមានរសជាតិ ៤យ៉ាង ទើបព្រះនាងទ្រង់គ្រឿងអលង្ការពីខាងក្រៅ ហើយទ្រង់យាងចូលទៅគាល់ព្រះរាជាដោយព្រះបាទទទេ ។ គួរឱ្យអាណិតព្រះបាទពិម្ពិសារខ្លាំងណាស់ ធ្លាប់តែសោយព្រះក្រយាស្ងោយដ៏វិចិត្រនៅក្នុងព្រះរាជដំណាក់ ឥឡូវនេះទ្រង់បែជាធ្លាក់ខ្លួនមកឱនលិទ្ធយករសជាតិអាហារ ដែលប្រឡាក់ទៅនឹងព្រះវរកាយរបស់ព្រះនាងទេវីទៅវិញ ។ ពេលនោះព្រះបាទអជាតសត្រូវបានសួរទៅអ្នកយាមគុកថា : ព្រះបិតារបស់យើងសោយទីវង្គតហើយឬនៅ ? ពួកអ្នកយាមគុកក្រាបទូលថា បពិត្រមហារាជ ព្រះវររាជបិតារបស់ព្រះអង្គ មិនទាន់សោយទីវង្គតនៅឡើយទេ។ ព្រះបាទអជាតសត្រូវបានសួរទៅទៀតថា ចុះហេតុអ្វីបានជាបិតារបស់យើងមិនទាន់សោយទីវង្គត ? ពួកអ្នកយាមគុកក្រាបទូលថា បពិត្រមហារាជបានជាព្រះបិតារបស់ព្រះអង្គមិនទាន់ចូលទីវង្គត ព្រោះព្រះនាងទេវីចេះតែចូលទៅគាល់សួរសុខទុក្ខជារៀងរាល់ថ្ងៃ ។ព្រះបាទអជាតសត្រូវទ្រង់បានចេញព្រះរាជបញ្ជាថា ចាប់ពីថ្ងៃនេះតទៅ អ្នកទាំងឡាយចូរហាមព្រះមាតារបស់យើង កុំឱ្យចូលគាល់ព្រះបិតាឱ្យសោះ បើអ្នកណាហ៊ានអនុញ្ញាតឱ្យចូលអ្នកនោះនឹងមានទោសជាទម្ងន់មិនខានឡើយ ។ គួរឱ្យអាសូរព្រះនាងទេវីខ្លាំងណាស់ ធ្លាប់តែបាននៅរួមសុខទុក្ខជាមួយគ្នានឹងព្រះស្វាមីក្នុងព្រះរាជដំណាក់ ឥឡូវពេលនេះមិនគួររឿងកើតឡើងយ៉ាងនេះសោះ ។ ព្រះនាងទ្រង់ព្រះកន្សែងសោយសោកាជាខ្លាំង ទ្រង់យាងទៅមាត់ទ្វារគុក លើកកម្បង់អញ្ជលីឱនក្រាបព្រះសិរសាដល់ធរណីថ្វាយបង្គំទូលសូមខមាទោសព្រះស្វាមី រួចពោលរៀបរាប់ទាំងទឹកនេត្រាស្រក់ឱ្យរហាមថា :

បពិត្រព្រះភស្តា ពិម្ពិសារម្ចាស់ប្អូនអើយ

កម្មតាមមកផ្តល់ហើយ　　អម្ចាស់អើយរងវេទនា ។
លំបាកចិត្តស្ទើរធ្លាយ　　ឈឺសព្វកាយណាយចិន្តា
ឃើញអង្គព្រះភស្តា　　ជាប់ទោសាប្អូនសឹងក្ស័យ ។
ធ្វើម្តេចកម្មព្រះអង្គ　　ដែលរូបទ្រង់សាងណាថ្លៃ
រងទុក្ខពន់ពេកក្រៃ　　អ្នកដទៃជួយមិនបាន ។
ឱះ ឱព្រះភស្តា　　តើពេលណាបានរួចប្រាណ
អង្គម្ចាស់បានក្សេមក្សាន្ត　　ធ្វើម្តេចបានចូលទៅជិត ។
ប្អូនឃើញតែរូបទ្រង់　　ជាពូជពង្សវង្សជីវិត
ជាប់ក្នុងគុកងងឹត　　ជាការពិតពេលនេះហើយ ។
សូមក្រាបទៀបបាទា　　លើកហត្ថាមិនព្រងើយ
ផ្គុំម្រាមទាំង ១០ ហើយ　　អម្ចាស់អើយប្អូនសុំទោស ។
សូមអង្គព្រះចមពល　　ស្រស់និមលអត់កំហុស
ដែលប្អូនប្រព្រឹត្តខុស　　ប្អូនសូមទោសព្រះភស្តា ។
ព្រះនាងសូមអភ័យ　　និងក្សត្រថ្លៃម្ចាស់សិរសា
រួចថ្វាយបង្គំលា　　ចរយាត្រាចាកចេញទៅ ។

ធេងធោងអស់កាយា　　ចុកឈឺផ្សាទុក្ខអួលក្តៅ
ទ្រង់យាងទៅលំនៅ　　ម្ចាស់ឆោមឆ្នៅស្ទើរក្ស័យជន្មា។

ព្រះបាទពិម្ពិសារលោកជាព្រះសោតាបន្នបុគ្គល ទោះបីជានៅក្នុងស្ថានភាពបែបណាក៏ដោយ ក៏ព្រះអង្គមិនទោមនស្សដែរ ទ្រង់ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយសារតែការយាងចង្រ្កម ។ ព្រះបាទអជាតសត្រូវបានជ្រាបរឿងនោះហើយ ទ្រង់ក៏បានបញ្ជូននាយខ្មាន់ព្រះកេសឱ្យទៅវះព្រះបាទារបស់ព្រះរាជបិតា ។នាយខ្មាន់ព្រះកេសទាំងឡាយ ក៏បានចាប់ព្រះបាទពិម្ពិសារ វះអង្គន់៧ នូវព្រះបាទប្រឡាក់ដោយអំបិល និងប្រេង ហើយយកទៅដុតរោលកំដៅនឹងគំនរនៃរងើកភ្លើងអុសគគីរដែលកំពុងតែក្តៅ ។ ព្រះបាទពិម្ពិសារឈឺពើតផ្សាក្រៃលែងបើគ្រាន់តែអត់អាហារមិនអីទេថែមទាំងត្រូវគេវះអង្គន់ ៧ ព្រះបាទាមិនឱ្យដើរកើតទៅទៀត គួរឱ្យអាសូរព្រះអង្គណាស់។ សេចក្តីថា : ក្នុងកាលមុនព្រះរាជាអង្គនោះបានពាក់ទ្រនាប់ជើងឡើងជាន់លើទីលានព្រះចេតិយដែលជាកន្លែងសម្រាប់ធ្វើសក្ការៈបូជា ទើបបានជាក្នុងកាលឥឡូវនេះ កម្មពៀរដែលខ្លួន

បានធ្វើនោះតាមមកផ្តល់ ត្រូវគេវះបាទជើងរងទុក្ខវេទនាយ៉ាងនេះឯង។ អាចារ្យពួកខ្លះបានពោលថា បានជាព្រះបាទពិម្ពិសារត្រូវគេវះបាទជើងមកពីមានបាបកម្ម ដោយសារតែព្រះអង្គយាងជាន់លើកន្ទេលដែលគេក្រាលសម្រាប់ព្រះភិក្ខុសង្ឃ ដោយព្រះបាទទាំងពីរដែលមិនបានលាងសំអាតហើយ ។ នៅក្នុងរាត្រីនោះឯង ព្រះបាទពិម្ពិសារមិនអាចអត់ទ្រាំទៅនឹងការឈឺចាប់បាន ទ្រង់ក៏បានសោយទិវង្គតនៅក្នុងគុកនោះទៅ។ គាប់ជួនជាមួយគ្នានោះ ពួកអាមាត្យក៏បានចូលក្រាបទូលព្រះបាទអជាតសត្រូវថា " បពិត្រព្រះអង្គ ! បុត្ររបស់ព្រះអង្គប្រសូតហើយ" ។ ព្រះបាទអជាតសត្រូវត្រេកអរខ្លាំងណាស់ រំភើបញាប់ញ័រសព្វសារពាង្គកាយ នឹកឃើញថា ខ្លួនមានកូន មិនដែលធ្លាប់មានកូនសោះពីមុនមក ។ ព្រះបាទអជាតសត្រូវក៏បាននឹកឃើញដល់បិតារបស់ខ្លួនថា ឱហ្ន៎ ! បិតារបស់អញកាលដែលប្រសូតអញមក មិនដឹងជាគាត់ស្រឡាញ់អញយ៉ាងណាទេ ? ដូច្នេះអញមិនគួរយកគាត់ទៅឃុំឃាំងទុកនៅក្នុងគុកងងឹតសោះឡើយ ។ ក្នុងខណៈនោះ មានអាមាត្យម្នាក់ទៀតចូលមកក្រាបទូលថា បពិត្រព្រះសម្មតិទេពព្រះបរមរាជបិតារបស់ព្រះអង្គបានសោយទិវង្គតកាលពីយប់មិញនេះហើយ គ្រាន់តែបានឮពាក្យនោះភ្លាម ព្រះបាទអជាតសត្រូវក៏ភាន់ភាំងដេកដួលសន្លប់បាត់បង់ស្មារតីមួយរំពេច។ ក្រោយពីបានដឹងខ្លួនពីសន្លប់វិញហើយ ព្រះបាទអជាតសត្រូវក៏បានយាងសំដៅទៅក្នុងគុកយំឱបក្រសោបព្រះបិតាអួលផ្សាឈឺរីងរៃនៅក្នុងទ្រូងក្រៃលែង។

និយាយពីព្រះនាងទេវី លុះដឹងដំណឹងថា ព្រះស្វាមីរបស់ខ្លួនសោយទិវង្គតដូច្នេះ ព្រះនាងក៏បានសោយព្រះកន្សែងសោកា យំរៀបរាប់អំពីការកំសត់កម្រគ្រប់អនុស្សាវរីយ៍ទាំងឡាយ ដែលបានសាងរួមគ្នាជាមួយនឹងព្រះស្វាមី តាំងតែពីបានគ្នាជាប្តីប្រពន្ធមក ។ ឥឡូវនេះព្រះអង្គក៏បានសោយទិវង្គតទាំងការឈឺចាប់រងទុក្ខវេទនាយ៉ាងក្រៃលែងជាទីបំផុត បន្សល់ទុកឱ្យទូលបង្គំនៅឯកាតែម្នាក់ឯងកណ្តោចកណ្តែងចំបែងចិត្តក្រៃ ។ ស្រាប់តែពេលនោះ ព្រះបាទអជាតសត្រូវបានចូលមកដល់ ព្រះនាងទ្រង់ក៏បានយំពោលរៀបរាប់ស្តីបន្ទោសថា :

បពិត្រមហារាជ    លោភក្នុងអំណាច    ចិត្តទ្រឹសប្ញស្សា
សាហាវឃោរឃៅ    កាចដូចសត្វខ្លា    ហ៊ានវាយប្រហារ
បិតាបង្កើត ។

នេះឬមហារាជ    ចិត្តក្លាអង់អាច    រូបកាយល្អឆើត
ហ៊ានសម្លាប់អ្នក    មានគុណបង្កើត    ជាស្រុកកំណើត
ដែលផ្តល់រូបកាយ ។

អាសូរខ្លាំងណាស់    កូនអត់ចេះខ្មាស    ហ៊ានប្រទូសរ៉ាយ
នឹងបិតាឯង    ដោយចិត្តម៉ាក់ងាយ    ព្រោះចង់សប្បាយ
ក្លាយខ្លួនជាស្តេច ។

ឥឡូវសមហើយ    ឱកូនប្រុសអើយ    អ្នកបានសម្រេច
តាមគោលបំណង    ដែលអ្នកប្តូរផ្តាច់    ចង់ក្លាយជាស្តេច
គ្រប់គ្រងផែនដី ។

បង្ហាញអំណាច    ឱ្យគេកោតខ្លាច    ថាស្តេចល្បាញល្បី
ដល់ប្រជារាស្ត្រ    នាម៉ឺនមន្ត្រី    ខ្លាចបុណ្យបារមី
ចេស្តាព្រះអង្គ ។

អ្នកមិនសមសោះ    កើតមកជាមនុស្ស    មិនគួរបើទ្រង់
សម្លាប់បិតា    ដោយការឆោតល្ងង់    ទៅតាមចំណង់
ចង់ក្លាយជាធំ ។

អ្នកមិនដឹងសោះ    អំពើធ្វើនោះ    អ្នកណាខ្លះយំ
អ្នកណាឈឺចាប់    អ្នកណាក្រៀមក្រំ    អ្នកណាខ្លះយំ
ងំក្នុងចិន្តា ។

ក្រោយពីការយំសោកខ្សឹកខ្សួលសោយព្រះកន្សែងសោកាចប់សព្វគ្រប់ហើយ ព្រះបាទអជាតសត្រូវទ្រង់ក៏បានបានថ្វាយព្រះភ្លើងព្រះសពរបស់ព្រះបាទពិម្ពិសារនោះ ដោយខ្លួនព្រះអង្គផ្ទាល់ ។ ចំណែកឯភិក្ខុទេវទត្ត ក្រោយពីបានប្រឹក្សាគ្នាជាមួយនឹងព្រះបាទអជាតសត្រូវមក ក៏បានព្យាយាមប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេង ៗ

ដោយបំណងថា អញនឹងសម្លាប់ព្រះសាស្តា រហូតដល់ការបំបែកបំបាក់ព្រះភិក្ខុសង្ឃជាដើម ។ នៅទីបំផុតផែនដីក៏បានស្រូបយកភិក្ខុទេវទត្តបាត់ទៅ ។ តាមន័យដែលលោកសម្តែងថា ភិក្ខុទេវទត្តក្រោយពេលព្រះធរណីស្រូបយកទៅ ក៏បានទៅកើតនៅក្នុងអវិចីមហានរក ។ ព្រះបាទអជាតសត្រូវគ្រាន់តែបានជ្រាបដំណឹងនោះហើយ ទ្រង់មានសេចក្តីភ័យខ្លាចតក់ស្លុតរន្ធត់យ៉ាងខ្លាំងដោយទ្រង់មានព្រះតម្រិះថា ផែនដីមុខជានឹងស្រូបអញទៀតមិនខានឡើយ ព្រោះអញក៏ធ្លាប់បានចូលដៃចូលជើងរួមផ្សំគំនិតគ្នាជាមួយនឹងភិក្ខុទេវទត្តនោះដែរ ។ ចាប់តាំងពីព្រះបាទអជាតសត្រូវបានសម្លាប់ព្រះបិតាបង្កើតរបស់ខ្លួនឯងមក ទ្រង់មិនដែលធ្លាប់បានផ្ទំលក់សុខស្រួលម្តងណាឡើយ ចេះតែក្តៅរោលរាលសព្វសារពាង្គកាយ អន្ទះអន្ទែង ភិតភ័យភាន់ភាំងស្មារតីដូចជាត្រូវផែនដីស្រូបទាំងរស់ ត្រូវអណ្តាតភ្លើងក្នុងអវិចីមហានរកមកឆាបឆេះទាំងស្រស់ឬថា ដូចជាទ្រង់ផ្ទំផ្ងាលើផែនដី ហើយត្រូវបុគ្គលកាន់យកដែកដ៏ស្រួចរន្ទាលច្រាលឆ្អៅមកចាក់ទម្លាយព្រះកាយរបស់ទ្រង់ទាំងរស់ដូច្នោះឯង ។ ព្រះបាទអជាតសត្រូវ សូម្បីតែសេចក្តីស្ងប់ព្រះរាជហឫទ័យត្រឹមតែមួយស្របក់ ក៏ទ្រង់មិនអាចបានដែរ ព្រោះទ្រង់ចេះតែរសាប់រសល់បែបនេះរហូត ។ ក្រោយមកទ្រង់ក៏បានប្រជុំសព្វមុខនាម៉ឺនមន្ត្រីអ្នកប្រាជ្ញល្បាញល្បីនៅក្នុងដែនអាណាចក្ររបស់ខ្លួន ដើម្បីប្រកាសស្វែងរកបុគ្គលណា ដែលអាចធ្វើឱ្យព្រះអង្គបានស្ងប់ព្រះរាជហឫទ័យ ។ ប៉ុន្តែទោះជាព្រះបាទអជាតសត្រូវបានប្រទាននូវរង្វាន់ជាទីគាប់ចិត្តយ៉ាងណាក៏ដោយ ក៏គ្មានបុគ្គលណាម្នាក់អាចធ្វើឱ្យទ្រង់បានសុខស្ងប់ចាកសេចក្តីរសាប់រសល់ រវើរវាយ នោះបានឡើយ ។ ខណៈនោះស្រាប់តែមានគ្រូពេទ្យម្នាក់ឈ្មោះជីវកកោមារភត្យបានចូលមកក្រាបទូលថា មានតែព្រះសម្មាសម្ពុទ្ធមួយអង្គប៉ុណ្ណោះទើបទ្រង់អាចជួយរឿងនេះបាន ។

ក្រោយពេលព្រះបាទអជាតសត្រូវបានស្តាប់ព្រះធម៌ទេសនារបស់ព្រះពុទ្ធហើយ ទ្រង់ក៏បានដល់នូវព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ជាទីពឹងទីរលឹកស្មើដោយជីវិត ។ ព្រះរាជាអង្គនេះបានជ្រះថ្លាបូជានូវគ្រឿងសក្ការៈទាំងឡាយចំពោះព្រះពុទ្ធសាសនាយ៉ាងក្រៃ-

លែង ។ ព្រះបាទអជាតសត្រូវទ្រង់បានទំនុកបម្រុងព្រះពុទ្ធសាសនា និងព្រះសម្មាសម្ពុទ្ធព្រមទាំងព្រះភិក្ខុសង្ឃដរាបដល់អស់ព្រះជន្ម ។ ជាពិសេសទៅទៀតនោះគឺទ្រង់បានទំនុកបម្រុងនូវបឋមសង្គាយនា អស់រយៈពេល ៧ ខែ ។ ប៉ុន្តែទោះបីជាព្រះរាជាបានធ្វើបុណ្យធ្វើកុសលច្រើនយ៉ាងណាក៏ដោយ ក៏មិនអាចគេចឱ្យផុតរត់ឱ្យរួច អំពីបាបកម្មដែលខ្លួនបានធ្វើនោះឡើយ ។លុះដល់ព្រះបាទអជាតសត្រូវសោយទីវង្គតទៅបាបកម្មដែលខ្លួនបានធ្វើអាចឱ្យទ្រង់ទៅកើតនៅក្នុងមហានរកឈ្មោះអវិចីបាន តែដោយអំណាចនៃធម្មទាន ការទំនុកបម្រុងព្រះសាសនា ទ្រង់ក៏បានចូលមកកើតត្រឹមលោហកុម្ភ-នរកដល់នូវទុក្ខវេទនាអស់កាលជាយូរអង្វែង ហើយក្រោយពីងើបពីនរកមកវិញ ព្រះរាជាអង្គនេះនឹងបានជាព្រះបច្ចេកពុទ្ធមួយអង្គមាននាមប្រាកដថា **ជីវិតវិសេស** នៅក្នុងអនាគតកាល ។

ការសេពគប់មានអំណាចខ្លាំងណាស់ បើសេពគប់ត្រូវបានផលមកវិញក៏ត្រូវដែរ ប៉ុន្តែបើសេពគប់ខុសបានផលមកវិញ គឺដូចជាព្រះបាទអជាតសត្រូវ ដែលហ៊ានសម្លាប់បិតាបង្កើតរបស់ខ្លួន ។ ការសម្លាប់មាតាបិតាមានទោសដល់ថ្នាក់អនន្តរិយកម្មធ្ងន់ធ្ងរយ៉ាងណា ដូច្នេះការចិញ្ចឹមទំនុកបម្រុងមាតាបិតា ក៏មានអានិសង្សច្រើនខ្លាំងក្លាយ៉ាងនោះដែរ ។ ទោះបីជាស្ថិតនៅក្នុងស្ថានភាព កាលៈទេសៈបែបណាក៏ដោយ សូមឱ្យកូនប្រុសស្រីទាំងឡាយបានស្ថិតនៅក្រោមដំបូលនៃព្រហ្មវិហារធម៌របស់មាតាបិតា ឱ្យបានគ្រប់ ៧ គ្នាតរៀងទៅហោង ។/

# សុភាសិត

| | | |
|---|---|---|
| បានប្រាក់ខែ | តែជីវិត | ពិតជាអស់ |
| គួរអាលោះ | អាល័យស្តាយ | សាមសិបថ្ងៃ |
| កុំព្រោះទ្រព្យ | កប់ជីវិត | ពិតគ្មានន័យ |
| គួរលកលៃ | ថ្លៃជីវិត | ផលិតបុណ្យ ។/ |

# គុណមាតាបិតា

មុននឹងថ្លាថ្លែងថែងពណ៌នា　　លើកហត្ថវន្ទាថ្វាយបង្គំ
ព្រះពុទ្ធព្រះធម៌ដ៏ជាធំ　　និងសង្ឃឧត្តមត្រៃរតនា ។
រួចនឹងថ្លាថ្លែងថែងបរិយាយ　　រៀបរាប់អធិប្បាយស្រាយបញ្ហា
ប្រាប់ជនអ្នកនៅក្នុងសាសនា　　គ្រាន់បានជ្រះថ្លាតាមនិស្ស័យ ។
មាតាបិតាលោកមានគុណ　　ធ្ងន់នោះសែនធ្ងន់ពន់ពេកក្រៃ
ធ្ងន់លើសប្រថពីហួសឧបមេយ្យ　　ផុតហួសវិស័យនឹងដឹងបាន ។
តែទោះយ៉ាងណាគង់ដឹងខ្លះ　　ទោះជាមិនច្បាស់តាមលំអាន
រៀបរាប់ឃ្លោងឃ្លាទាំងប៉ុន្មាន　　ចងជានិទានប្រាប់ជនា ។
តាំងតែពីកូននៅក្នុងផ្ទៃ　　លោកអ្នកថ្នមបីថែរក្សា
ប្រយ័ត្នប្រយែងគ្រប់តិរិយា　　គ្រប់ពេលវេលាគ្មានចន្លោះ ។
លុះដល់ពេលកូនកើតមកហើយ　　អ្នកមិនកន្តើយតែងសង្គ្រោះ
ចិញ្ចឹមថ្នាក់ថ្នមឱ្យទឹកដោះ　　ចង់ឱ្យកូនរស់ខ្ពស់ដូចគេ ។
អ្នកបីអ្នកបមថ្នមរក្សា　　ប្រើដោយហត្ថាអ្នកទាំងទ្វេ
បបោសអង្អែលសព្វកាយេ　　អ្នកច្រៀងបំពេដោយវាចា ។
តាំងតែពីកូនមានរូបកាយ　　អ្នកតែងខ្វល់ខ្វាយថែរក្សា
ចិញ្ចឹមបីបាច់កូនស្ងួនភ្ងា　　មិនអាចពណ៌នាឱ្យគ្រប់បាន ។
កូនបន្ទោបង់មូត្រលាមក　　របស់គម្រក់ទាំងប៉ុន្មាន
អ្នកចាប់អ្នកកាន់ប្រឡាក់ប្រាណ　　កូនយំថ្ងើរម៉ាណអ្នកភិតភ័យ ។
បពិត្រលោកអ្នកដ៏មានគុណ　　អ្នករងទុក្ខធ្ងន់ពន់ពេកក្រៃ
អ្នកមើលថែកូនទាំងយប់ថ្ងៃ　　ទាំងប្រុសទាំងស្រីឱ្យរស់បាន ។
នេះគឺព្រះគុណរបស់អ្នក　　គុណជ្រៅអនន្តអប្បមាណ
ទោះបីកូនខុសលោះលាថ្កាន　　ចិត្តលោកស្រោកស្រាន្តមិនជេរស្តី ។
ដូច្នេះកូនសូមលើកហត្ថា　　បន្ទន់កាយាឱនសិរសី
ថ្វាយបង្គំអ្នកដោយមេត្រី　　ដោយចិត្តភក្តីជាប្រធាន ។
សូមអ្នកបានសុខទាំងយប់ថ្ងៃ　　កុំបីមានភ័យមកបៀតបៀន
គ្រោះកាចចង្រៃទាំងប៉ុន្មាន　　ឆ្ងាយចាកសន្តានតរៀងទៅ ។/

# ភ្លើងអាចរលត់ដោយភ្លៀងរលឹម

ហៃអស់កូនម៉ែប្រុសស្រីទាំងឡាយ   ចូរកូនស្ដាប់ម្ដាយណាកូនមាសស្ងួន
ឥឡូវធំហើយត្រូវថែទាំខ្លួន   កុំខឹងរត់ពួនដូចនៅកុមារ ។
កាលកូននៅតូចកូនខឹងអាងយំ   ពេលនេះកូនធំកុំប្រើហិង្សា
ត្បិតមនុស្សសព្វថ្ងៃច្រើនខ្វះមេត្តា   កូនទៅទីណាប្រយ័ត្នសម្ដី ។
ឯកូនស្រីម៉ែកូនកុំមាយា   ត្បិតប្រុសច្រើនគ្នាឆាប់មាក់ងាយស្រី
រូបកូននៅក្មេងកុំភ័យអត់ប្ដី   ត្បិតមនុស្សប្រុសស្រីពិតមានគូព្រេង ។
ចំណែកកូនប្រុសត្រូវខំពុះពារ   ស្វែងរកវិជ្ជាទាន់ខ្លួននៅក្មេង
សេពគប់បណ្ឌិតពិតឥតវង្វេង   ញៀនស្រាស្រីល្បែងតែងតែវិនាស ។
ម៉ែរីករាយណាស់ពេលកូនសាងផ្នួស   គិតថាកូនបួសរស់រៀនធម៌ព្រះ
ម៉ែខំដាក់បាត្រសម្អាតមុខផ្ទះ   ទៅវត្តសំពះស្ដាប់ធម៌ទេសនា ។
ប៉ុន្តែម៉ែត្រូវខកចិត្តពេកក្រៃ   នៅពេលដែលថ្ងៃកូនលាសិក្ខា
ម៉ែអស់សង្ឃឹមតឹងណែនឱរា   មិននឹកស្មានថាលោកកូនសឹកទេ ។
ម៉ែខ្លះមិនចង់ឱ្យកូនបួសឡើយ   ចង់ឱ្យរៀនហើយប្រលងនឹងគេ
ម៉ែយំរន្ធត់ពេលឃើញមាសមេ   បួសជាសាមណេរទៅសុំច្បាប់គ្រូ ។
ម៉ែចង់ឱ្យកូនសឹកចូលរៀនវិញ   ខ្វះខាតម្ដេចមិញម៉ែអ្នកគិតគូរ
ព្រោះម៉ែខ្លាចកូនបួសមិនបានយូរ   សឹកមករកគូឥតមុខរបរ ។
កូនម៉ែរៀនឈរជំហរឱ្យមាំ   ត្រូវសាងសន្សំតែអំពើល្អ
កុំដើរកន្លងជាន់ខ្នងអ្នកក្រ   ក្រែងគេដល់កកូនត្រូវរងគ្រោះ ។
កូនត្រូវចេះរត់បត់តាមសង្គម   រឿងរ៉ាវតូចធំកុំនាំជម្លោះ
យកឈ្នះអ្នកទាបដោយការសង្គ្រោះ   យកឈ្នះអ្នកខ្ពស់ដោយការវន្ទា ។
ម៉ែចង់ឱ្យកូនឈ្នះក្រៅសង្គ្រាម   បើកូនព្យាយាមឈ្នះអ្នកផងគ្នា
កូនត្រូវប្រយ័ត្នគ្រប់ម៉ាត់គ្រប់ឃ្លា   ឆ្កែឆ្កួតពស់ជាវាឥតស្គាល់ម្ចាស់ ។
កាយតែងគ្រាំគ្រាជរានាំទៅ   តែកេរ្តិ៍ឈ្មោះនៅជិតដាមយ៉ាងច្បាស់
រទេះឡានខូចមានគ្រឿងបន្លាស់   ខូចអស់កេរ្តិ៍ខ្មាសគ្មានអ្វីផ្លាស់ឡើយ ។
ពេលអស់ពីម៉ែត្រូវថែបងប្អូន   ម៉ែសង្ឃឹមកូនជូនប្អូនដល់ត្រើយ
បើកូនយល់ជាតិញ្ញាតិពិតធូរស្បើយ   កូនធ្វើតាមហើយម៉ែអរឥតថ្លឹម ។
សូមកូនមាសម្ដាយរំសាយហិង្សា   ចេះផ្សាយមេត្តាដោយស្នាមញញឹម
ភ្លើងអាចរលត់ដោយភ្លៀងរលឹម   កូនទីសង្ឃឹមនៃជីវិតម៉ែ ។/

ដោយឧបាសក : **គុយ សុធន**

# បាបកម្មចិញ្ចឹមកូន

ហៃអស់កូនប្រុសស្រីផងទាំងឡាយ គ្រប់រូបគ្រប់កាយក្មេងចាស់ម្តេចម្តា
ត្រូវតែលកលៃគិតពិចារណា មាតាបិតាមានគុណវែងឆ្ងាយ ។
ពួកគាត់នៅរស់រកស៊ីភូតភរ មិនដែលត្រេកអរនឹងការសប្បាយ
ព្រោះគាត់ខ្លាចកូនជួបក្តីអន្តរាយ គាត់តែងខ្វល់ខ្វាយគ្រប់ពេលវេលា ។
រកស៊ីប្រវ័ញ្ចបំបាត់ជីវិត ក៏គាត់មិនគិតរឿងកម្មវេរា
ធ្វើម្តេចឱ្យតែកូនបានសិក្សា នោះទើបមាតាបិតាពេញចិត្ត ។
មាតាបិតាធ្វើបាបគ្រប់យ៉ាង តែនាំសំណាងដល់បុត្រវរមិត្ត
ឱ្យកូនបានសុខសប្បាយក្នុងចិត្ត ទោះជាជីវិតរងទុក្ខឈឺផ្សា ។
គាត់ខំរកស៊ីរែកពុនជិតឆ្ងាយ មិនខ្លាចនឿយណាយហត់ក្នុងកាយា
ហាលថ្ងៃហាលខ្យល់ហាលភ្លៀងម្តេចម្តា ក៏គាត់មិនថាទេកូនប្រុសស្រី ។
ពួកគាត់រកស៊ីប្រព្រឹត្តទុច្ចរិត សម្លាប់ជីវិតសត្វផងដទៃ
ធ្វើបាបគ្រប់យ៉ាងជារៀងរាល់ថ្ងៃ ព្រោះកូនប្រុសស្រីនៅក្នុងគ្រួសារ ។
ព្រោះហេតុតែការចិញ្ចឹមកូន ទើបគាត់បិទពួនរបស់នានា
ភូតភរកុហកប្រវ័ញ្ចគ្រប់គ្រា ដើម្បីស្ងួនភ្ងាបានរស់សុខសាន្ត ។

ឥឡូវបាបកម្មដេញតាមមកដល់ កម្មតាមហុចផលមិនដែលស្រាកស្រាន្ត
ឱ្យគាត់រងទុក្ខនៅក្នុងសន្តាន អកុសលរំខានគាត់គ្រប់វេលា ។
ហេតុនេះសូមកូនប្រុសស្រីទាំងឡាយ លកលៃខ្វល់ខ្វាយគិតពិចារណា
ឃើញទេបាបកម្មមាតាបិតា ព្រោះតែនរណាទើបគាត់អួលក្តៅ ។
មិនមែនដើមហេតុក៏ព្រោះនរណា ព្រោះបុត្រសង្សារណាមាសឆោមឆ្លៅ
ទើបបានជាកម្មតាមមកសំដៅ ឱ្យផលម៉ែឪរងទុក្ខយ៉ាងនេះ ។/

# កូនស្តាយក្រោយណាស់

កូនស្តាយក្រោយណាស់ មិនគួរកម្មក្រាស់ ព្រាត់អ្នកមានគុណ
ឱ្យកូនទឹកភ្នែក រងកម្មទារុណ វាសនាស៊យស៊ុន
កំព្រាឯកា ។

កូនស្តាយម៉ែឪ ធ្លាប់តែនិត្យនៅ មើលថែរក្សា
ចិញ្ចឹមបីបាច់ ដល់កូនស្ងួនភ្ងា ឱ្យរស់គ្រប់គ្នា
មកដល់សព្វថ្ងៃ ។

កូនសែនស្តាយក្រោយ មិនគួរថ្លោះធ្លោយ ព្រាត់ទាំងអាល័យ

ព្រាត់ម្ដាយឪពុក រហូតពេលក្ស័យ មិនមានទេថ្ងៃ

ថាបានជួបវិញ ។

ស្ដាយធ្លាប់ថ្នមបី ដល់កូនប្រុសស្រី មិនឱ្យទោម្នេញ

ឱ្យកូនបានសុខ សប្បាយពេញលេញ មិនគិតចំណេញ

ពីកូនឡើយណា ។

ស្ដាយធ្លាប់បំពេ សម្លេងលាន់ទ្វេ ពិរោះអស្ចារ្យ

ច្រៀងថ្នាក់ថ្នមកូន ដោយចិត្តមេត្តា ឱ្យកូនគ្រប់គ្នា

បានស្ដាប់សម្ដី ។

ស្ដាយហួសពីស្ដាយ មិនគួរឃ្លាតឆ្ងាយ ព្រាត់ចាកលោកិយ

ឱ្យកូនកំព្រា រងារាល់ថ្ងៃ មិនដឹងម្ចាស់ថ្លៃ

បាត់ទៅទីណា ។

ស្ដាយខានបានស្ដាប់ វាចាសូរស័ព្ទ ប្រាប់កូនគ្រប់គ្នា

ឱ្យកូនធ្វើល្អ ស្គាល់ញាតិមីងមា ឱ្យប្រឹងសិក្សា

ក្រេបយកចំណេះ ។

ស្ដាយអើយសែនស្ដាយ ស្ដាយឪពុកម្ដាយ ស្មើរតែរលេះ

រលួយឱរា នៅក្នុងពេលនេះ ជាតិជាអ្នកចេះ

រិះគិតបូជា ។

ស្ដាយទឹកន្លែង ឱ្យកូនវង្វេង ចំបែងចិន្ដា

ឥឡូវបាត់អ្នក មិនដឹងទៅណា ឱ្យកូនឈឺផ្សា

ចំបែងហឫទ័យ ។

កូនស្ដាយអ្នកណាស់ ហេតុអ្វីព្រាត់ប្រាស អ្នកម្ដាយពិសី

ព្រមទាំងឪពុក ឱ្យកូនរីងរៃ ស្មើរតែក្សិណក្ស័យ

ក្នុងគ្រានេះហោង ។/

# ម៉ែត្រេកអរនឹងកូនសាងផ្នួស

ម៉ែខកចិត្ត ត្បិតកូនលា ចាកសិក្ខា

មិនហ៊ានថា ហាវាស្លាក់ ខ្វាក់វាស្លែង
បើប្រឹងឃាត់ នាំបាបមាត់ តែម្នាក់ឯង
ទើបថ្លឹងថ្លែង ឈប់ហួងហែង លែងចរចា ។
បើជាប្រុស ម៉ែនឹងបួស ជំនួសកូន
តែលាភសូន្យ ជោគអាប់ឱន ភេទហីនា
មិនអនុញ្ញាត ឱ្យស្ត្រី សាងបព្វជ្ជា
ដូចកាលគ្រា ព្រះសាស្តា គង់នៅឡើយ ។
មិនថ្វីទេ បើពេលនេះ ហេតុបច្ច័យ
អូសទាញដៃ កូនប្រុសថ្លៃ ឆ្ងាយពីត្រើយ
ទោះម៉ែតឹង ចង្អៀតចិត្ត ក៏ពិតហើយ
ប៉ុន្តែណ្ហើយ ! គង់ពេលក្រោយ កូននឹងយល់ ។
ថាមាសប្រាក់ លាភយសស័ក្តិ ថ្នាក់មន្ត្រី
ទាំងសេដ្ឋី សេនាបតី ស្តេចទ្រង់ពល

គង់នៅចាញ់ កម្លាំងបុណ្យ ផ្តួសឱ្យផល
ជាកុសល នាំកូនដល់ ផ្តល់និព្វាន ។
កូនដឹងទេ ក្រពេកក្រៃ បច្ច័យល្មម
ក្រដល់ព្រម ទាំងសទ្ធា ដែលកូនមាន
ក្របានកើត មកជាមនុស្ស ទាំងធនធាន
ក្រធម្មយាន ព្រះប្រទាន ទុកកេរឱ្យ ។
ក្រម្យ៉ាងទៀត ក្រកើតទាន់ ពុទ្ធសាសនា
ក្រអាចារ្យ ប្រោសទេសនា គ្រប់ជ្រុងជ្រោយ
ថ្ងៃមរណៈ កាន់តែខិត ជិតណាស់ហើយ
មាសម្តាយអើយ ម្តេចកន្តើយ លែងខន្តី ។
ក្នុងពេលនេះ គ្មានអ្វីសោះ ជាទីពួន
ឱ្យកូនស្ងួន បានរួចខ្លួន ចាកទុក្ខភ័យ
តែបើអ្នក ពឹងលើព្រះ រតនត្រ័យ

កូនប្រុសថ្លៃ រួចភពបី ផុតទារុណ ។
កាលកូនបួស សមឥតខ្ចោះ ម៉ែញញឹម
មានសង្ឃឹម កូនថ្វាយខ្លួន បម្រើបុណ្យ
តែទោះសឹក ក៏កុំឆ្ងាយ ពីពុទ្ធគុណ
ម៉ែភ័យស្លន់ ខ្លាចតណ្ហា ខ្ទីកូនប្រើ ។/

ដោយឧបាសិកា : **ខិម លក្ខណា**

# អវសានកថា

ខ្ញុំអ្នករៀបរៀងឈ្មោះ **ឈុំ ឈន់** លើកហត្ថបន្ទន់ឱនសិរសា
ក្រាបថ្វាយបង្គំព្រះសាស្តា ដែលទ្រង់ឈ្នះមារពេលបានត្រាស់ ។
ក្រាបថ្វាយបង្គំឆ្ពោះព្រះធម៌ ដែលពុទ្ធបវរបានប្រកាស
បានត្រាស់សម្តែងថ្លែងយ៉ាងច្បាស់ ប្រៀបបានស្គរដាស់ពួកសត្វលោក ។
បង្គំព្រះសង្ឃគម្រប់បី សាវ័កជិនស្រីដែលងុយងោក
បានឮស្គរដាស់ទើបភ្ញាក់ក្រោក ផុតចាកការងោកក្នុងកិលេស ។
ខ្ញុំសូមបង្គំបន្ទន់ប្រាណ សូមលោកអ្នកអានបានចំណេះ
បានការចេះដឹងប្រឹងត្រិះរិះ ខ្ញុំសូមឈប់ស្លេះចប់សេចក្តី ។
សូមបានសម្បត្តិ ៣ ប្រការ សម្បត្តិមនុស្សានិងសួគ៌ាល័យ
ព្រមទាំងសម្បត្តិដ៏ប្រពៃ និព្វានគ្មានអ្វីប្រដូចឡើយ ។
ដោយអំណាចបុណ្យនៃធម្មទាន ដែលរូបខ្ញុំបានកសាងហើយ
សូមឱ្យរូបខ្ញុំបានសុខស្បើយ ឆ្លងផុតដល់ត្រើយគឺព្រះនិព្វាន ។/

## ឯកសារពិគ្រោះ

១ / វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ( ផ្សាយចេញពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ) ។

២ / គម្ពីរមង្គលត្ថទីបនីបាលីភាគ ១ - ២ ( ដោយព្រះ-ពុទ្ធឃោសាចារ្យ ) ។

៣ / គម្ពីរមង្គលត្ថទីបនីប្រែភាគ ១ - ២ ( ដោយព្រះភិក្ខុវិនយធរោ : **មហាឃិន នឿន** ) ។

៤ / បទានុក្រមបាលីភាគ ១ - ២ - ៣ ( ដោយព្រះគ្រូសិរីសោភ័ណ : **គីម តូរ** ) ។

៥ / សៀវភៅគុណព្រះកន្លោង ( ដោយ **ត្រង ហៀង** ) ។

៦ / សៀវភៅជីវិតម៉ែ ( ដោយព្រះភិក្ខុ **វិរិយបណ្ឌិតោ : ប៉ាង ខាត់** ) ។

៧ / ឯកសារផ្សេងៗ ជាច្រើនទៀត ។/

## នាមសប្បុរសជនចូលបច្ច័យបោះពុម្ពសៀវភៅ

១ ភិក្ខុ **បែន វិបុល + ** ឧបាសិកា **ចាយ នៃលី** (ភ្នំពេញ)...... ២១០.០០០៛

២ ពុទ្ធបរិស័ទវត្តនន្ទីជោត្តនារាម ( ខ្វោកខាងជើង )......... ១០៥.០០០៛

៣ ពុទ្ធបរិស័ទវត្តព្រះឈរ ( ស្រុកកំពង់ត្របែក )............. ១០០.០០០៛

៤ ញោមប្រុស **សួន ឈុំ** និង ញោមស្រី **ឃិន ហ៊ាន** ព្រមទាំងបងប្រុស **ឈុំ ឈាន** ( ភូមិព្រៃខ្នុរ ) ...................................... ១០០.០០០៛

៥ ព្រះភិក្ខុឧទ្ទេសាចារ្យ **ផុន សោភ័ណ+**ញោមស្រី **ហេង មី** ... ៦០.០០០៛

៦ ពុទ្ធបរិស័ទវត្តអង្គរឃ្លោកថ្មី ( ស្រុកមេសាង )................. ៥៧.៤០០៛

៧ ព្រះភិក្ខុ **សុខ ធម្មភាសី** ( គ្រូសូត្រស្តាំវត្តសំសមី )........ } ៥០.០០០៛

៨ ញោមប្រុស **សុខ តេង +** ញោមស្រី **តុង គីមលី** ...........

៩ សាមណេរ **ឡូន ឡា** ( វត្តសំសមី ) ........................... ៥០.០០០៛

១០ ទាយក **សារឿន +** ឧបាសិកា **ផេង ធី** ( ភូមិធ្នង់ )......... ៥០.០០០៛

១១ ពុទ្ធបរិស័ទវត្តបុញ្ញក្ខេត្តារាម ( ស្រុកកំពង់លាវ )........... ៤២.០០០៛

១២ សាមណេរ **គ្រាល ផានិត** ( វត្តប្ញស្សីជុកខាងជើង )....... ៣៥.០០០៛